# របាយការណ៍សង្ខេប

របាយការណ៍សកលលោកតាមដានការអប់រំសម្រាប់ទាំងអស់គ្នា ២០០៥




# សារប្រយោជន៍របស់គុណភាព

ការអប់រំសម្រាប់ទាំងអស់គ្នា

## សារប្រយោជន៍របស់គុណភាព

# របាយការណ៍សង្ខេប

UNESCO Publishing

ចំណេះដឹងដែលបានយកមកប្រើ និងការបង្ហាញសម្ភារនៅក្នុងការបោះពុម្ពនេះមិនសំដៅទៅលើការបញ្ចេញមតិណាមួយរបស់អង្គការយូណេស្កូទាក់ទងនឹងស្ថានភាពស្របច្បាប់នៃប្រទេសណាមួយ ទឹកដី ទីក្រុង ឬតំបន់ណាមួយ ឬនៃសិទ្ធិអំណាចរបស់ខ្លួនឬទាក់ទងនឹងកាកំណត់ព្រំដែនឬព្រំប្រទល់របស់ប្រទេសណាមួយឡើយ ។

ការវិភាគ និងអនុសាសន៍នៅក្នុងរបាយការណ៍នេះមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់អង្គការយូណេស្កូទេ ។ របាយការណ៍នេះជាការបោះពុម្ពឯករាជមួយអនុញ្ញាតឱ្យបោះពុម្ពដោយអង្គការយូណេស្កូជំនួសមុខឱ្យសហគមន៍អន្តរជាតិ ។ របាយការណ៍នេះជាសមទ្ធិផលនៃកិច្ចប្រឹងប្រែងរួម និងកិច្ចសហការរបស់ក្រុមការងារធ្វើរបាយការណ៍ និងមនុស្សជាច្រើន និងទីភ្នាក់ងារ ស្ថាប័ន និងរដ្ឋាភិបាលជាច្រើនប្រទេស ។ ទស្សនៈ និងមតិដែលបានសំដែងចេញនៅក្នុងរបាយការណ៍នេះជាការទទួលខុសត្រូវទូទៅរបស់នាយកអង្គការយូណេស្កូ ។

**បញ្ហាទាក់ទងនឹងទិន្នន័យ**

ទិន្នន័យត្រឹមត្រូវ ថ្មីទាន់ពេលវេលា និងសមស្របទាំងទិន្នន័យគុណវិស័យ និងបរិវិស័យសុទ្ធតែមានតម្លៃសម្រាប់ប្រើប្រាស់ក្នុងការតាមដានការរីកចម្រើនឈានទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ។ ទិន្នន័យទាំងនេះមានសារៈសំខាន់សម្រាប់តាក់តែងគោលនយោបាយដោយសំអាងលើភស្តុតាងច្បាស់លាស់និងសម្រាប់វាយតម្លៃការអនុវត្តជាក់ស្តែង ។ ទិន្នន័យដែលបានបែងចែកតាមប្រភេទច្បាស់លាស់អាចជួយកំណត់រកកន្លែងដែលមានវិសមភាពធំជាងគេបង្អស់ និងអាចជួយសម្រួលដល់ការធ្វើផែនការ និងវាយតម្លៃទាំងនៅថ្នាក់ជាតិ និងសហគមន៍ ។

របាយការណ៍នេះពឹងផ្អែកច្រើនលើទន្នន័យប្រមូលតាមវិធីរដ្ឋបាលដែលផ្តល់ដោយរដ្ឋាភិបាលរៀងរាល់ឆ្នាំទៅឱ្យវិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូ (UIS) ។ ទិន្នន័យក្នុងឆ្នាំសិក្សា ២០០១/២០០២ ជាទិន្នន័យថ្មីបំផុតទទួលបានពីប្រភពនេះ ។ ទិន្នន័យទាំងនោះស្ថិតនៅក្នុងចង្កោមទិន្នន័យដែលមានគុណភាព ចងក្រងតាមវិធីដែលអាចប្រៀបធៀបស្ថិតិក្នុងចំណោមប្រទេសភាគច្រើន ដោយប្រើវិធីចាត់ចំណាត់ថ្នាក់អប់រំតាមនិយាមស្តង់ដាអន្តរជាតិ (ISCE) ។ ការយឺតយ៉ាវក្នុងការប្រមូលទិន្នន័យរបស់រដ្ឋាភិបាល និងការបញ្ចេញឱ្យប្រើប្រាស់ដោយវិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូសម្រាប់បញ្ចូលក្នុងរបាយការណ៍នេះ និងរបាយការណ៍ផ្សេងទៀត ។

វិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូកំពុងប្រឹងប្រែងប្រមូលទិន្នន័យឱ្យបានលឿនជាងមុនហើយកាត់បន្ថយការយឺតយ៉ាវរយៈពេលពីរឆ្នាំដូចបច្ចុប្បន្ន ។ ការជោគជ័យលើកិច្ចការនេះគឺអាស្រ័យលើរដ្ឋាភិបាលរបស់ប្រទេសទាំងអស់ក្នុងការពង្រឹងសមត្ថភាពប្រមូល និងវិភាគទិន្នន័យ ដោយមានជំនួយពីវិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូ និងភ្នាក់ងារផ្សេងទៀត ។ វិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូកំពុងព្យាយាមបង្កើតកម្មវិធីជំនួយដើម្បីពង្រឹងសមត្ថភាពវិភាគស្ថិតិ ព្រោះ គុណភាពនៃទិន្នន័យដែលយកមកប្រើដើម្បីបោះពុម្ពផ្សាយបង្ហាញអំពីគុណភាពទិន្នន័យពីប្រទេសដែលផ្តល់ឱ្យ ។

គួរកត់សំគាល់ផងដែរថា របាយការណ៍នេះប្រើទិន្នន័យមកពីប្រភពជាច្រើនដូចជា អង្កេតគ្រួសារ និង ការស្រាវជ្រាវជាច្រើនទៀត ។ ហេតុដូច្នេះរបាយការណ៍នេះមានទិន្នន័យជាច្រើនយកមកវិភាគ និងអាចធ្វើផែនទីមួយសម្រាប់បង្ហាញអំពីបំរែបំរួលគោលនយោបាយនៅប្រទេសជាច្រើន និងអំពីភាពជឿនលឿនឈានទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ។

ឯកសារដើមជាភាសាអង់គ្លេស
បោះពុម្ពនៅឆ្នាំ២០០៤ ដោយអង្គការសហប្រជាជាតិ
ទទួលបន្ទុកការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (UNESCO)
7, Place de Fontenoy, 75352 Paris 07 SP
រចនាក្រាហ្វិកដោយ Sylvaine Baeyens
ក្រាហ្វិកដោយ Id-Prod
បោះពុម្ពដោយ Graphoprint, Paris
©UNESCO 2003
បោះពុម្ពនៅប្រទេសបារាំង

របាយការណ៍សកលលោកតាមដានការអប់រំសម្រាប់ទាំងអស់គ្នា
ឆ្នាំ២០០៥ ជាភាសាខ្មែរចែកជូនដោយឥតគិតថ្លៃ

ឯកសារជាភាសាខ្មែរ
បោះពុម្ពនៅឆ្នាំ២០០៥ ដោយការិយាល័យអង្គការយូណេស្កូនៅកម្ពុជា
តាមអាសយដ្ឋានខាងក្រោម :
P.O. BOX 29, អគារលេខ ៣៨ មហាវិថីសម្តេចសុធារស
សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ភ្នំពេញ
ទូរស័ព្ទ : ៨៥៥–២៣៤២៦៧២៦/២១៧២៤៤
ទូរសារ : ៨៥៥–២៣៤២៦១៦៣/២១៧០២២
www.unesco.org www.un.org.kh/unesco

**គ្រប់គ្រងដោយ :**
លោក អេជែន ក្លេម៉ង់
អ្នកតំណាងអង្គការ UNESCO ប្រចាំនៅកម្ពុជា
លោកបណ្ឌិត សម្ភោធសែនភុន ប្រសើរសិរី
អ្នកឯកទេសកម្មវិធីអប់រំ UNESCO
**បកប្រែអត្ថបទជាភាសាខ្មែរដោយ :**
លោក ឈិន និត

**ផ្ទៀងផ្ទាត់ និង សម្រួលអត្ថបទដោយ :**
លោក ខៀវ វិជ្ជានន្ទ
**បោះពុម្ពដោយ :**
រោងពុម្ព ឥន្ទ្រីមាស

ការបកប្រែជាភាសាខ្មែរធ្វើឡើងក្រោមបន្ទុក
របស់ការិយាល័យអង្គការយូណេស្កូនៅភ្នំពេញ ។

# តើពិភពលោកកំពុងឈរនៅកន្លែងណា នៅលើគោលដៅទាំងប្រាំមួយរបស់ការអប់រំសម្រាប់ទាំងអស់គ្នា?

**គោលដៅ ១** **គាំពារ និងអប់រំកុមារតូច :** ដំណើរឈានទៅពង្រីកឱកាសចូលរៀនមានការយឺតយ៉ាវ។ ដោយសារហេតុផលនោះ ទើបកុមារមកពីគ្រួសារក្រីក្រជួបការលំបាកមិនសូវមានឱកាសចូលរៀនក្នុងកម្មវិធីគាំពារ និងអប់រំកុមារតូច។ កុមារតូចម្នាក់នៅអាព្រិចសាប់សាហារាអាចមានឱកាសចូលរៀនក្នុងសាលាមតេយ្យបានតែ ០,៣ ឆ្នាំ ប៉ុណ្ណោះ។ ចំណែកកុមារនៅអាមេរិកឡាទីន និងការីប៊ីនមានឱកាសចូលរៀនបាន ១,៦ ឆ្នាំ ហើយកុមារនៅអាមេរិកខាងជើង និងអ៊ឺរ៉ុបខាងលិច អាចមានឱកាសចូលរៀននៅមតេយ្យសាលាបាន ២,៣ ឆ្នាំ។ នៅប្រទេសកំពុងអភិវឌ្ឍជាច្រើន បុគ្គលិករបស់កម្មវិធីគាំពារ និងអប់រំកុមារតូចមានសមត្ថភាពតិចតួច។

**គោលដៅ ២** **សកលកម្មអប់រំបឋមសិក្សា :** ចំនួនកុមារនៅក្រៅសាលាមានការធ្លាក់ចុះច្រើន គឺធ្លាក់ចុះពី ១០៦,៦ លាននាក់ នៅឆ្នាំ ១៩៩៨ មកត្រឹម ១០៣,៥ លាននាក់នៅឆ្នាំ ២០០១។ ដោយសារពិភពលោកបានឈានទៅសម្រេចគោលដៅនេះក្នុងរយៈពេលប៉ុន្មានទសវត្សរ៍នេះ កុមារជាច្រើនបានចូលសាលា ប៉ុន្តែដំណើរឈានទៅសម្រេចគោលដៅសកលកម្មអប់រំបឋមសិក្សានៅមុន ឬត្រឹមឆ្នាំ ២០១៥ មានការយឺតយ៉ាងណាស់។ បើដំណើរដ៏យឺតនេះនៅតែបន្ត ផលធៀបសិស្សចុះឈ្មោះចូលរៀនពិតនឹងកើនដល់ ៨៥% នៅឆ្នាំ ២០០៥ ហើយ ៨៧%នៅឆ្នាំ ២០១៥។ ក្នុងគោលដៅនេះ ការរៀនចប់បឋមសិក្សាគឺជាបញ្ហាចំបងដែលត្រូវដោះស្រាយជាចាំបាច់ ដូចជា បញ្ហាសិស្សចុះឈ្មោះចូលរៀនក្រោយអាយុស្របច្បាប់ ហើយបញ្ហាសិស្សអាចបន្តរៀនរហូតចប់ថ្នាក់ទី ៥ មានចំនួនតិច (តិចជាង ៧៥% នៅប្រទេស ៣០ ក្នុងចំណោមប្រទេស ៩១ ដែលមានទិន្នន័យប្រើបាន) ហើយសិស្សត្រួតថ្នាក់ក៏ជាបញ្ហាធំដែលត្រូវដោះស្រាយបន្ទាន់ផងដែរ។

**គោលដៅ ៣** **ការអប់រំយុវវ័យ និងមនុស្សចាស់ :** នៅប្រទេសកំពុងអភិវឌ្ឍមួយចំនួនដែលបានវាយតម្លៃលើកកម្មវិធីអភិវឌ្ឍបំណិនជីវិតមិនសូវប្រឹងប្រែងដើម្បីលើកកំពស់សមត្ថភាព និងជំនាញដល់យុវវ័យ និងមនុស្សចាស់ទេ។ ដំណើរឈានទៅសម្រេចគោលដៅនេះនៅទូទាំងពិភពលោកជួបប្រទះនឹងការលំបាកច្រើន ក្នុងការវាយតម្លៃ។

**គោលដៅ ៤** **អក្ខរកម្ម :** នៅឆ្នាំ ២០០២ មានមនុស្សចាស់ប្រមាណ ៨០០ លាននាក់ជា អនក្ខរជន[១] ៧០% រស់នៅប្រទេសចំនួន ៩ នៅអាព្រិចសាហារា និងអាស៊ីខាងកើត និងខាងត្បូង ជាពិសេសឥណ្ឌា ចិន បង់ក្លាដែស និងប៉ាគីស្ថាន។

**គោលដៅ ៥** **យេនឌ័រ :** ទោះជាប្រទេសជាច្រើននៅជុំវិញពិភពលោកបានពុះពារឈានទៅសម្រេចសមភាពយេនឌ័រគិតជាតួលេខនៅបឋមសិក្សា និងមធ្យមសិក្សាក្នុងរយៈពេលជាច្រើនទសវត្សរ៍កន្លងមកនេះក៏ដោយ ក៏គម្លាតយេនឌ័រនៅតែធំដដែល ដូចជានៅប្រទេសអារ៉ាប់ អាហ្វ្រិកសាហារា និងអាស៊ីខាងត្បូង និងខាងលិច។ នៅទូទាំងសកលលោក កាលពីឆ្នាំ ២០០១ មានកុមារីប្រមាណ ៥៧% មិនបានចូលរៀននៅសាលាបឋមសិក្សា ហើយជាង៦០%នៅរដ្ឋអារ៉ាប់ និងអាស៊ី ខាងត្បូង និងខាងលិច។ ការចូលរៀនរបស់សិស្សស្រីមានចំនួនតិចជាងក្មេងប្រុសយ៉ាងច្រើននៅបឋមសិក្សា (សន្ទស្សន៍សមភាពយេនឌ័រគិតជាតួលេខខាងក្រោម ០,៩៧) នៅប្រទេសចំនួន ៧១ ក្នុងចំណោមប្រទេស ១៧៥។ វិសមភាពយេនឌ័រ គិតជាតួលេខកាន់តែរីកធំនៅមធ្យមសិក្សា និងឧត្តមសិក្សា។ ក្នុងចំណោមប្រទេស កំពុងអភិវឌ្ឍចំនួន ៨៣ ដែលមាន ទិន្នន័យអាចយកមកប្រើការបានមានប្រទេស ចំនួនពាក់កណ្តាលបានឈានទៅសម្រេចសមភាពយេនឌ័រគិតជាតួលេខនៅបឋមសិក្សា ហើយប្រទេសតិចជាង ១ ភាគ ៥ បានសម្រេចសមភាពយេនឌ័រគិតជាតួលេខនៅមធ្យមសិក្សា ហើយប្រទេសតែ ៤ ប៉ុណ្ណោះបានសម្រេចសមភាពយេនឌ័រគិតជាតួលេខនៅឧត្តមសិក្សា។ អនក្ខរជនពិភពលោកជិត ២ ភាគ ៣ (៦៤%) ជាស្ត្រី។

**គោលដៅ ៦** **គុណភាព :** ប្រទេសដែលស្ថិតនៅឆ្ងាយពីការសម្រេចគោលដៅ ១ ដល់ ៥ សុទ្ធតែជាប្រទេសដែលពិបាកនឹងសម្រេចគោលដៅទី ៦ ណាស់។ សូចនាករណ៍ជាច្រើនបានចង្អុលបង្ហាញអំពីព័ត៌មានស្តីពីគុណភាព។ ការចំណាយរបស់រដ្ឋលើវិស័យអប់រំបង្ហាញអំពីប្រភាគនៃផលទុនជាតិសរុបនៅប្រទេសអ្នកមានដែលបានសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នារួចហើយខ្ពស់ជាងប្រភាគនៃផលទុនជាតិសរុបរបស់ប្រទេសអ្នកក្រដែលត្រូវការពង្រីក និងកែលំអប្រព័ន្ធអប់រំដែលមានធនធានតិចជាចាំបាច់។ ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ការចំណាយលើវិស័យអប់រំមានការកើនឡើងច្រើន ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ដូចជាប្រទេសនៅអាស៊ីខាងកើត និងប៉ាស៊ីហ្វិក ប្រទេសនៅអាមេរិកឡាទីន និងការីប៊ីន។ ផលធៀបសិស្ស និងគ្រូនៅតែខ្ពស់នៅប្រទេសជាច្រើននៅអាព្រិច សាប់សាហារ៉ា (នៅតាមតំបន់ ៤៤:១) និងនៅអាស៊ីខាងត្បូង និងខាងលិច (៤០:១)។ នៅប្រទេសដែលមានប្រាក់ចំណូលទាប គ្រូបង្រៀនមិនទាន់មានស្តង់ដាជំនាញដើម្បីចូលបង្រៀនទេ ហើយគ្រូភាគច្រើនមិនទាន់យល់ច្បាស់អំពីកម្មវិធីសិក្សាដែលត្រូវបង្រៀនផង។ ការឆ្លងរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍កំពុងមានឥទ្ធិពលលើការផ្តល់ការអប់រំប្រកបដោយគុណភាព និងលើវត្តមានរបស់គ្រូ។ ទិន្នន័យបានពីការធ្វើតេស្តតាមប្រទេស និងជាអន្តរជាតិបង្ហាញថា សិស្សទទួលបានលទ្ធផលខ្សោយច្រើននៅតំបន់កំពុងអភិវឌ្ឍទាបបំផុត។

---

៤. វិទ្យាស្ថានស្ថិតិ UNESCO បានប៉ាន់ស្មានឡើងវិញអំពីចំនួនអនក្ខរជនដោយប្រើទិន្នន័យថ្មីចុងក្រោយ។ អត្រាស្មានបច្ចុប្បន្នប្រហែលតិចជាង ៨៦២ លាននាក់ក្នុងឆ្នាំ ២០០០ ក្នុងរបាយការណ៍សកលលោកតាមដានការអប់រំសម្រាប់ទាំងអស់គ្នា ២០០៣/៤។ ការប្រើទិន្នន័យថ្មីបណ្តាលមកពីកត្តាច្រើនយ៉ាង ដូចជា ទិន្នន័យបានមកពីជំរឿន និងអង្កេតថ្មីរបស់បណ្តាប្រទេសជាច្រើន។ ឧ. ជំរឿនឆ្នាំ ២០០០ របស់ចិនផ្តល់ទិន្នន័យដល់វិទ្យាស្ថានសម្រាប់គណនាចំនួនអនក្ខរជនមនុស្សចាស់នៅប្រទេសនេះ ដែលបានថយចុះជាង ៥០ លាននាក់។

## សន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នា (EDI)

សន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នា (EDI) វាស់អំពីទំហំជោគជ័យរបស់ប្រទេសដែលបានសម្រេចគោលដៅ ៤ ក្នុងចំណោមគោលដៅទាំង ៦ របស់ការអប់រំសម្រាប់ទាំងអស់គ្នាគឺ សកលកម្មអប់រំបឋមសិក្សា សមភាពយេនឌ័រគិតជាគូលេខ អក្ខរកម្ម និងគុណភាព។ ប្រទេសជាច្រើន គិតទាំងប្រទេសក្រីក្របំផុតមួយចំនួនបានសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាក្នុងចន្លោះឆ្នាំ ១៩៩៨ និង ២០០១។ ជោគជ័យនេះបង្ហាញថា ភាពក្រីក្រមិនមែនជាឧបសគ្គដ៏ធំរារាំងដល់ការឈានទៅសម្រេចការអប់រំសម្រាប់ទាំងអស់គ្នាទេ។ ម្យ៉ាងទៀត ការបរាជ័យដ៏ធំក្នុងវិស័យអប់រំបានរីកធំនៅប្រទេសអាហ្វ្រិកសាប់សាហារា រដ្ឋអារ៉ាប់ និងអាស៊ីខាងត្បូង និងខាងលិច។

- ប្រទេសចំនួន ៤១ (១ ភាគ ៣ នៃប្រទេសទាំងនេះមានសន្ទស្សន៍ដែលអាចគណនាបាន) ប្រទេសភាគច្រើននៅអាមេរិកខាងជើង និងអឺរ៉ុបខាងលិច អឺរ៉ុបកណ្តាល និងអឺរ៉ុបខាងកើតបានសម្រេចគោលដៅ ឬជិតឈានទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នាហើយ។

- ប្រទេស៥១ មានតម្លៃសន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នាចន្លោះពី ០,៨០ និង ០,៩៤[២] ពាក់កណ្តាលនៃប្រទេសទាំងនេះ ភាគច្រើននៅអាមេរិកឡាទីន គុណភាពអប់រំស្ថិតនៅឆ្ងាយពីគោលដៅផ្សេងៗទៀត។

- ប្រទេសចំនួន ៣៥ ស្ថិតនៅឆ្ងាយពីការសម្រេចគោលដៅការអប់រំសម្រាប់ទាំងអស់គ្នាដែលមានតម្លៃសន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នាក្រោម ០,៨០។ ប្រទេសចំនួន ២២ នៅអាហ្វ្រិកសាប់សាហារា។ បីប្រទេសទៀតនៅអាស៊ីខាងត្បូងដែលមានប្រជាជនច្រើនគឺ បង់ក្លាដែស ឥណ្ឌា និងប៉ាគីស្ថានក៏ស្ថិតនៅក្នុងក្រុមនេះដែរ។

២. តម្លៃសន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នាអាចមានចន្លោះពី ០ – ១។ កាលណាតម្លៃរឹតជិត ១ មានន័យថា ប្រទេសនោះជិតឈានសម្រេចគោលដៅរបស់ខ្លួន ហើយការអប់រំក៏សម្រេចកាន់តែច្រើនដែរ។

# គុណភាពល្អប្រសើរ :

- **កាតព្វកិច្ចចំពោះមុខ :** ការអប់រំសម្រាប់ទាំងអស់គ្នាមិនទើងមិនអាចសម្រេចបានទេ បើមិនលើកកំពស់គុណភាពឲ្យល្អប្រសើរ។ នៅប្រទេសជាច្រើនលើពិភពលោក គម្លាតរវាងសិស្សដែលបានរៀនចប់ពីសាលា និងអ្នកដែលចប់ហើយមានជំនាញប្រើការបានមានទំហំធំធេងណាស់។ គោលនយោបាយដែលមានបំណងជម្រុញឲ្យមានការចុះឈ្មោះចូលរៀនរហូតដល់ ១០០% ត្រូវតែធានាឲ្យមានលក្ខខណ្ឌសិក្សា និងឱកាសសិក្សាសមរម្យ។ បទពិសោធន៍ល្អៗអំពីលក្ខខណ្ឌនេះអាចយកពីប្រទេសដែលបានអនុវត្ត និងបំពេញកាតព្វកិច្ចទាំងពីរនេះបានជោគជ័យ។

- **កំណត់និយមន័យគុណភាព :** គោលការណ៍ពីរដែលអាចយកមកប្រើដើម្បីកំណត់និយមន័យគុណភាពក្នុងវិស័យអប់រំ។ គោលការណ៍ទីមួយកំណត់និយមន័យអំពីការអភិវឌ្ឍពុទ្ធិរបស់អ្នកសិក្សា ដែលនិយមន័យនេះជាបំណងរបស់ប្រព័ន្ធអប់រំទាំងអស់។ ហេតុដូច្នេះ ជោគជ័យដែលប្រព័ន្ធអប់រំទទួលបានគឺជាសូចនាករណ៍មួយចង្អុលបង្ហាញអំពីគុណភាពរបស់ប្រព័ន្ធអប់រំទាំងនោះ។ គោលការណ៍ទីពីរសង្កត់ធ្ងន់លើតួនាទីរបស់អប់រំក្នុងការលើកកំពស់តម្លៃគុណធម៌ និងឥរិយាបថទទួលខុសត្រូវរបស់ពលរដ្ឋ និងផ្តល់ចំណីអាហារដល់ការអភិវឌ្ឍន៍សមត្ថភាពច្នៃប្រឌិត និងស្មារតីទទួលខុសត្រូវ។ ដើម្បីសម្រេចគោលបំណងនេះនឹងជួបការលំបាកក្នុងការវាយតម្លៃ និងក្នុងការប្រៀបធៀបរវាងប្រទេសមួយទៅប្រទេសមួយ។

- **សារប្រយោជន៍បានពីការអប់រំ :** ការអប់រំល្អប្រសើររួមចំណែកដល់ការបង្កើនប្រាក់ចំណូល និងជួយលើកកំពស់កំណើនសេដ្ឋកិច្ច ហើយជួយឲ្យមនុស្សម្នាក់ៗកាន់តែមានសមត្ថភាពក្នុងការសម្រេចចិត្តឲ្យបានត្រឹមត្រូវ ដូចជា ការសម្រេចចិត្តអំពីការមានកូន និងបញ្ហាសំខាន់ៗទាក់ទងនឹងសុខុមាលភាពផ្ទាល់ខ្លួន។ ឧទាហរណ៍ ការអប់រំល្អនឹងជួយកាត់បន្ថយភាពគ្រោះថ្នាក់ដោយការឆ្លងមេរោគអេដស៍។ ការស្រាវជ្រាវជាច្រើនបង្ហាញថា មានពុទ្ធិ និងជំនាញទទួលបានពីការអប់រំមូលដ្ឋានមានសារប្រយោជន៍បំផុតសម្រាប់យុវវ័យការពារខ្លួនពីការឆ្លងមេរោគអេដស៍។ សារប្រយោជន៍នេះពិតជាមានទំនាក់ទំនងជាមួយកំរិតអប់រំ ដែលមនុស្សម្នាក់ៗបាន រៀន។

- **ឆ្នាំចូលរៀនក្នុងសាលា :** គុណភាពខ្ពស់ក្នុងការអប់រំនឹងជួយឲ្យសិស្សរៀនទៅសាលាកាន់តែយូរ អាយុខ័យចូលរៀនក្នុងសាលាកាន់តែវែងទោះជាឱកាសខុសគ្នាពីតំបន់មួយទៅតំបន់ក៏ដោយ។ គិតជាមធ្យមសម្រាប់ប្រទេសទាំងអស់ សិស្សអាចរៀនបានរយៈពេល ៩.២ ឆ្នាំ រៀននៅបឋមសិក្សា និងមធ្យមសិក្សា។ សិស្សម្នាក់នៅអាព្រិចសាប់សាហារាំពឹងថាបានរៀនពី ៥ ទៅ ៦ ឆ្នាំតិចជាងកុមារនៅតំបន់អឺរ៉ុបខាងលិច និងអាមេរិក។ ប្រជាជនដែលបានចូលរៀននៅសាលាបានយូរច្រើនឆ្នាំ រំពឹងថានឹងរៀននៅសាលាបាន ៥ ឆ្នាំ ដូចកុមារនៅប្រទេសនៅចំណាត់ថ្នាក់បាតតារាង។

## សង្ខេប

■ **ពិន្ទុតេស្ត :** តេស្តអំពីជោគជ័យអន្តរជាតិបង្ហាញថា ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចមានឥទ្ធិពលខ្លាំងលើលទ្ធផលសិក្សានៅសាលា។ ដូច្នេះ ទាំងគោលនយោបាយអប់រំ និងគោលនយោបាយសេដ្ឋកិច្ចត្រូវតែដោះស្រាយបញ្ហាវិសមភាពសេដ្ឋកិច្ច សង្គមកិច្ចក្នុងចំណោមសិស្សានុសិស្សឲ្យបានជាមុនសិន។

■ **ធនធាន :** នៅប្រទេសដែលមានប្រាក់ចំណូលទាប ការបង្កើនការចំណាយសម្រាប់សៀវភៅសិក្សា កាត់បន្ថយចំនួនសិស្សក្នុងថ្នាក់ លើកកំពស់សមត្ថភាពគ្រូ និងបំពាក់បរិក្ខាសាលាឲ្យកាន់តែប្រសើរនឹងជួយដល់ការសម្រេចជោគជ័យរបស់សិស្សក្នុងការរៀនសូត្រ។ ប៉ុន្តែនៅប្រទេសអ្នកមាន ការបង្កើនចំណាយបែបនេះមិនសូវមានទំនាក់ទំនងនឹងលទ្ធផលសិក្សារបស់សិស្សទេ។ ការលើកកំពស់គុណភាពក៏អាចសម្រេចជោគជ័យដោយចំណាយទាបមធ្យមបានដែរ ហើយប្រទេសក្រីក្រក៏អាចមាន សមត្ថភាពធ្វើបានដែរ។ នៅកន្លែងដែលមានអត្រាត្រួតថ្នាក់ខ្ពស់ ការបង្កើនគុណភាពទាមទារនូវការចំណាយហិរញ្ញវត្ថុផ្ទាល់ខ្លួនមួយចំណែក ព្រោះអាចកាត់បន្ថយរយៈពេលរៀនយូរនៅសាលា ដោយសារការរៀនត្រួតថ្នាក់។

■ **ការអប់រំបែបដាក់បញ្ចូលគ្នាគ្រប់ក្រុមមុខសញ្ញាទាំងអស់ :** គ្រប់កំណែទម្រង់ទាំងអស់ដែលមិនពិចារណា យកចិត្តទុកដាក់ និងជ្រះបញ្ចាំងអំពីក្រុមជនក្រីក្រ និងជួបការលំបាកតែងទទួលបរាជ័យ។ វិធីសាស្ត្រអប់រំសម្រាប់អ្នកផ្ទុកមេរោគអេដស៍ ក្រុមដែលត្រូវការជំនួយបន្ទាន់ ជនពិការ និងកុមារពលកម្មត្រូវទទួលបានការគាំទ្រឲ្យ កាន់តែច្រើន។

■ **ការសម្របសម្រួល :** ទំនាក់ទំនងរវាងនាយកដ្ឋាន និងនាយកដ្ឋានទទួលបន្ទុកកម្មវិធីគាំពារ និងអប់រំកុមារតូច អក្ខរកម្ម និងសុខភាព នឹងជួយលើកកំពស់គុណភាព។ លើសនេះទៀត គោលនយោបាយឆ្លើយតបនឹងតម្រូវការយេនឌ័រក្នុងវិស័យអប់រំ និងកំណែទម្រង់ដែលឆ្លើយតបទៅនឹងតម្រូវការយេនឌ័រនៅក្នុងសង្គមក៏ជួយលើកកំពស់គុណភាពអប់រំផងដែរ។

## ខ្លឹមសារនាំមុខអត្ថបទ

■ **សកម្មភាពរៀនឲ្យកាន់តែប្រសើរ :** ភស្តុតាងជាច្រើនផ្តល់ការណែនាំអំពីប្រសិទ្ធភាពរបស់សាលា។ ភស្តុតាងទាំងនោះច្រើនសង្កត់ធ្ងន់លើសកម្មភាពរៀន និងបង្រៀនដ៏សកម្មរបស់សិស្ស និងគ្រូ ដូចជា តើគ្រូ និងសិស្សទំនាក់ទំនងគ្នាយ៉ាងដូចម្តេចនៅក្នុងថ្នាក់រៀន ហើយគ្រូ និងសិស្សប្រើប្រាស់សម្ភាររៀន និងបង្រៀនមានប្រសិទ្ធភាពប៉ុណ្ណា។ គោលនយោបាយសម្រាប់លើកកំពស់សកម្មភាពរៀន និងបង្រៀនឲ្យកាន់តែល្អប្រសើរត្រូវសង្កត់ធ្ងន់លើ :

- **គ្រូបង្រៀន :** ដើម្បីសម្រេចសកលកម្មអប់រំបឋមសិក្សាតែមួយមុខទាមទារឲ្យមានគ្រូបង្រៀនកាន់តែច្រើន និងកាន់តែមានសមត្ថភាព។ ប្រទេសដែលបានសម្រេចលទ្ធផលសិក្សាខ្ពស់ពិតជាបានវិនិយោគច្រើនក្នុងការបណ្តុះបណ្តាលគ្រូ។ ប៉ុន្តែ នៅប្រទេសជាច្រើន ក្នុងប៉ុន្មានពីរទសវត្សរ៍ចុងក្រោយនេះ ប្រាក់ខែគ្រូបានធ្លាក់ចុះបើប្រៀបធៀបនឹងមុខរបរអាជីពផ្សេង ហើយប្រាក់ខែគឺទាបមិនអាចទ្រទ្រង់ជីវភាពឲ្យបានសមរម្យ។ ហេតុដូចនេះ នៅប្រទេសជាច្រើនការបណ្តុះបណ្តាគ្រូត្រូវពិចារណាឡើងវិញ ត្រូវពង្រឹងការបណ្តុះបណ្តាល និងបំប៉នគ្រូនៅតាមសាលា ហើយបន្ថយការបណ្តុះបណ្តាលគ្រូតាមបែបចាស់ រយៈពេលយូរនៅតាមស្ថាប័នបណ្តុះបណ្តាលគ្រូ។
- **រយៈពេលរៀន :** ពេលវេលាបង្រៀនគឺជាកត្តាជួយសម្រេចជោគជ័យក្នុងការសិក្សា ដូចជារយៈពេលបង្រៀនដែលបានព្រមព្រៀងជាទូទៅពី៨៥០-១០០០ម៉ោងក្នុងមួយឆ្នាំ ប្រទេសខ្លះមិនបានផ្តល់គ្រប់ម៉ោងទេ។ ពិន្ទុតេស្តបានបង្ហាញយ៉ាងច្បាស់ថា រយៈពេលរៀន និងបង្រៀននៅក្នុងថ្នាក់មានឥទ្ធិពលដល់ការរៀនមុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងភាសា។
- **មុខវិជ្ជាសំខាន់ៗ :** អក្ខរកម្មជាកត្តាចាំបាច់សម្រាប់រៀនមុខវជ្ជាផ្សេងឲ្យពូកែ ហើយអក្ខរកម្មជាជំនាញចាំបាច់ដើម្បីសម្រេចជោគជ័យលើការរៀនសូត្រយូរអង្វែង។ រៀនអានត្រូវចាត់ទុជាអាទិភាពសម្រាប់លើកកំពស់គុណភាពអប់រំមូលដ្ឋាន ពិសេសសម្រាប់សិស្សមកពីគ្រួសារក្រីក្រជួបការលំបាក។
- **គរុកោសល្យ :** វិធីបង្រៀនជាច្រើនត្រូវបានប្រើជាទូទៅ ប៉ុន្តែមិនសម្រេចបំណង និងតម្រូវចិត្តសិស្សទេ។ វិធីទាំងនោះច្រើនមិនទទន់ភ្លន់ ហើយត្រូវឲ្យសិស្សទន្ទេញចាំមាត់ ហើយធ្វើឲ្យសិស្សអសកម្ម។ អ្នកស្រាវជ្រាវអប់រំជាច្រើននាក់បានស្វែងរកការគាំទ្រឲ្យប្រើវិធីបង្រៀនប្រកបដោយរចនាសម្ព័ន្ធច្បាស់លាស់- ត្រូវមានការណែនាំផ្ទាល់របស់គ្រូ ការណែនាំឲ្យសិស្សអនុវត្ត និងឲ្យសិស្សរៀនដោយខ្លួនឯង ក្នុងបរិយាកាសបង្រៀនសិស្សមេត្រី។
- **ភាសា :** ជំរើសភាសាសម្រាប់បង្រៀនសិស្សនៅសាលាមានសារៈសំខាន់បំផុត។ ការបង្រៀនសិស្សនូវភាសាទីមួយរបស់សិស្សនឹងជួយសិស្សឲ្យរៀនបានល្អប្រសើរនូវមុខវិជ្ជាផ្សេងៗ ហើយជួយកាត់បន្ថយអត្រាត្រួតថ្នាក់ និងបោះបង់ចោលសាលា។
- **សម្ភាររៀន និងបង្រៀន :** គុណភាព និងធនធានរូបវ័ន្តនៃសម្ភាររៀន និងបង្រៀនពិតជាមានឥទ្ធិពលខ្លាំងក្លាលើការបង្រៀនរបស់គ្រូ។ កង្វះសៀវភៅសិស្សកើតឡើងដោយសារប្រព័ន្ធចែកចាយមិនល្អ អនុវត្តខុសគោលការណ៍ និងអំពើពុករលួយ។
- **បរិក្ខាសាលា :** ដើម្បីសម្រេចសកលកម្មអប់រំបឋមសិក្សា ប្រទេសជាច្រើនត្រូវការតុបតែងបន្ទប់រៀនឲ្យល្អ និងសាងសង់បន្ទប់រៀនបន្ថែម។ ទឹកស្អាត អនាម័យ និងឱកាសចូលរៀនសម្រាប់ជនពិការគឺមានសារៈសំខាន់មិនអាចខ្វះបាន។
- **ការដឹកនាំ :** រដ្ឋបាលកណ្តាលរបស់រដ្ឋាភិបាលត្រូវតែប្រុងប្រៀប និងត្រៀមខ្លួនដើម្បីផ្តល់សេរីភាពក្នុងការចូលរៀនរបស់សិស្ស ដូច្នេះត្រូវមានធនធានគ្រប់គ្រាន់ ហើយតួនាទី និងការទទួលខុសត្រូវនៅគ្រប់ថ្នាក់ដឹកនាំទាំងអស់ត្រូវតែច្បាស់លាស់។ គ្រូបង្រៀន និងនាយកសាលាអាចមានឥទ្ធិពលខ្លាំងលើគុណភាពរបស់សាលារៀន។

នៅប្រទេសជាច្រើនដែលកំពុងព្យាយាមធានាផ្តល់សិទ្ធិទទួលការអប់រំដល់កុមារគ្រប់ៗរូប ការយកចិត្តទុកដាក់ខ្លាំងលើការពង្រីកឱកាសចូលរៀនបានរារាំង និងប៉ះពាល់ដល់ការយកចិត្តទុកដាក់លើគុណភាព។ ប៉ុន្តែ គុណភាពគឺជាកត្តាកំណត់ថា តើសិស្សរៀនបានប៉ុន្មាន និងចេះប៉ុន្មាន ហើយគុណភាពក៏កំណត់អំពីសារប្រយោជន៍ដែលសិស្សទទួលបានពីការអប់រំសម្រាប់អភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួន និងអភិវឌ្ឍសង្គម។ គោលដៅទី ៦ របស់ក្របខ័ណ្ឌសកម្មភាពក្រុងដាកាទាមទារលើកកំពស់គុណភាពអប់រំក្នុងគ្រប់ទិដ្ឋភាពទាំងអស់។ ដូចរបាយការណ៍នេះបានលើកឡើងច្បាស់ សិស្សជាច្រើនបានចេញពីសាលាដោយមិនបានទទួលពុទ្ធិ និងជំនាញច្បាស់លាស់ឡើយ។

ក្រោយពីបានវិភាគវែកញែកអំពីគុណភាព របាយការណ៍នេះបានបង្ហាញនូវផែនទីមួយសម្រាប់ជាជំនួយក្នុងការកំណត់និយមន័យ និងស្វែងយល់អំពីបញ្ហាគុណភាព (ជំពូក ១)។ របាយការណ៍នេះក៏បានវិភាគលទ្ធផលស្រាវជ្រាវជាច្រើនទាក់ទងនឹងកត្តាទាំងឡាយដែលមានឥទ្ធិពលលើគុណភាពអប់រំ (ជំពូក ២) ហើយរបាយការណ៍នេះក៏ផ្តល់នូវយុទ្ធសាស្ត្រ និងគោលនយោបាយគន្លឹះៗសម្រាប់លើកកំពស់គុណភាពផងដែរ ជាពិសេសនៅប្រទេសដែលមានប្រាក់ចំណូលទាប (ជំពូក ៤)។ របាយការណ៍ឆ្នាំមុនៗបង្ហាញថា ជំនួយអន្តរជាតិសម្រាប់ការអប់រំមូលដ្ឋាន និងកិច្ចប្រឹងប្រែងដើម្បីពង្រឹងកិច្ចសម្របសម្រួលក៏មានបង្ហាញនៅក្នុងរបាយការណ៍នេះដែរ (ជំពូក ៥)។ ជាទីបញ្ចប់ របាយការណ៍នេះក៏បានតាមដាន និងត្រួតពិនិត្យការរីកចំរើនឈានទៅសម្រេចគោលដៅទាំង ៦ ដែលបានអនុម័តនៅក្រុងដាកា ឆ្នាំ ២០០០ ដែលបានយកចិត្តទុកដាក់ខ្លាំងលើសូចនាករណ៍គុណភាពអប់រំ។ សន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នា (EDI) ដែលបានបង្ហាញនៅក្នុងរបាយការណ៍ឆ្នាំមុនៗក៏មានបង្ហាញបន្ថែមនៅក្នុងរបាយការណ៍ឆ្នាំនេះដែរ ហើយរបាយការណ៍នេះក៏បានសង្ខេបអំពីការជឿនលឿនឈានទៅសម្រេចគោលដៅ ៤ ក្នុងចំណោមគោលដៅទាំង ៦ នៅប្រទេសចំនួន ១២៧ (ជំពូក ៣)។

ជំពូក ១

# ការយល់ដឹងអំពីគុណភាពអប់រំ

- គុណភាពគឺស្ថិតក្នុងបេះដូងរបស់ការអប់រំសំរាប់ទាំងអស់គ្នា
- រកចំណុចរួមមួយ : ការអភិវឌ្ឍពុទ្ធិ បំណិន និងជំនាញច្នៃប្រឌិត
- កំណើនឡើងអំពីការប្រើប្រាស់វិធីសាស្ត្រយកសិទ្ធិមនុស្សជាមូលដ្ឋាន
- មរតកបានពីប្រពៃណីអប់រំ
- សេចក្តីណែនាំអំពីវិសាលភាពទាំង ៥ យ៉ាង


ស្នាមញញឹមក្នុងក្តីសង្ឃឹមជាថ្មីនៅអាហ្វហ្គានីស្ថាន
© Radu Sigheti/REUTERS

ទោះបីជាសិទ្ធិទទួលការអប់រំបានលើកឡើង និងបញ្ជាក់ម្តងហើយម្តងទៀតនៅក្នុងព្រឹត្តិការណ៍ជាច្រើនចាប់តាំងពីសេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្សបានអនុម័តជាផ្លូវការឆ្នាំ ១៩៤៨ ក៏ដោយ ក៏ច្បាប់អន្តរជាតិជាច្រើនទៀតស្ថិតក្នុងសភាពស្ងៀមស្ងាត់មិននិយាយអំពីគុណវិស័យនៃការរៀនសូត្ររបស់សិស្សដែរ។ ក្នុងពេលថ្មីៗនេះ សេចក្តីថ្លែងការណ៍សហស្សវត្សរ៍អង្គការសហប្រជាជាតិដែលបានអនុម័តកាលពីឆ្នាំ ២០០០ បានចែងថា កុមារគ្រប់រូបនឹងមានឱកាស និងសមត្ថភាពរៀនចប់បឋមសិក្សានៅមុន ឬត្រឹមឆ្នាំ ២០១៥ ប៉ុន្តែសេចក្តីថ្លែងការណ៍នោះមិនបាននិយាយអ្វីទាក់ទងនឹងគុណភាពអប់រំទេ។

ការសម្រេចសកលកម្មនៃការចូលរៀនអាស្រ័យទាំងស្រុងលើការធានាឲ្យមានគុណភាពអប់រំ។ **តើសិស្សទទួលបានការបង្រៀនបានល្អឬទេ? តើសិស្សរៀនបានប៉ុន្មាន?** ពិតជាមានឥទ្ធិពលលើការចូលរៀនរបស់សិស្ស ទាំងរយៈពេលរៀន និងទម្លាប់ចូលរៀនរបស់សិស្ស។ មាតាបិតាតែងវាយតម្លៃអំពីគុណភាពសាលារៀននៅពេលមាតាបិតាវិនិយោគធនធានសំរាប់ការអប់រំកូននៅសាលា។ មនុស្សទូទៅនៅលើសកលលោករំពឹងថា ការរៀនសូត្រនៅសាលាពិតជាជួយកុមារឲ្យអភិវឌ្ឍពុទ្ធិ បំណិន និងជំនាញ តម្លៃ សីលធម៌ និងឥរិយាបថសំរាប់យកទៅប្រើក្នុងជីវិតប្រចាំថ្ងៃ ហើយសំរាប់ប្រែក្លាយខ្លួនជាពលរដ្ឋសកម្ម និងទទួលខុសត្រូវ។

សេចក្តីថ្លែងការណ៍សកលលោកស្តីពីការអប់រំសំរាប់ទាំងអស់គ្នា (១៩៩០) និងក្របខ័ណ្ឌសកម្មភាពក្រុងដាកា (២០០០)– សេចក្តីថ្លែងការណ៍ដ៏ថ្មីបំផុតពីរនេះរបស់អង្គការសហប្រជាជាតិយកចិត្តទុកដាក់ខ្លាំងលើការអប់រំ – ទទួលស្គាល់គុណភាពថា ជាលក្ខខណ្ឌទីមួយសំរាប់ធានាសម្រេចការអប់រំសំរាប់ទាំងអស់គ្នា។ ក្របខ័ណ្ឌសកម្មភាពក្រុងដាកាប្រកាសថា គុណភាពគឺជា "បេះដូងរបស់អប់រំ"។ គោលដៅទី ២ សន្យាឲ្យប្រទេសទាំងអស់ផ្តល់ការអប់រំបឋមសិក្សា "ប្រកបដោយគុណភាពល្អ"។ គោលដៅទី ៦ សង្កត់ធ្ងន់អំពីការប្តេជ្ញាក្នុងការលើកកំពស់គុណភាពអប់រំក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ហើយធានាឲ្យមានឧត្តមភាពសំរាប់ទាំងអស់គ្នា។ ដូច្នេះ លទ្ធផលចុងក្រោយគឺគ្រប់គ្នានឹងទទួលបានលទ្ធផល និងផលប្រយោជន៍ពីការសិក្សាទាំងអស់គ្នា តាមរយៈជំនាញអក្ខរកម្ម លេខនព្វន្ត ជំនាញ និងបំណិនជីវិត។

## ការស្រាវជ្រាវរកគោលការណ៍រួម

ថ្វីបើសារៈសំខាន់នៃគុណភាពត្រូវបានទទួលស្គាល់កាន់តែច្រើនឡើងក៏ដោយ ក៏អត្ថន័យនៃគុណភាពមិនទាន់បានឯកភាពគ្នាជារួមក្នុងការអនុវត្តជាក់ស្តែងដែរ។ ក្នុងន័យនេះ មានគោលការណ៍ពីរដែលអាចយកមកប្រើដើម្បីកំណត់និយមន័យរបស់គុណភាពអប់រំ។ គោលការណ៍ទី ១ កំណត់អំពីការអភិវឌ្ឍពុទ្ធិរបស់អ្នកសិក្សាដែលជាគោលដៅចំបងរបស់ប្រព័ន្ធអប់រំ។ គោលការណ៍ទី ១ ចាត់ទុកថា បើសម្រេចគោលដៅនេះគឺសម្រេចសូចនាករណ៍មួយរបស់គុណភាព។ គោលការណ៍ទី២ សង្កត់ធ្ងន់លើតួនាទីរបស់អប់រំក្នុងការលើកកំពស់តម្លៃ និងអភិវឌ្ឍជំនាញច្នៃប្រឌិតដែលពិបាកវាយតម្លៃលើលទ្ធផលចុងក្រោយ។

**ច្បាប់សិទ្ធិមនុស្សឆ្លុះបញ្ចាំងអំពីជំនឿដែលថា កុមារគ្រប់រូបអាចអភិវឌ្ឍពុទ្ធិ និងជំនាញឲ្យតែស្ថិតក្នុងបរិយាកាសរៀនសូត្រត្រឹមត្រូវ**

ចំណុចរួមមួយបានរកឃើញនៅក្នុងគោលដៅដែលមានបំណងពិភាក្សាអំពីគុណភាព។ ការគោរពសិទ្ធិរបស់បុគ្គលម្នាក់ៗ ពង្រីកឱកាសចូលរៀន និងលទ្ធផលសិក្សារបស់សិស្សឲ្យមានសមធម៌ និងកែប្រែខ្លឹមសារអប់រំឲ្យស្របតាមតម្រូវការជាក់ស្តែងក្នុងជីវភាពរស់នៅរបស់សិស្ស។ ច្បាប់សិទ្ធិមនុស្ស (អានប្រអប់ខាងក្រោម) និយាយសង្កត់ធ្ងន់អំពីឱកាសទទួលការអប់រំ និងសមភាពនៃលទ្ធផលរៀនសូត្ររបស់សិស្ស។ ប្រអប់នេះឆ្លុះបញ្ចាំង និងវិភាគអំពីជំនឿមួយដែលថា កុមារទាំងអស់អាចអភិវឌ្ឍពុទ្ធិ និងជំនាញមូលដ្ឋាន ឲ្យតែស្ថិតក្នុងបរិយាកាសរៀនសូត្រត្រឹមត្រូវ និងជំនឿមួយទៀតដែលថា បើសិស្សណាមិនបានអភិវឌ្ឍពុទ្ធិ និងជំនាញមូលដ្ឋាន នោះមានន័យថា ផ្នែកណាមួយនៃប្រព័ន្ធអប់រំពិតជាទន់ខ្សោយ។ ការវិភាគបង្ហាញថា ភាពក្រីក្រ ការរស់នៅតាមតំបន់ជនបទ និងការរើសអើងយេនឌ័រនៅតែជាឧបសគ្គរារាំងដល់ការចូលរៀន និងលទ្ធផលសិក្សារបស់សិស្ស ហើយបង្ហាញទៀតថា គុណភាពបង្រៀនអន់ខ្សោយក៏ជាប្រភពបង្កឲ្យមានវិសមភាពផងដែរ។

## ច្បាប់អន្តរជាតិស្តីពីគុណភាព

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងសិទ្ធិវប្បធម៌ក៏មានបំណងឆ្លើយតបនឹងគោលការណ៍សមធម៌ ដោយលើកឡើងច្បាស់អំពីការទទួលខុសត្រូវរបស់រដ្ឋាភិបាលដើម្បីធានាថា កុមារគ្រប់រូបមានឱកាសទទួលការអប់រំប្រកបដោយគុណភាព។ នៅប្រទេសប្រេស៊ីល កូស្តារីកា និងភីលីពីន បញ្ញត្តិក្នុងរដ្ឋធម្មនុញ្ញធានាថា ថវិកាមួយភាគរយត្រូវទំលាក់ឲ្យវិស័យអប់រំ ជាការឆ្លើយតបនឹងតម្រូវការរបស់កតិកាសញ្ញានេះ។

អនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៩០) ក្នុងមាត្រា ២៩ បានចែងយ៉ាងច្បាស់អំពីកិច្ចសន្យាទាក់ទងនឹងគោលដៅអប់រំ ដែលក្នុងនោះនិយាយសង្កត់ធ្ងន់អំពីខ្លឹមសារ និងគុណភាពអប់រំ។ មាត្រានេះក៏បញ្ជាក់បន្ថែមទៀតថា ការអប់រំគួរអនុញ្ញាតឲ្យកុមារទាំងអស់មានសមត្ថភាពសម្រេចសក្តានុភាពរបស់ខ្លួនក្នុងការអភិវឌ្ឍពុទ្ធិ តម្លៃ សីលធម៌ បំណិន និងជំនាញច្នៃប្រឌិត។

ក្នុងពេលថ្មីៗនេះ សកលភាវូបនីយកម្មបានជួយដឹកនាំរដ្ឋាភិបាលជាច្រើនឲ្យវិភាគ និងស្វែងយល់អំពីជំនាញ និងបំណិនដែលពលរដ្ឋត្រូវការដើម្បីអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។

## ប្រវត្តិសាស្ត្រ

វិធីជាច្រើនទាក់ទងនឹងគុណភាពមានប្រវត្តិខុសៗគ្នា។ ដូចទស្សនៈវិទូ Locke and Rousseau បានរកឃើញថា គុណភាពជាប្រពៃណីរបស់មនុស្សជាតិ ហើយចាត់ទុកធម្មជាតិរបស់មនុស្សជាកត្តាល្អលើសគេ។ ទស្សនៈនេះមានន័យថា មនុស្សទាំងអស់កើតមកគឺស្មើគ្នាទាំងអស់ វិសមភាពបានកើតឡើងដោយសារផលិតផលរបស់ស្ថានភាពមិនល្អ ហើយមានន័យទៀតថា មនុស្សគ្រប់រូបមានតួនាទីដឹកនាំមួយក្នុងការកំណត់និយមន័យនៃកំណើតសមភាពនិងវិសមភាពនេះ។ គោលការណ៍នេះជ្រួតជ្រាបដល់ផ្នត់គំនិតរបស់អ្នកអប់រំជាច្រើនអ្នក។ ជាពិសេស James Dewey និង Jean Piaget មានឥទ្ធិពលក្នុងការស្វែងរកការគាំទ្រអំពីតួនាទីរបស់កុមារក្នុងវិធីសាស្ត្ររៀនបែបសកម្ម និងបែបចូលរួម ហើយបញ្ជាក់អំពីវិធីនានាដែលសិស្សអាចរៀនដើម្បីបង្កើតអត្ថន័យ និងស្វែងយល់ដោយខ្លួនឯង។

ទ្រឹស្តីឥរិយានិយមបានដឹកនាំអ្នកអប់រំនិយមឲ្យដើរបញ្ច្រាស់ទិស។ ទ្រឹស្តីនោះមានឥទ្ធិពលខ្លាំងលើកំណែទម្រង់អប់រំក្នុងពាក់កណ្តាលសតវត្សរ៍ទី២១។ គោលការណ៍ចំបងគឺថា ឥរិយាបថរបស់មនុស្សអាចកែប្រែបាន អាចទស្សន៍ទាយបាន និងអាចគ្រប់គ្រងបានតាមរយៈការផ្តល់រង្វាន់ និងចម្លើយតប (ឧ. តេស្ត និងការប្រលង)។ ទោះជាអ្នកអប់រំមួយចំនួនទទួលស្គាល់នូវទ្រឹស្តីរបស់អ្នកឥរិយាបថនិយមក៏ដោយ ក៏ការអនុវត្តជាក់ស្តែងបានធ្វើឡើងនៅប្រទេសជាច្រើនក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូក្នុងកម្មវិធីសិក្សា និងការបង្រៀនជាក់ស្តែងរបស់គ្រូក្នុងថ្នាក់រៀន។

រយៈពេលជិតមួយភាគបួននៃសតវត្សរ៍ទី ២១ គេឃើញមានការទិតៀនលើទ្រឹស្តីទាំងពីរ។ សង្គមវិទូធ្វើការនៅតាមសាលាមួយចំនួនចាត់ទុក ការអប់រំជាយន្តការគន្លឹះធានាឲ្យមានវិសមភាពក្នុងសង្គម។ សង្គមវិទូទាំងនោះបានចោទជាសំណួរថា តើការរីកដុះដាលនៃការរៀនសូត្រតាមសាលាកាន់តែច្រើន និងកាន់តែទូទៅជាសកល នឹងជួយធានាឲ្យមានការអភិវឌ្ឍសក្តានុភាពរបស់អ្នករៀនប្រកបដោយសមភាពដែរឬទេ? អ្នកទាំងនោះតែងចាត់ទុកការអប់រំល្អជាសក្តានុភាពដើម្បីធានាឲ្យមានការកែប្រែសង្គម។

កិច្ចខិតខំប្រឹងប្រែងដើម្បីបណ្តុះគំនិតអំពីតួនាទីរបស់ការអប់រំកើតចេញពីការពិតដែលបានកើតឡើងក្នុងប្រទេសដែលមានប្រាក់ចំណូលទាប ព្រោះការអប់រំជាកេរដំណែលសល់ពីអាណានិគម។ អ្នកប្រឆាំងនឹងគំនិតបែបនេះមាន Ghandhi ហើយក្រោយមកទៀតគឺ Nyerere នៅសាធារណៈរដ្ឋសហព័ន្ធតាន់ហ្សាន់ញ៉ា។ អ្នកទាំងពីរដាក់សំណើរថា ប្រព័ន្ធអប់រំគួរ តាមលក្ខណៈវប្បធម៌ យកចិត្តទុកដាក់លើភាពស្វ័យម្ចាស់ការ សមធម៌ និងការងារតាមជនបទ។

គំនិតទាំងនេះមាននៅក្នុងការអប់រំមនុស្សចាស់។ អ្នកនិពន្ធមួយចំនួនចាត់ទុកបទពិសោធន៍របស់មនុស្សចាស់ជាប្រភពសំរាប់ការរៀនសូត្រ។ អ្នកនិពន្ធខ្លះទៀតចាត់ទុកការអនុវត្តការអប់រំមនុស្សចាស់ជាទិសដៅឈានទៅកែប្រែស្ថានភាពសង្គម វប្បធម៌ នយោបាយ និងប្រវត្តិសាស្ត្រ។

## ធ្វើផែនទីគុណភាព

តើគុណភាពអាចសិក្សាបានយ៉ាងដូចម្តេចតាមវិធី និងទ្រឹស្តីផ្សេងៗគ្នាខាងលើ? វិធីមួយគឺត្រូវវិលត្រលប់ទៅរកទ្រឹស្តីមូលដ្ឋានសិន : គោលបំណងនៃការអភិវឌ្ឍពុទ្ធិ និងតម្លៃគុណធម៌ ឥរិយាបថ និងបំណិនគឺជាគោលដៅចំបងរបស់ប្រព័ន្ធអប់រំ។ ការសិក្សាស្វែងយល់លំអិតអំពីប្រព័ន្ធអប់រំ និងស្វែងយល់ថាតើប្រព័ន្ធអប់រំអាចផ្តល់ផែនទីដ៏មានប្រយោជន៍មួយដើម្បីស្វែងយល់ តាមដាន និងលើកកំពស់គុណភាពដោយរបៀបណា?

ក្របខ័ណ្ឌនេះ (អានក្រាហ្វ ១.១) ពិចារណាលើចំណុចសំខាន់ប្រាំ ដែលមានឥទ្ធិពលលើគុណភាព។ ក្របខ័ណ្ឌនេះជាចក្ខុវិស័យលំអិតមួយ និយាយ លំអិតអំពីឱកាសចូលរៀន សកម្មភាពរៀន និងបង្រៀន និង លទ្ធផលសិក្សារបស់សិស្ស។

## ក្រាហ្វ ១.១ ក្របខ័ណ្ឌសកម្មភាពមួយសម្រាប់ស្វែងយល់អំពីគុណភាពអប់រំ

**ស្ថានភាពរបស់អ្នករៀន**
- សម្បទា
- សេចក្តីព្យាយាម
- ត្រៀមលក្ខណៈ ចូលរៀនជាស្រេច
- ចំណេះដឹងរៀនពីសង្គម
- ឧបសគ្គក្នុងការរៀនសូត្រ

**ធនធានសម្រាប់អនុវត្ត**

**បង្រៀន និងរៀន**
- ពេលវេលារៀន
- វិធីសាស្ត្របង្រៀន
- វង្វាយតម្លៃ យោបល់កែលំអ វង្វាន់
- ចំនួនសិស្សក្នុងថ្នាក់

- សម្ភាររៀន និងបង្រៀន
- ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខាសាលា
- ធនធានមនុស្ស : គ្រូបង្រៀន នាយក អធិការ អ្នកគ្រប់គ្រង អ្នករដ្ឋបាល
- អភិបាលកិច្ចសាលា

**លទ្ធផលរំពឹងទទួលបាន**
- អក្ខរកម្ម លេខនព្វន្ត បំណិនជីវិត
- ជំនាញច្នៃប្រឌិត និងអារម្មណ៍
- តម្លៃគុណធម៌
- ផលប្រយោជន៍សម្រាប់សង្គម

**បរិបទទូទៅ**
- លក្ខខណ្ឌសេដ្ឋកិច្ច និងទីផ្សារការងារ នៅតាមសហគមន៍
- កត្តាសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងសាសនា
- (យុទ្ធសាស្ត្រជំនួយ)
- ពុទ្ធិអប់រំ និងហេដ្ឋារចនាសម្ព័ន្ធជំនួយគាំទ្រ
- ធនធានរបស់រដ្ឋសម្រាប់ការអប់រំ
- ការប្រកួតប្រជែងក្នុងវិជ្ជាជីវៈ គ្រូបង្រៀននៅក្នុងផ្សារការងារ
- អភិបាលកិច្ចជាតិ និងយុទ្ធសាស្ត្រគ្រប់គ្រង
- ទស្សនៈវិជ្ជារបស់គ្រូបង្រៀន និងសិស្ស
- កត្តាមិត្តភក្តិ
- ការគាំទ្ររបស់មាតាបិតា
- ពេលវេលាសម្រាប់ទៅសាលា និងធ្វើកិច្ចការផ្ទះ
- និយាមស្តង់ដារជាតិ
- លទ្ធផលដែលគ្រប់គ្នារំពឹងទទួលបាន
- តម្រូវការរបស់ទីផ្សារការងារ
- សកលភាវូបនីយកម្ម

*ស្ថានភាពរបស់អ្នករៀន* : អ្នករៀនមិនមកថ្នាក់រៀនក្នុងស្ថានភាពសង្គម និងសេដ្ឋកិច្ចដូចគ្នាទេ។ ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច យេនឌ័រ ពិការភាព ជាតិសាសន៍ ជនជាតិភាគតិច មេរោគអេដស៍/ជំងឺអេដស៍ និងស្ថានភាពត្រូវការជំនួយបន្ទាន់ ដូចជាក្នុងស្ថានភាពជម្លោះ និងគ្រោះធម្មជាតិសុទ្ធតែរួមចំណែកបង្កើតវិសមភាព ដែលទាំងនេះជាកត្តាសម្រាប់យកមកពិចារណាដើម្បីលើកកំពស់គុណភាព។ ផលប្រយោជន៍ដែលសិស្សទទួលបានពីឱកាសរៀនសូត្រក្នុងកម្មវិធីគាំពារ និងអប់រំកុមារតូចក៏មានតួនាទីសំខាន់នៅក្នុងក្របខ័ណ្ឌគុណភាពផងដែរ។

**អ្នករៀនមិនមកថ្នាក់រៀនក្នុងស្ថានភាពសង្គម និងសេដ្ឋកិច្ចដូចគ្នាទេ**

*បរិបទទូទៅ* : ការអប់រំច្រើនឆ្លុះបញ្ចាំងអំពីតម្លៃ និងឥរិយាបថសង្គម។ ស្ថានភាពទូទៅរបស់អប់រំគិតរួមទាំងស្ថានភាពសង្គម និងគោលនយោបាយទាក់ទងនឹងគោលដៅនិយាមស្តង់ដា កម្មវិធីសិក្សា និងគ្រូបង្រៀនសុទ្ធតែមានឥទ្ធិពលលើគុណភាព។

*ធនធានសម្រាប់អនុវត្ត* : ធនធាននេះគិតទាំងធនធានសម្ភារ (សៀវភៅសិស្ស សម្ភាររៀន ថ្នាក់រៀន បណ្ណាល័យ បរិក្ខាសាលា) និងធនធានមនុស្ស (អ្នកគ្រប់គ្រង អធិការ សំខាន់ជាងគេបំផុតគឺ គ្រូបង្រៀន)។ ទាំងអស់នេះជាសូចនាករណ៍និយមប្រើជាងគេសំរាប់ចង្អុលបង្ហាញអំពីអត្រាផលធៀបសិស្ស-គ្រូ ប្រាក់ខែគ្រូ ចំណែកចិការបស់រដ្ឋចំណាយលើការអប់រំសំរាប់កុមារមួយនាក់ប្រៀបធៀបនឹងការចំណាយរបស់អប់រំជាមួយផលិតផលសរុបក្នុងស្រុក។

*បង្រៀន និងរៀន* : ជាសកម្មភាពកើតមានជាក់ស្តែងក្នុងថ្នាក់ និងក្នុងសាលារៀន។ សកម្មភាពគរុកោសល្យបិតក្នុងសកម្មភាពរៀនប្រចាំថ្ងៃរបស់សិស្ស។ សូចនាករណ៍ក្នុងសកម្មភាពបង្រៀន និងរៀនរួមមាន ពេលវេលាចំណាយក្នុងការរៀនសូត្រ ការប្រើវិធីសាស្ត្របង្រៀនបែបសកម្ម និងបែបចូលរួម ហើយសកម្មភាពរៀន និងបង្រៀនជាទូទៅត្រូវវាយតម្លៃតាមការអនុវត្តជាក់ស្តែង។ សុវត្ថិភាពក្នុងសាលា ការចូលរួមក្នុងសកម្មភាពសហគមន៍ លទ្ធផលរំពឹងទទួលបាន និងការដឹកនាំសុទ្ធតែមានឥទ្ធិពលផ្ទាល់ទៅលើសកម្មភាពបង្រៀន និងរៀនរបស់សិស្ស។

*លទ្ធផលរំពឹងទទួលបាន* : និយាយអំពីការសម្រេចបានជោគជ័យក្នុងសកម្មភាពសិក្សា (លទ្ធផលប្រលង) ប៉ុន្តែលទ្ធផលនេះក៏រំពឹងថានឹងទទួលបានប្រយោជន៍សេដ្ឋកិច្ច និងសង្គមកិច្ចអប់រំផងដែរ។

របាយការណ៍នេះវិភាគ និងធ្វើសំយោគលទ្ធផលនៃការស្រាវជ្រាវជាច្រើនទាក់ទងនឹងផលប្រយោជន៍ទទួលបានពីការអប់រំប្រកបដោយគុណភាពល្អ (ជំពូក ២) កំណត់រកយុទ្ធសាស្ត្រល្អៗសម្រាប់លើកកំពស់គុណភាព ពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍ (ជំពូក ៤) ហើយក៏តាមដានជំនួយអន្តរជាតិសម្រាប់លើកកំពស់គុណភាពផងដែរ (ជំពូក៥)។ ដូចរបាយការណ៍មុនៗដែរ របាយការណ៍ឆ្នាំ ២០០៥ វាយតម្លៃអំពីភាពជឿនលឿនឈានទៅសម្រេចគោលដៅទាំង ៦ របស់ការអប់រំសម្រាប់ទាំងអស់គ្នា។ របាយការណ៍ឆ្នាំនេះយកចិត្តទុកដាក់លើសូចនាករណ៍គុណភាពតាមគោលដៅនីមួយៗរបស់ការអប់រំសម្រាប់ទាំងអស់គ្នា (ជំពូក៣)។



© L. FRANEY/RAPHO

ជំពូក ២

រៀនជាមួយគ្នា រស់នៅជាមួយគ្នា : ទីធ្លាសាលារៀនមួយនៅប្រទេសសេណេហ្គាល

# សារប្រយោជន៍នៃគុណភាពល្អ : តើការស្រាវជ្រាវប្រាប់យើងអ្វីខ្លះ?

- ប្រាក់ចំណូលកើនឡើង
- ការការពារបានប្រសើរឡើងប្រឆាំងនឹង HIV/AIDS
- យល់ដឹងច្បាស់លាស់បានមកពីសមិទ្ធិកម្ម
- យកចិត្តទុកដាក់ពិសេសទៅលើគំរូនៃការអប់រំ
- ការស្រាវជ្រាវពីប្រសិទ្ធភាពសាលារៀន : ខាងក្នុងដំណើរការអប់រំ
- ទំនាក់ទំនងរវាងធនធានសាលា និងការខិតខំប្រឹងប្រែង
- មេរៀនជាបទពិសោធន៍ពី ១១ ប្រទេស
- ការសិក្សាប្រកបដោយគុណភាពសម្រាប់កុមារមុនចូលរៀននៅសាលា និងមនុស្សចាស់

**តើ**ការអប់រំល្អប្រសើរធ្វើឲ្យលទ្ធផលអភិវឌ្ឍន៍មានភាពខុសគ្នាឬទេ? ប្រសិនបើមានភាពខុសប្លែកមែន តើការអប់រំដ៏ល្អប្រសើរនេះអាចធ្វើឲ្យសម្រេចទៅបានដូចម្តេច ជាពិសេសនៅប្រទេសកំពុងអភិវឌ្ឍ? ការយល់ដឹងអំពីកត្តាកំណត់គុណភាពនៃការអប់រំគឺជាលក្ខខណ្ឌដំបូងមួយសម្រាប់រៀបចំគោលនយោបាយធានាផ្តល់ការអប់រំប្រកបដោយគុណភាព។ រយៈពេល២០ឆ្នាំកន្លងទៅនេះ ស្ថាប័នស្រាវជ្រាវដ៏ធំមួយត្រូវបានបង្កើតឡើងដើម្បីស្រាវជ្រាវលើបញ្ហាទាំងនេះដោយស្វែងយល់អំពីវិធីសាស្ត្រគំរូ និងវិធានការផ្សេងៗសម្រាប់វាយតម្លៃគុណភាព។

## ប្រាក់ចំណូលខ្ពស់ជាងមុន ជំរើសដោយផ្អែកលើព័ត៌មានគ្រប់គ្រាន់

ការលើកកំពស់គុណភាពអប់រំនឹងជួយសម្រេចនូវគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចដែលមានភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់។ បើចាត់ទុកពិន្ទុតេស្តស្តង់ដាជាខ្នាតតំណាងសម្រាប់គុណភាពនៃជំនាញវិភាគ ការស្រាវជ្រាវបង្ហាញឲ្យឃើញពីឥទ្ធិពលនៃការរៀនពូកែនៅក្នុងសាលាទៅលើប្រាក់ចំណូលប្រចាំជីវិត។ ការស្រាវជ្រាវទាំងឡាយក៏បានយកចិត្តទុកដាក់លើទំនាក់ទំនងរវាងកំណើនធនធានមនុស្ស និងសេដ្ឋកិច្ចក្នុងប្រទេស។ បច្ចុប្បន្ន តេស្តសមិទ្ធិកម្មអន្តរជាតិអាចយកទៅបញ្ចូលក្នុងវិធានការនៃគុណភាពល្អរបស់សាលា និងវិភាគទាំងឡាយ។

ពិន្ទុគណិតវិទ្យា និងវិទ្យាសាស្ត្រគឺជាសូចនាករណ៍មួយនៃផលិតភាពកម្លាំងពលកម្មរបស់ប្រទេសនៅពេលអនាគត។ ការនេះបង្ហាញឲ្យឃើញពីទំនាក់ទំនងរឹងមាំរវាងការកាត់បន្ថយភាពក្រីក្រ និងប្រជាពលរដ្ឋដែលមានការអប់រំ។

គុណភាពនៃការអប់រំក៏មានឥទ្ធិពលជ្រាលជ្រៅទៅលើទង្វើ និងអាកប្បកិរិយាផងដែរ។ ការស្រាវជ្រាវមួយនាពេលថ្មីៗក្នុងប្រទេស ៦ នៅអាព្រិច ដែលមានអត្រាឆ្លងរាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ខ្ពស់បានបង្ហាញថា ប្រជាពលរដ្ឋត្រូវការជំនាញនានាដែលចាំបាច់សម្រាប់កាត់បន្ថយអាកប្បកិរិយារួមភេទគ្មានសុវត្ថិភាពតាមរយៈបណ្តាញការងារផ្តល់ព័ត៌មានផ្លូវការ និងមិនផ្លូវការដោយរួមបញ្ចូលទាំងប្រព័ន្ធអប់រំ។ ជំនាញគិត និងវិភាគដែលតម្រូវឲ្យសិស្សជ្រើសរើសដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងកម្រិតនៃការអប់រំ និងអក្ខរកម្ម ឧទាហរណ៍ ការប្រើប្រាស់ស្រោមអនាម័យមានការកើនឡើងយ៉ាងខ្ពស់ក្នុងចំណោមក្រុមមនុស្សដែលទទួលបានការអប់រំច្រើននៅសាលា។ ការទទួលបានជំនាញគិតពីការអប់រំមូលដ្ឋានបានក្លាយជាកត្តាដ៏សំខាន់បំផុតសម្រាប់ការពារក្មេងជំទង់ និងយុវវ័យពីការចម្លងមេរោគដោយចាត់ទុកការអប់រំជា "ថ្នាំបង្ការរោគសង្គម"។ ក្រាហ្វ ២.១ បង្ហាញថា អត្រាឆ្លងរាលដាលនៃ HIV/AIDS ទៅតាមកម្រិតនៃការអប់រំក្នុងតំបន់ជនបទនៃប្រទេសអ៊ូហ្គាន់ដា ជាដំបូងមានចំនួនប្រហាក់ប្រហែលគ្នា ប៉ុន្តែមួយរយៈពេល ក្រោយមកប្រជាពលរដ្ឋដែលមានការអប់រំច្រើនមានអត្រាឆ្លងទាបជាងប្រជាជនដែលមានការអប់រំតិចតួចនៅសាលា។ ភស្តុតាងនេះគឺជាការឆ្លុះបញ្ចាំងពីស្ថានភាពឆ្លងរាលដាល HIV/AIDS ក្នុងប្រទេសផ្សេងទៀតនៅអាព្រិច។

**ក្រាហ្វ ២.១ : អត្រាប្រេវ៉ាឡង់អេដស៍នៅតាមតំបន់ជនបទ អ៊ូហ្គាន់ដា តាមប្រភេទអប់រំឆ្នាំ ១៩៩០–២០០១ (ចាប់ពីអាយុ ១៨–២៩ឆ្នាំ)**




កំណត់សំគាល់ : អានជំពូក ២ របាយការណ៍អប់រំសម្រាប់ទាំងអស់គ្នា

## ការពិនិត្យពិន្ទុតេស្តអានអក្សរ

ពិន្ទុតេស្តគឺជាខ្នាតវាស់ដ៏មានតម្លៃដើម្បីបញ្ជាក់ថា តើសិស្សរៀនពីកម្មវិធីសិក្សាបានកម្រិតណា ពិន្ទុនោះជួយបង្ហាញថា តើសិស្សរៀនបានល្អកម្រិតណានៅពេលប្រលងបញ្ចប់ចេញពីសាលា។ ពិន្ទុតេស្តក៏អាចប្រើប្រាស់ជាមូលដ្ឋានសម្រាប់ប៉ាន់ស្មានអំពីទំនាក់ទំនងរវាងគុណភាពអប់រំ ការរីកចម្រើនសេដ្ឋកិច្ច និងប្រាក់ចំណូលរបស់បុគ្គលម្នាក់ៗ។ បើទោះបីជាពិន្ទុទាំងនោះអាចប្រើជាម៉ែត្រសម្រាប់វាស់គុណភាពនៃការអប់រំក៏ពិតមែន តែមិនអាចប្រើប្រាស់សម្រាប់វាស់វែងឲ្យបានច្បាស់លាស់អំពីគុណភាពផ្សេងៗ ដូចជាភាពស្មោះត្រង់ ភាពដែលអាចទុកចិត្តបាន ការប្តេជ្ញាចិត្ត និងគុណភាពនៃការដឹកនាំ ដែលមានឥទ្ធិពលយ៉ាងខ្លាំងទៅលើភាពជោគជ័យនៃទីផ្សារពលកម្មបានឡើយ។

### តេស្តសំខាន់ៗ

ការធ្វើតេស្តជាអន្តរជាតិបានអនុវត្តចាប់តាំងពីទសវត្សរ៍ ១៩៥០ គឺនៅពេលដែលសមាគមអន្តរជាតិសម្រាប់វាយតម្លៃសមិទ្ធិកម្មនៃការអប់រំ (IEA) ត្រូវបានបង្កើត។ សមាគម នេះបានចាប់ផ្តើមធ្វើការងារជាដំបូង ដោយពិនិត្យលើអ្វីដែលអាចបញ្ចូលទៅក្នុងការស្រាវជ្រាវក្នុងគោលបំណងធ្វើការប្រៀបធៀបសមិទ្ធិកម្មនៃការគិតនៅតាមកម្រិតផ្សេងៗនៃការសិក្សានៅសាលារបស់សិស្សក្នុងប្រទេសមួយចំនួន និងដើម្បីកំណត់អំពីមូលហេតុចំបងនៃភាពខុសគ្នា។ ដល់ឆ្នាំ ២០០០ ប្រទេសប្រមាណ ៥០ បានចូលរួមក្នុងការស្រាវជ្រាវដែលយកចិត្តទុកដាក់ទៅលើគណិតវិទ្យា និងវិទ្យាសាស្ត្រ (TIMSS) ការអាន (PIRLS) និងមុខវិជ្ជាផ្សេងៗទៀត។ ការស្រាវជ្រាវជាអន្តរជាតិផ្សេងៗទៀតរួមមាន កម្មវិធីវាយតម្លៃសិស្សជាអន្តរជាតិ (PISA) ដែលបានបង្កើតឡើងដោយអង្គការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហប្រតិបត្តិការ (OECD) នៅឆ្នាំ ១៩៩៨ ហើយនៅពេលនេះ កម្មវិធីនោះបានអនុវត្តក្នុងប្រទេសឧស្សាហកម្មជឿនលឿន និងប្រទេសដែលមានប្រាក់ចំណូលមធ្យមចំនួន៥៩ សមាគមអាព្រិចខាងត្បូង និងខាងកើតសម្រាប់ត្រួតពិនិត្យគុណភាពអប់រំ (SACMEQ) ចំនួន ១៥ ប្រទេស និងកន្លែងពិសោធន៍អាមេរិកឡាទីនសម្រាប់វាយតម្លៃគុណភាពអប់រំ (LLECE) ដែលអនុវត្តការងារក្នុងប្រទេសចំនួន ១៦។ កម្មវិធីអន្តរជាតិពីរផ្សេងទៀតដែលមួយគឺជាគម្រោងរួមគ្នារវាងអង្គការ UNESCO និង UNICEF សម្រាប់ត្រួតពិនិត្យសមិទ្ធិកម្មនៃការសិក្សា និងមួយទៀតគឺជាកម្មវិធីសិក្សាក្នុងប្រទេសអាព្រិចនិយាយភាសាបារាំង (PASEC) បានអនុវត្តការងារនៅប្រទេសជាច្រើន ប៉ុន្តែកម្មវិធីទាំងពីរនេះមិនបានត្រួតពិនិត្យពីសមិទ្ធិកម្មនៃការអប់រំមួយរយៈកន្លងទៅទេ។

ការស្រាវជ្រាវទាំងឡាយ ដូចជា ការសិក្សាដែលបញ្ជាក់ក្នុងប្រអប់ខាងលើអាចជាការប្រៀបធៀបដ៏មានតម្លៃទៅលើសមិទ្ធិកម្មនៃការរៀនសូត្រក្នុងប្រទេសនានាក្នុងរយៈពេលមួយ បើទោះបីការស្រាវជ្រាវទាំងនោះមិនអាចយកមកប្រៀបធៀបបានដោយសារកត្តានៃការសិក្សាមួយចំនួនមានលក្ខណៈខុសគ្នាក៏ដោយ។ ការស្រាវជ្រាវទាំងនោះបង្ហាញថា គុណភាពនៃការអប់រំនៅអាព្រិចបានប្រឈមមុខទៅនឹងការលំបាកមួយចំនួនក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ឧទាហរណ៍ ការប្រៀបធៀបរវាងការសិក្សាដែលធ្វើឡើងដោយ SACMEQ នៅឆ្នាំ ១៩៩៥ – ១៩៩៦ និង ឆ្នាំ ២០០០ – ២០០១ បង្ហាញឲ្យឃើញពីការធ្លាក់ចុះចំនួន ៤% នៃពិន្ទុតេស្តអក្ខរកម្មថ្នាក់ទី ៦ ដោយមានភាពខុសគ្នាយ៉ាងខ្លាំងកើតឡើងនៅប្រទេសម៉ាឡាវី ណាមីប៊ី និងមាសបៀរ (ក្រាហ្វ ២.២)។ ទោះបីជាគ្មានការបញ្ជាក់ពីមូលហេតុឲ្យបានច្បាស់លាស់ក៏ដោយ ក៏ប្រាក់ចំណូលប្រចាំគ្រួសារអាចមានការធ្លាក់ចុះនៅក្នុងប្រទេសដែលទទួលរងគ្រោះបំផុតចំនួន ៣ ដែរ។ ក្នុងប្រទេសម៉ាឡាវី ចំនួនសិស្សរៀននៅបឋមសិក្សាបានកើនទ្វេក្នុងរយៈពេល ១ ទសវត្សរ៍កន្លងទៅនេះ (ការបង់ថ្លៃសាលាត្រូវលុបចោលនៅឆ្នាំ ១៩៩៤) ធនធានសាលារៀនបានធ្លាក់ចុះស្ទើរទាំងស្រុងក្នុងអំឡុងពេលនៃការសិក្សាទាំងពីរលើករបស់ SACMEQ។

**ក្រាហ្វ ២.២ : បំរែបំរួលពន្ទុអក្ខរកម្មរវាង SACMEQ I និង SACMEQ II ក្នុងប្រទេសអាព្រិចចំនួន ៦**




កំណត់សំគាល់ : អានជំពូក ២ របាយការណ៍អប់រំសម្រាប់ទាំងអស់គ្នា

**ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ពិតជាមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងការសម្រេចជោគជ័យគ្រប់បរិបទអប់រំ**

ក្នុងចំណោមមេរៀនទាំងឡាយដែលដកស្រង់ចេញពីការសិក្សាតេស្តសមិទ្ធិកម្មក្នុងមួយរយៈពេលកន្លងទៅឲ្យដឹងថា ទីមួយ : ស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសមិទ្ធិកម្មក្នុងបរិបទទាំងអស់។ នៅអាព្រិច និងអាមេរិកឡាទីនមានភាពខុសគ្នាយ៉ាងខ្លាំងរវាងតំបន់ជនបទ និងទីក្រុងដែលនៅទីនោះ តំបន់ទីក្រុងមានគ្រូបង្រៀនដែលមានចំណេះដឹងខ្ពស់។ ទីពីរ : ការចំណាយពេលក្នុងថ្នាក់រៀនសម្រាប់មុខវិជ្ជាគណិតវិទ្យា វិទ្យាសាស្ត្រ និងភាសាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើការសិក្សារបស់សិស្ស។ ទីបី : យេនឌ័រគ្រូបង្រៀនមានឥទ្ធិពលក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន។ ឧទាហរណ៍នៅអាព្រិច សិស្សសាលា ពិសេសសិស្សស្រីដែលបានទទួលការបង្ហាត់បង្រៀនដោយគ្រូស្រីទទួលបានលទ្ធផលសិក្សាល្អជាងសិស្សស្រីដែលបង្រៀនដោយគ្រូប្រុស។

ការស្រាវជ្រាវមួយចំនួនបង្ហាញថា ស្ថានភាពសេដ្ឋកិច្ច–សង្គមរបស់សិស្សខ្សត់ខ្សោយ និងជួបការលំបាកអាចត្រូវបានលើកកំពស់មួយផ្នែកដោយសារតែការកែលំអបរិយាកាសក្នុងសាលា ការយកចិត្តទុកដាក់ខ្ពស់របស់គ្រូបង្រៀន ស្វ័យភាពរបស់សាលា និងធនធានសម្រាប់សិក្សា (ជាពិសេសសៀវភៅសិក្សា)។

## វង្វាយតម្លៃគុណភាពសាលា : យកការស្រាវជ្រាវជាខ្នាតគំរូ

ការពិតមួយបញ្ជាក់ថា ការចំណាយបានកើនឡើងសម្រាប់សិស្សម្នាក់នាំឲ្យសិស្សនោះទទួលបានលទ្ធផលខ្ពស់។ ទោះជាយ៉ាងនេះក៏ដោយ នៅប្រទេសចំនួន ១១ ដែលអង្គការអភិវឌ្ឍន៍សេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការ (OECD) អនុវត្តការផារពិន្ទុតេស្តមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ ជាទូទៅធ្លាក់ចុះក្នុងអំឡុងពេល ១ ភាគ ៤ នៃចុងទសវត្សរ៍ឆ្នាំ ១៩៩៥ បើទោះបីជាការចំណាយសម្រាប់សិស្សម្នាក់ៗបានកើនឡើងទ្វេដងក៏ដោយ។ ការនេះមានកត្តាមួយចំនួនបញ្ជាក់ពីឥទ្ធិពលតិចតួចទៅលើលទ្ធផលនៃការរៀនសូត្រ ដោយសារតែការកើនឡើងនៃការចំណាយ។ ការចំណាយច្រើនជាងមុន ដោយសារក្នុងរយៈពេលកន្លងមក ប្រាក់ចំណូលពិតប្រាកដរបស់មនុស្សម្នាក់ៗ ពេលខ្លះកើនឡើងលឿន ជាងការចំណាយរបស់សិស្សម្នាក់។ ប្រព័ន្ធសាលារៀនបានពង្រីកដើម្បីឲ្យសិស្សកាន់តែច្រើនឡើងអាចចុះឈ្មោះចូលរៀន ហើយក្នុងករណីមួយចំនួន ស្ថានភាព និងប្រាក់ខែរបស់គ្រូបង្រៀនកើនឡើងបើប្រៀបធៀបទៅនឹងវិជ្ជាជីវៈផ្សេងៗ។

## ការសិក្សាពីមុខងារផលិតភាព : ភស្តុតាងលំអិត

នៅទសវត្សរ៍ ១៩៦០ ការស្រាវជ្រាវដ៏សំខាន់មួយនៅសហរដ្ឋអាមេរិកបង្ហាញថា សាលារៀនគឺជាកន្លែងដ៏សំខាន់បង្កឲ្យមានវិសមភាពសង្គម។ ស្ថានភាពគ្រួសារ និងក្រុមមិត្តភក្តិមានឥទ្ធិពលយ៉ាងខ្លាំងលើលទ្ធផលរៀនសូត្រច្រើនជាងធនធានផ្សេងៗក្នុងសាលារៀន។ ការអះអាងនេះបង្កើតឲ្យមានការសិក្សាលំអិតមួយក្នុង

នៅស្រុកគីជីវ៉ា ប្រទេសកេនញ៉ា សិស្សនៅសាលាមួយកក្នុងភូមិផ្លាស់វេនគ្នាប្រើក្ដារខៀនមួយនៅក្រៅថ្នាក់ដោយសារខ្វះបរិក្ខារៀន។ អត្រាសិស្សចុះឈ្មោះចូលរៀនបានកើនឡើងជាខ្លាំងក្រោមពីរដ្ឋាភិបាលបានលុបថៃចំណាយសម្រាប់ចូលរៀនក្នុងសាលាក្នុងឆ្នាំ ២០០៣។



© THERRY DUDOIT/L'EXPRESS/EDITINGSERVER.COM

គោលបំណងពិនិត្យឲ្យបានច្បាស់លាស់ថា តើការរកឃើញទាំងនោះជាការត្រឹមត្រូវឬយ៉ាងណា។ អ្នកស្រាវជ្រាវទាំងឡាយបានប្រើប្រាស់វិធីសាស្ត្រ "មុខងារផលិតកម្ម"មួយមានឥទ្ធិពលខ្លាំងក្លាបំផុតទៅលើលទ្ធផលនៃការសិក្សារបស់សិស្សដែលត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយក្នុងវិស័យសេដ្ឋកិច្ចដើម្បីវិភាគថា តើធនធានប្រភេទណាដែលគ្រប់គ្រងដោយគោលនយោបាយដែលរួមមានកម្រិតវប្បធម៌គ្រូបង្រៀន បទពិសោធន៍ការងារ ប្រាក់ខែគ្រូ សម្ភារបង្រៀន អត្រាផលធៀបគ្រូ និងសិស្ស។ ការវិភាគជារួមទៅលើការស្រាវជ្រាវទាំងនេះដែលបានបោះពុម្ពផ្សាយនៅមុនឆ្នាំ ១៩៩៥ នៅសហរដ្ឋអាមេរិកបានរកឃើញថាពុំមានទំនាក់ទំនងច្បាស់លាស់ណាមួយរវាងការចំណាយធនធាន និងលទ្ធផលសិក្សារបស់សិស្សឡើយ។ លទ្ធផលទាំងនោះរឹតតែបង្ហាញឲ្យឃើញច្បាស់ឡើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដែលកន្លែងប្រើប្រាស់វិធីនេះសម្រាប់ការស្រាវជ្រាវភាគច្រើនបង្ហាញថា គ្រូដែលមានការអប់រំល្អ និងមានបទពិសោធន៍ ការចំណាយច្រើនសម្រាប់សិស្សម្នាក់ៗ និងសម្ភារសិក្សាក្នុងសាលាសមស្របមានឥទ្ធិពលលើការរៀនសូត្រ។ ផ្ទុយទៅវិញ ថ្វីបើការសិក្សាមួយចំនួនបានប្រើប្រាស់វិធីសាស្ត្រនេះក៏ដោយ ក៏មានមតិរិះគន់ជាច្រើន។ ការជំទាស់មួយគឺថា អាកប្បកិរិយាសិស្ស និងដំណើរការរៀនសូត្រមិនអាចដាក់ធ្វើជាខ្នាតគំរូ ប្រៀបដូចវត្ថុធាតុដើម និងផលិតផលមិនអាចប្រៀបធៀបគ្នាបានទេ។

## តើមានអ្វីខ្លះកើតឡើងក្នុងសាលារៀន?

វិធីសាស្ត្រមុខងារផលិតភាពមិនបានយកចិត្តទុកដាក់ឲ្យបានដិតដល់លើវិធីនានាដែលក្នុងនោះសកម្មភាពរៀន និងបង្រៀន (សកម្មភាពប្រកបដោយការច្នៃប្រឌិតនៅក្នុងថ្នាក់រៀន)មានឥទ្ធិពលទៅលើគុណភាពអប់រំ។ ដូចនេះ អ្នកស្រាវជ្រាវមួយក្រុមដែលមានជំនាញចម្រុះបានចាប់ផ្តើមស្រាវជ្រាវទៅលើកត្តាអ្វីខ្លះដែលធ្វើឲ្យសាលានានាបង្រៀនមានប្រសិទ្ធភាព។ ការស្រាវជ្រាវនេះបង្ហាញថា សាលាបឋមសិក្សាទាំងឡាយ ដែលបានទទួលជោគជ័យ ជាធម្មតាគឺជាលទ្ធផលនៃការដឹកនាំដ៏ខ្លាំងពូកែ បរិយាកាសក្នុងបន្ទប់រៀន និងសាលាប្រកបដោយសុវត្ថិភាព និងមានសណ្តាប់ធ្នាប់ ការយកចិត្តទុកដាក់ទៅលើតម្រូវការ ជំនាញមូលដ្ឋាន ក្តីសង្ឃឹមខ្ពស់ពីភាពជោគជ័យរបស់សិស្ស និងការវាយតម្លៃពីការរីកចម្រើនជាប្រចាំ។ ទោះបីយ៉ាងនេះក៏ដោយ ក៏ការសិក្សាទាំងនេះបញ្ជាក់ពីភាពខុសគ្នាតិចតួចនៃលទ្ធផលយល់ដឹងចំពោះប្រទេសអ្នកមាន។ ស្ថានភាពគ្រួសារ បទពិសោធន៍នៅសាលាមត្តេយ្យ និងភាពខុសគ្នាដែលមានការលំបាកក្នុងការវាស់វែងផ្សេងៗទៀត នៅតែជាផ្នែកដ៏សំខាន់។ ទោះជាយ៉ាងនេះក៏ដោយ ក៏លទ្ធផលមានភាពត្រឹមត្រូវច្រើនសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ប្រសិនមានពេលវេលាបង្រៀន មានសៀវភៅអាន និងមានសម្ភារបង្រៀនគ្រប់គ្រាន់ ព្រមទាំងគ្រូមានចំណេះដឹងខ្ពស់ ដែលកត្តាទាំងនេះមានមុខងារដ៏សំខាន់ធ្វើឲ្យការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ។

**របៀបនៃការចំណាយពេលវេលារបស់គ្រូមានឥទ្ធិពលយ៉ាងខ្លាំងទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស។**

លទ្ធផលនៃការស្រាវជ្រាវក៏បង្ហាញដែរថា របៀបនៃការចំណាយពេលរបស់គ្រូបក៏មានឥទ្ធិពលខ្លាំងលើលទ្ធផលនៃការរៀនសូត្ររបស់សិស្សផងដែរ។ វិធីសាស្ត្របង្រៀនដែលមានការរៀបចំត្រឹមត្រូវផ្តល់លទ្ធផលខ្ពស់ជាពិសេសសម្រាប់សិស្សដែលពុំសូវមានលទ្ធភាពក្នុងសាលាបឋមសិក្សា និងជាទូទៅនៅក្នុងកម្រិតខ្ពស់ៗ។ វិធីទាំង នេះតម្រូវឲ្យគ្រូបង្កើតគោលបំណង មុខងាររៀនសូត្រឲ្យបានច្បាស់លាស់ និងទុក ពេលវេលាឲ្យសិស្សសួរសំណួរអនុវត្ត និងតេស្តឲ្យបានទៀងទាត់។ ការចងក្រងសិស្សជាក្រុមទៅតាមលទ្ធភាពជាទង្វើដ៏ប្រសើរសម្រាប់សិក្សាជំនាញ ជាពិសេស ជំនាញអាន និងគណិតសាស្ត្រ។ ពុំមានអ្នកផ្តល់ការអប់រំទាំងអស់ឯកភាពលើវិធីសាស្ត្រនេះឡើយ សិស្សទាំងនោះប្រកាន់យកវិធីសាស្ត្រ "ស្ថាបនានិយម"




សកម្មភាពរៀនប្រកបដោយសេចក្តីសប្បាយរីករាយ : នៅបាហៀ ប្រេស៊ីល កុមារីគូររូបផ្កានបាតដៃលេងនៅលើក្តារខៀន។

ដែលសង្កត់ធ្ងន់លើការសិក្សាដោយខ្លួនឯងតាមរយៈការស្រាវជ្រាវ។ ចំណុចគន្លឹះគឺការកំណត់ថា តើត្រូវយកចិត្តទុកដាក់លើវិធីសាស្ត្ររៀនសូត្រកម្រិតណាដើម្បីជួយដល់លទ្ធភាពរៀនសូត្ររបស់សិស្សនិងបំពេញគោលបំណងរបស់សិស្ស។

## ការសិក្សាតាមវិធីពិសោធន៍ :ករណីមានធនធានច្រើនជាងនេះ

អ្នកស្រាវជ្រាវទាំងឡាយបានពិសោធព្រាវៗដើម្បីស្វែងយល់ពីឥទ្ធិពលនៃការចូលរួមធ្វើអន្តរាគមន៍ពីសំណាក់គោលនយោបាយទៅលើលទ្ធផលនៃការសិក្សានៅក្នុងបរិបទពិសេសមួយ ដោយប្រៀបធៀបជាមួយនឹងក្រុមស្ថិតក្រោមការត្រួតពិនិត្យ។ បើទោះបីលទ្ធផលមិនអាចបញ្ជាក់ពីមូលហេតុឲ្យបានគ្រប់គ្រាន់សម្រាប់កំណត់ពីវិសាលភាពក៏ដោយ ក៏ការសិក្សាមួយចំនួនបង្ហាញពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងធនធានសាលារៀន និងលទ្ធផលនៃ ការរៀនសូត្រ។ នៅចុងទសវត្សរ៍ឆ្នាំ ១៩៨០ គម្រោងអត្រាសមិទ្ធិកម្មផលធៀបគ្រូ និងសិស្ស (STAR) នៅរដ្ឋតានេស៊ី (សហរដ្ឋអាមេរិក)បានស្រាវជ្រាវទៅលើសិស្សចំនួនប្រហែល១២០០០នាក់ចាប់ពីថ្នាក់មត្តេយ្យរហូត ដល់ថ្នាក់ទី ៣ ដោយចំណាយពេលជាង ៤ ឆ្នាំ ដើម្បីស្វែងយល់អំពីឥទ្ធិពលនៃទំហំថ្នាក់រៀនទៅលើលទ្ធផលនៃការសិក្សារបស់សិស្ស។ លទ្ធផលទាំងឡាយបានបង្ហាញថា ការកាត់បន្ថយចំនួនសិស្សក្នុងថ្នាក់រៀនមានឥទ្ធិពលវិជ្ជមាន ជាពិសេសសម្រាប់សិស្សមកពីស្ថានភាពលំបាក និងក្រីក្រ។ នៅប្រទេសកេនញ៉ា ធនធានសាលាល្អ (ម្ហូបអាហារ ឯកសណ្ឋាន សៀវភៅសិក្សា) ជួយលើកកំពស់ការសិក្សា បើទោះបីជាថ្នាក់រៀនមានចំនួនសិស្សច្រើនក៏ដោយ។ នៅប្រទេសហ្វីលីពីន ការពិសោធមួយក្នុងសាលាចំនួន ៣០ បង្ហាញថា ការផ្តល់សម្ភារគរុកោសល្យជួយកាត់បន្ថយអត្រាបោះបង់ចោលសាលារបស់សិស្សយ៉ាងច្រើន។ នៅប្រទេសឥណ្ឌា កុមារក្នុងតំបន់អនាធិបតេយ្យក្នុងក្រុងដែលមិនបានទទួលការសិក្សានៅបឋមសិក្សា ប៉ុន្តែបានទទួលការអប់រំបំប៉នពីកម្មវិធីរបស់អង្គការក្រៅរដ្ឋាភិបាលមួយបានទទួលលទ្ធផលល្អ។

ការពិសោធបែបនេះជួយពង្រឹងដល់ករណីចំពោះថ្នាក់ដែលមានទំហំតូច មានឯកសារសិក្សាច្រើន ការបណ្តុះបណ្តាលគ្រូដោយអនុវត្តផ្ទាល់ និងវិធីបង្រៀនដែលសង្កត់ធ្ងន់ទៅលើតម្រូវការរបស់អ្នករៀន ជាពិសេសនៅក្នុងប្រទេសក្រីក្រ និងក្រុមសិស្ស ដែលពុំសូវមានលទ្ធភាព និងជួបការលំបាក។

### ប្រព័ន្ធឈានទៅសម្រេចនិយាមស្តង់ដាខ្ពស់ជាង‌នេះ : ចំណុចសំខាន់ៗរបស់គោលនយោបាយជាតិក្នុងប្រទេសចំនួន ១១

| ប្រទេស | តួលេខគន្លឹះ | ចំណុចខ្លាំង |
|---|---|---|
| **ប្រទេសលោភលន់** | | |
| អាព្រិចខាងត្បូង | ■ ប្រាក់ចំណូលទាប<br>■ ការរីកចម្រើនខ្លាំងក្លាលើលទ្ធភាពចូលរៀនក្នុងសាលាបឋមសិក្សា : អត្រាចុះឈ្មោះចូលរៀនពិត ៨៥.៦% ២០០១ កើនពី ៧១.២% ១៩៩០<br>■ សមភាពយេនឌ័រគិតជាតួលេខសម្រេចនៅបឋមសិក្សា<br>■ ការវាយតម្លៃលទ្ធផលនៃការសិក្សាបង្ហាញឲ្យឃើញពីកម្រិតទាបនៃជំនាញជាមូលដ្ឋាន<br>■ ២.២%នៃផលិតផលក្នុងស្រុកសរុបសម្រាប់អប់រំ | ■ កុមារ ២ លាននាក់រៀននៅតាមសាលារបស់អង្គការក្រៅរដ្ឋាភិបាល (១៩ លាននាក់នៅសាលាក្នុងប្រព័ន្ធ<br>— សាលារបស់គណកម្មាធិការអភិវឌ្ឍជនបទរបស់បង់ក្លាដែសបង្រៀនច្រើនអំពីបំណិនជីវិត និងជំនាញសរសេរបើប្រៀបធៀបនឹងសាលាធម្មតា ចំណែករៀនអាន និងអក្ខរកម្មទទួលបានលទ្ធផលដូចគ្នា តែអត្រាឡើងថ្នាក់ទៅមធ្យមសិក្សាបានច្រើនជាង។<br>■ រដ្ឋាភិបាលបន្តប្តេជ្ញាខ្ពស់ក្នុងការកែទម្រង់អប់រំ។ កាតព្វកិច្ចចំបងៗរួមមាន : អត្រាអវត្តមានគ្រូខ្ពស់ ហើយម៉ោងរៀនតិច។ |
| ស្រីលង្កការ | ■ ប្រាក់ចំណូលក្រោមមធ្យម<br>■ អត្រាចុះឈ្មោះចូលរៀនពិត ៩៦.៥% ២០០១ កើនពី ៨៥.៦% ១៩៩០<br>■ ៤.២%នៃផលិតផលក្នុងស្រុកសរុបសម្រាប់អប់រំ | ■ កិច្ចប្រឹងប្រែងដែលមានចែងក្នុងគោលនយោបាយក្នុងផែនការអប់រំសម្រាប់ទាំងអស់គ្នា ១៩៩៣ – ២០០៣ ដើម្បីកាត់បន្ថយវិសមភាពតាមតំបន់ និងក្នុងសង្គមតាមរយៈគម្រោងធំៗដូចជា :<br>— មូលនិធិសមភាពរបស់ FUNDEF សម្រាប់បន្ថយគម្លាតវិសមភាពនៃការផ្តល់ហិរញ្ញវត្ថុទៅឲ្យសាលាបឋមសិក្សាតាមតំបន់<br>— FUNDESSCOLA ដើម្បីបង្កើនអត្រាសិស្សចូលរៀន និងកាត់បន្ថយអត្រាសិស្សបោះបង់ចោលសាលា<br>— កម្មវិធីអាហារូបករណ៍ Bolsa Escola សម្រាប់គ្រួសារក្រីក្រ<br>— កម្មវិធីលើកកំពស់សមត្ថភាព : ការបណ្តុះបណ្តាលគ្រូដែលគ្មានសញ្ញាប័ត្រតាមរយៈកម្មវិធីរៀនពីចម្ងាយ<br>— កម្មវិធីសិស្សបំប៉ន : ផ្តល់ឱកាសឲ្យសិស្សដែលចុះឈ្មោះចូលរៀនដើម្បីឲ្យមានឱកាសរៀនទាន់គេ<br>— កម្មវិធីសៀវភៅសិក្សាតាមសាលា |
| កាណាដា | ■ ប្រាក់ចំណូលលើមធ្យម<br>■ អត្រាចុះឈ្មោះចូលរៀនពិត = ៨៨.៨% ២០០០<br>■ សមភាពយេនឌ័រគិតជាតួលេខសម្រេចនៅបឋមសិក្សា និងមធ្យមសិក្សា<br>■ ៤%នៃផលិតផលក្នុងស្រុកសរុបសម្រាប់អប់រំ | ■ ក្នុងមួយទសវត្សរ៍ទៀត បង្កើនថវិកាឲ្យបានទ្វេដងសម្រាប់វិស័យអប់រំ<br>■ ជោគជ័យក្នុងលទ្ធផលសិក្សាកើនឡើងដោយសារការខិតខំយកចិត្តទុកដាក់ឡើសាលាខ្សោយចំនួន ១០%<br>■ វិធីបង្រៀនបែបចូលរួម និងបែបសកម្មកាន់តែប្រើច្រើន<br>■ ក្នុងមួយឆ្នាំៗបង្កើនម៉ោងរៀនឲ្យបានពី ៩៩០ ដល់ ១២០០ ម៉ោង<br>■ បច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ជាគន្លឹះក្នុងការធ្វើទំនើបកម្មអប់រំ |
| គូបា | ■ ប្រាក់ចំណូលក្រោមមធ្យម<br>អត្រាចុះឈ្មោះចូលរៀនពិត ៩០.៣% ២០០១<br>កើនពី ៨៤% ១៩៩០<br>■ ដោយសារការពង្រីកការអប់រំកាន់តែខ្លាំង ទើបការសម្រេចសកលកម្មអប់រំបឋមសិក្សា និងសមភាពយេនឌ័រគិតជាតួលេខជិតឈានមកដល់ | ■ តាំងពីដើមទសវត្សរ៍ ១៩៩០ អត្រាសិស្សត្រួតថ្នាក់ និងបោះបង់ចោលសាលាធ្លាក់ចុះ<br>■ យកចិត្តទុកដាក់លើកម្មវិធីគាំពារ និងអប់រំកុមារតូច<br>■ ចុងទសវត្សរ៍ ១៩៩០ : បង្កើនប្រាក់ខែគ្រូ បន្ថយចំនួនសិស្សក្នុងថ្នាក់ ពង្រឹងវគ្គបំប៉នគ្រូ និងកែលំអប្រព័ន្ធ<br>■ ផែនការ ៥ ឆ្នាំ ២០០២ – ២០០៧– យកចិត្តទុកដាក់លើ "ភាពល្អប្រពៃសម្រាប់ទាំងអស់គ្នា"<br>■ ការគ្រប់គ្រងបែបវិមជ្ឈការ និងផ្អែកលើបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍គឺជាវិធីសាស្ត្រពាណិជ្ជកម្មដែលអាចយកទៅប្រើក្នុងការវាយតម្លៃសកម្មភាពរបស់សាលារៀន |
| ហ្វាំងឡង់ | ■ ប្រាក់ចំណូលទាប<br>■ ពង្រីកឱកាសចូលរៀនឲ្យបានច្រើន : អត្រាចុះឈ្មោះចូលរៀនពិត = ៥៨% ២០០១ កើនពី ៤៧% ១៩៩០<br>■ សមភាពយេនឌ័រគិតជាតួលេខ = ០.៩១<br>■ អត្រាសិស្សត្រួតថ្នាក់ខ្ពស់បន្តរនៅថ្នាក់ខ្ពស់<br>■ ៣.២%នៃផលិតផលក្នុងស្រុកសរុបសម្រាប់អប់រំ | ■ វិធីសាស្ត្រ FAIRE-FAIRE (ធានាអនុវត្តឲ្យបាន)<br>— ចែកការងារឲ្យអ្នកអនុវត្តតាមសហគមន៍ជួយធ្វើ។ ឱ. វិធីសាស្ត្រអនុវត្តក្នុងកម្មវិធីអក្ខរកម្ម :<br>— មានមនុស្សចាស់ចុះឈ្មោះចូលរៀនប្រមាណ ១ លាននាក់ ហើយយុវវ័យក្រៅសាលាបានចុះឈ្មោះចូលរៀនប្រមាណជាងកន្លះលាននាក់។<br>■ សមាគមនាយកសាលាក្នុងប្រព័ន្ធអប់រំ : ក្រុមនាយកសាលាតាមតំបន់បំផុសឲ្យមានការរៀនសូត្រ និងដកបទពិសោធន៍ពីគ្នាទៅវិញទៅមក |

## វិសាលភាពសង្គម

ការបង្រៀន និងការរៀនកើតឡើងក្នុងបរិបទសង្គម និងនយោបាយ។ ភាពទន់ខ្សោយផ្នែកគ្រប់គ្រងរបស់សាលាគឺត្រូវបានចាត់ទុកថា ជាមូលហេតុចំបងនៃការធ្លាក់ចុះលទ្ធផលនៃការសិក្សា ជាពិសេស សាលារដ្ឋនៅប្រទេសកំពុងអភិវឌ្ឍ។ អ្នកវិភាគមួយចំនួនជំរុញឲ្យមានការកែប្រែក្នុងរចនាសម្ព័ន្ធលើកទឹកចិត្តគ្រូដែលជាមធ្យោបាយលើកកំពស់លទ្ធផលសិក្សារបស់សិស្ស។ ទោះជាយ៉ាងនេះក៏ដោយ ក៏ភស្តុតាងបង្ហាញពីទំនាក់ទំនងពុំរឹងមាំរវាងប្រាក់ខែខ្ពស់ និងប្រសិទ្ធភាពបង្រៀន។ ម្យ៉ាងវិញទៀត បរិបទសង្គមរបស់សាលារៀនគឺជាកត្តាដ៏សំខាន់។ ការស្រាវជ្រាវទាំងឡាយអំពីទំនាក់ទំនងសង្គមជាមួយការអប់រំបញ្ជាក់ថា សិស្សដែលស្ថានភាពគ្រួសារ និងក្រុមមិត្តភក្តិមានគំនិតស្រដៀងគ្នា នឹងសិស្សដែលទទួលបានការលើកទឹកចិត្តពីសាលាខិតខំរៀនសូត្រខ្លាំង ហើយទទួលបានកម្រិតនៃជំនាញវិភាគខ្ពស់ជាងសិស្សដែលព្យាយាមមិនបញ្ជាក់ពីការខ្វែងគ្នារវាងគំនិតរបស់គេផ្ទាល់ និងគំនិតរបស់សាលា ដោយសកម្មភាពជំទាស់ ដូចជាការកាត់បន្ថយការខិតខំសិក្សាជាដើម។ តម្រូវការសម្រាប់គោលនយោបាយអប់រំដែលត្រូវបង្កើតគោលដៅសង្គមច្បាស់លាស់គឺជាចំណុចសម្រាប់ពិចារណាលើកកំពស់គុណភាពសាលាដែលមិនអាចដោះស្រាយដោយមធ្យោបាយបច្ចេកទេសតែឯងបានឡើយ។

| ប្រទេស | តួលេខគន្លឹះ | ចំណុចខ្លាំង |
|---|---|---|
| **ប្រទេសលោកលន់** | | |
| អព្រិច ខាងត្បូង | ■ ប្រាក់ចំណូលទាបមធ្យម<br>■ អត្រាចុះឈ្មោះចូលរៀនពិតក្រោម ៩០%<br>■ សមភាពយេនឌ័រគិតជាតួលេខ = ០.៩៦<br>៥.៥%នៃផលិតផលក្នុងស្រុកសរុបសម្រាប់អប់រំ | ■ វិធានការកាត់បន្ថយវិសមភាព និងលើកកំពស់គុណភាព ចាប់តាំងពីរបបផ្តាច់ការអាប៉ាថេតដួលរលំ ១៩៩៤<br>■ ការអប់រំដោយកាតព្វកិច្ច ៩ ឆ្នាំ ដោយទំលាក់ថវិកាឲ្យបានស្មើគ្នាសម្រាប់គ្រប់ក្រុមជនជាតិទាំងអស់<br>■ ចាប់ផ្តើមអនុវត្តឲ្យមានគណកម្មាការអភិបាលកិច្ចសាលា<br>■ ចាប់ផ្តើមកម្មវិធីសិក្សាថ្មីកាលពីឆ្នាំ ១៩៩៧<br>■ យកចិត្តទុកដាក់លើកកំពស់ភាពស្វ័យម្ចាស់ការ និងទទួលខុសត្រូវក្នុងវិជ្ជាជីវៈគ្រូបង្រៀន |
| ស្រីលង្កា | ■ បាក់ចំណូលទាបមធ្យម<br>■ សម្រេចសកលកម្មអប់រំបឋមសិក្សា និងសមភាពយេនឌ័រគិតជាតួលេខនៅបឋមសិក្សាដែរ<br>■ ១.៣%នៃផលិតផលក្នុងស្រុកសរុបសម្រាប់អប់រំ | ■ អត្រាត្រួតថ្នាក់ និងបោះបង់ចោលសាលាធ្លាក់ចុះជាខ្លាំងក្នុងទសវត្សរ៍ ១៩៩០<br>■ វិធីសាស្ត្រលំអិតសម្រាប់កែទម្រង់ (១៩៨១) ដោយមានសង្គមស៊ីវិលចូលរួម<br>■ យកចិត្តទុកដាក់លើគ្រូបង្រៀន និងអភិវឌ្ឍសមត្ថភាពតាមដាន និងវាយតម្លៃ |
| **អនុវត្តការងារបានល្អ** | | |
| កាណាដា | ■ ប្រាក់ចំណូលខ្ពស់<br>■ សម្រេចសកលកម្មអប់រំបឋមសិក្សា និងសមភាពយេនឌ័រគិតជាតួលេខនៅបឋមសិក្សា និងមធ្យមសិក្សាផងដែរ<br>■ ៥.៥%នៃផលិតផលក្នុងស្រុកសរុបសម្រាប់អប់រំ | ■ កូនជនអន្តោប្រវេសន៍រៀនពូកែ ពោរពេញដោយពហុវប្បធម៌សម្រាប់កសាងជាតិ<br>■ មានការគោរពវិជ្ជាជីវៈគ្រូបង្រៀនខ្លាំង ការប្រលងជ្រើសរើសគ្រូចូលរៀនមានលក្ខខណ្ឌតឹងរឹងខ្លាំង<br>■ កម្មវិធីបំប៉នគ្រូគ្រប់គ្រាន់<br>■ មានប្រព័ន្ធគាំទ្រនៅថ្នាក់ឃុំ និងតាមសាលាខ្លាំងក្លា<br>■ ការតាមដានរបស់សាលាផ្ទាល់ របស់ស្រុក និងខេត្តផ្ទាល់ដើម្បីទប់ស្កាត់កុំឲ្យមានវិសមភាពកើតឡើង |
| គុបា | ■ ប្រាក់ចំណូលលើមធ្យម<br>■ អត្រាចុះឈ្មោះចូលរៀនពិត = ៩៨.៨% ២០០០ សមភាពយេនឌ័រគិតជាតួលេខសម្រេចនៅបឋមសិក្សា និងមធ្យមសិក្សា<br>■ ៩%នៃផលិតផលក្នុងស្រុកសរុបសម្រាប់អប់រំ | ■ ការអប់រំជាស្តម្ភយុទ្ធសាស្ត្ររបស់បដិវត្តរបស់ប្រទេសគុយបា<br>■ និរន្តរភាពវិនិយោគ<br>■ គ្រូទទួលបានតម្លៃ និងកិត្តិយសខ្ពស់<br>■ មានរង្វាន់លើកទឹកចិត្តសម្រាប់សិស្សពូកែ គ្រូល្អ និងសាលាល្អ<br>■ គោលការណ៍ប្រកួតប្រជែង សាមគ្គី និងសហការដើម្បីលើកកំពស់គុណភាព<br>■ យន្តការផ្លាស់ប្តូរបទពិសោធន៍ដើម្បីរៀនពីគ្នាទៅវិញទៅមក និងរួមគ្នារៀបរៀងកម្មវិធីសិក្សារួម |
| ហ្វាំងឡង់ | ■ ប្រាក់ចំណូលខ្ពស់<br>■ សម្រេចសកលកម្មអប់រំបឋមសិក្សា និងសមភាពយេនឌ័រគិតជាតួលេខនៅបឋមសិក្សាដែរ<br>■ ៦.៤%នៃផលិតផលក្នុងស្រុកសរុបសម្រាប់អប់រំ | ■ និរន្តរភាពវិនិយោគសម្រាប់អភិវឌ្ឍធនធានមនុស្ស ដើម្បីជំនួសវិបត្តិសេដ្ឋកិច្ចកាលពីទសវត្សរ៍ ១៩៩០<br>■ គ្រូបង្រៀនមានសមត្ថភាពខ្ពស់<br>■ វិធីសាស្ត្រគរុកោសល្យល្អគ្រប់ជ្រុងជ្រោយ<br>■ សារៈសំខាន់នៃការរៀន និងកំសាន្តសប្បាយនៅចាមួយគ្នាជាទម្លាប់ |
| សាធារណៈ រដ្ឋកូរេ | ■ ប្រាក់ចំណូលខ្ពស់<br>■ សម្រេចសកលកម្មអប់រំបឋមសិក្សា និងសមភាពយេនឌ័រគិតជាតួលេខនៅបឋមសិក្សា និងមធ្យមសិក្សាផងដែរ<br>■ ៣.៦%នៃផលិតផលក្នុងស្រុកសរុបសម្រាប់អប់រំ | ■ ចាត់ទុកការអប់រំថា មានតួនាទីសំខាន់សម្រាប់អភិវឌ្ឍសេដ្ឋកិច្ច<br>■ យកចិត្តទុកដាក់លើគុណភាពតាំងពីទសវត្សរ៍ ១៩៨០<br>■ ពង្រីកកម្មវិធីរៀនពីចម្ងាយ និងកម្មវិធីអប់រំមនុស្សចាស់ ដើម្បីបន្ធូរបន្ថយសម្ពាធលើប្រព័ន្ធសាលារៀន<br>■ កម្មវិធីបណ្តុះបណ្តាលគ្រូមានរយៈពេលយូរ និងមានរង្វាន់លើកទឹកចិត្ត<br>■ មានបណ្តាញស្ថានប័នស្រាវជ្រាវ ទទួលហិរញ្ញវត្ថុផ្ទាល់តាមរយៈពន្ធអប់រំ<br><br>អត្រាផលធៀបសិស្សចុះឈ្មោះចូលរៀនពិតនៅបឋមសិក្សា = NEF<br>សិស្សសមភាព យេនឌ័រគិតជាតួលេខនៅបឋមសិក្សា = GPI<br>បច្ចេកវិទ្យាព័ត៌មានគមនាគមន៍ = ICT |

## មេរៀនជាបទពិសោធន៍ពីប្រទេស ១១

ផ្អែកតាមលទ្ធផលទាំងអស់នេះ ករណីសិក្សានានាពីប្រទេស ១១ ផ្តល់ឲ្យឃើញអំពីរបៀបដោះស្រាយបញ្ហាគុណភាពនៅប្រទេសអភិវឌ្ឍ និងកំពុងអភិវឌ្ឍ។ យោងទៅតាមតេស្តអន្តរជាតិ ប្រទេស ៤ ក្នុងចំណោមប្រទេសទាំង ១១ គឺ ប្រទេសកាណាដា គុយបា ហ្វាំងឡង់ និង សាធារណៈរដ្ឋកូរេមានខ្នាតគំរូនៃ គុណភាពនៃការអប់រំខ្ពស់។ សាធារណៈរដ្ឋកូរេមានចំណាត់ថ្នាក់លេខ ១ ខាង មុខវិជ្ជាវិទ្យាសាស្ត្រ និងលេខ៣ សម្រាប់មុខវិជ្ជាគណិតសាស្ត្រក្នុងកម្មវិធីវាយតម្លៃសិស្សជាអន្តរជាតិ (PISA) រីឯប្រទេសកាណាដាជាប់ចំណាត់ថ្នាក់លេខ២ខាងការអាន និងពិន្ទុសរុបខ្ពស់ជាងគេបំផុតបានទៅប្រទេសហ្វាំងឡង់។ ការសិក្សាជាមធ្យមភាគរបស់សិស្សក្នុងប្រទេសគុយបាខ្ពស់ជាងគេបំផុតក្នុងប្រទេសក្នុងតំបន់ដែលបានស្រាវជ្រាវនៅឆ្នាំ ២០០២ ដោយ OREALC[1]/UNESCO។ ប្រទេស ៧ ផ្សេងទៀតអាចចាត់ទុកជាប្រទេសមានមហិច្ឆតា ដោយសារប្រទេសទាំងនេះធ្វើការខិតខំប្រឹងប្រែងខ្លាំងក្លាទៅលើការអប់រំសម្រាប់ទាំងអស់គ្នាដោយផ្តោះបញ្ចាំងតាមរយៈការពង្រីកការអប់រំបឋមសិក្សាយ៉ាងឆាប់រហ័ស និងការឈានទៅសម្រេចសមភាពយេនឌ័រ

១. ការិយាល័យតំបន់ទទួលបន្ទុកកិច្ចការអប់រំនៅអាមេរិកឡាទីន និងការីប៊ីន



© Kevin Lamarque/REUTERS

បទពិសោធន៍ចូលរៀនដំបូងដ៏មានឥទ្ធិពល : សិស្សសាលាមត្តេយ្យនៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី

គិតជាតួលេខ។ ប្រទេសទាំងអស់កំពុងធ្វើការខិតខំប្រឹងប្រែងយ៉ាងមុតមាំដើម្បីនាំឲ្យមានតុល្យភាពរវាងគុណភាព និងបរិមាណ។ ប្រទេសប្រេស៊ីល និងជីលីគឺជាប្រទេសពីរក្នុងចំណោមប្រទេសទាំងឡាយមានការរីកចម្រើនអស្ចារ្យលើការអប់រំសម្រាប់ទាំងអស់គ្នានៅអាមេរិកឡាទីន និងនៅការ៉ាប៊ីន។ ប្រទេសទាំងពីរនេះក៏ដូចជាប្រទេសអាសង់ទីនដែរមានលទ្ធផលល្អប្រសើរ បើពិនិត្យទៅលើការស្រាវជ្រាវរបស់ OREALC/UNESCO ។ ប្រទេសប្រេស៊ីលដែលជាប្រទេសមានប្រជាជនច្រើនបានខិតខំប្រឹងប្រែងខាងគោលនយោបាយយ៉ាងខ្លាំងក្លាដើម្បីលើកកំពស់គុណភាពនៃប្រព័ន្ធអប់រំតាមរយៈគំនិតផ្ដួចផ្ដើមនានា ដើម្បីដោះស្រាយវិសមភាពធនធាន (ជាពិសេសការផ្ដល់មូលនិធិ) តាមតំបន់ និងក្នុងសង្គម និងលើសមិទ្ធិកម្ម។ ការផ្ដល់មូលនិធិសម្រាប់សាលាក្រីក្របំផុតបានកើនឡើងយ៉ាងខ្លាំង (បញ្ជាក់ពីកំណើននៃការចុះឈ្មោះ) ហើយប្រាក់ខែ និងការបណ្ដុះបណ្ដាលគ្រូបង្រៀនត្រូវបានលើកកំពស់។ បើទោះបីជាឥទ្ធិពលទៅលើលទ្ធផលនៃការសិក្សាមានភាពសាមញ្ញបំផុតក៏ដោយ ក៏គោលនយោបាយ និងយុទ្ធសាស្ត្រមួយចំនួនយកចិត្តទុកដាក់លើផ្នែកទាំងពីរនេះ (ប្រាក់ខែ និង ការបណ្ដុះបណ្ដាល) ដូចមានបង្ហាញនៅក្នុងតារាងដែលមានភ្ជាប់មកជាមួយនេះ។

មានចំណុចសាមញ្ញៗមួយចំនួនកើតមានឡើងនៅក្នុងប្រទេសមានលទ្ធផលខ្ពស់ទាំងបួន។ ជនទាំងអស់ដែលមានវិជ្ជាជីវៈជាគ្រូបង្រៀនឲ្យតម្លៃខ្ពស់លើវិជ្ជាជីវៈនេះ ហើយធ្វើការគាំទ្រតាមរយៈវិនិយោគលើការបណ្ដុះបណ្ដាល។ មានកិច្ចបន្តគោលនយោបាយក្នុងរយៈពេលកន្លងទៅនេះ និងមានចក្ខុវិស័យនៃគោលបំណងអប់រំរឹងមាំ។ ប្រទេសដែលមានមហិច្ឆតាទាំង ៧ បានជំរុញឲ្យមានការរីកចម្រើនពិតប្រាកដក្នុងការពង្រីកឱកាសអប់រំ ដោយសារគំនិតផ្ដួចផ្ដើមខាងគោលនយោបាយថ្មីៗក្នុងនោះមានគោលបំណងលើកកំពស់លទ្ធផលជំនាញវិភាគផងដែរ។ ទោះបីជាគ្មានក្របខ័ណ្ឌជាសកលពិត ក៏មានចក្ខុវិស័យរឹងប៉ឹងយូរអង្វែងសម្រាប់ការអប់រំ ការដឹកនាំរបស់រដ្ឋាភិបាល និងក្រុមគ្រូបង្រៀនដែលទទួលបានការគាំទ្រល្អ និងមានទឹកចិត្តខ្ពស់គឺជាលក្ខខណ្ឌសម្រាប់កែទម្រង់គុណភាពអប់រំប្រកបដោយជោគជ័យ។ សម្រាប់ប្រទេសដែលមានមហិច្ឆតាទាំងនោះ ចំណង់ចំណូលចិត្ត និងការគាំទ្រជាញឹកញាប់គឺជាបញ្ហាដែលត្រូវប្រឈមដោះស្រាយ។

## ក្រៅសមត្ថកិច្ចរបស់សាលា : កុមារតូច និងការអប់រំមនុស្សចាស់

ភស្តុតាងភាគច្រើនពីប្រទេសដែលលើកឡើងខាងលើយកចិត្តទុកដាក់ទៅលើប្រព័ន្ធសាលារៀន។ ការយកចិត្តទុកដាក់តិចតួចធ្វើឡើងទាក់ទងនឹងគុណវិស័យនៃទិសដៅអប់រំសម្រាប់ទាំងអស់គ្នាពីរផ្សេងទៀតគឺ ការថែទាំ និង អប់រំកុមារតូច (ECCE) និងជំនាញអក្ខរកម្ម និងបំណិនជីវិត។ តើមានអ្វីខ្លះដែលគេអាចនិយាយបានអំពីគុណភាពនៃកម្មវិធីទាំងពីរនេះ ហើយតើកម្មវិធីទាំងពីរនេះអាចធ្វើការកែលំអបានទេ? បើទោះបីជាការប្រៀបធៀបកម្មវិធី ECCE មានការលំបាក ការស្រាវជ្រាវបង្ហាញថា កម្រិតវប្បធម៌របស់គ្រូ សកម្មភាពសិក្សាតាមក្រុមតូចៗ និងភាពសម្បូរបែបខាងឧបករណ៍ និងសម្ភារមានមុខងារវិជ្ជមាន។ ការថែទាំកុមារបានប្រសើរនៅមុនពេលចូលរៀនគឺមានទំនាក់ទំនង ជាមួយនឹងការអភិវឌ្ឍគំនិត និងសង្គម។ ខ្លឹមសាររឿងជោគជ័យភាគច្រើនកើតចេញពីប្រទេសមានប្រាក់ចំណូលមធ្យម និងខ្ពស់ ប៉ុន្តែប្រទេសណេប៉ាល់ និងឥណ្ឌា គឺជាករណីលើកលែងដោយសារប្រទេសទាំងពីរនេះមានកម្មវិធីចំណាយតិច ប៉ុន្តែមានឥទ្ធិពលវិជ្ជមានខ្លាំងក្លាបង្គួរលើកុមារ និងគ្រួសារកុមារ។ នៅក្នុងប្រទេសទាំងនេះដែលធានាសម្រេចសកលកម្មអប់រំបឋមសិក្សាគឺជាឧបសគ្គដ៏ធំ ដូច្នេះវិធានការចំណាយលុយតិចគឺជាជំរើសមួយដ៏ប្រសើរ។

**ការថែទាំកុមារមត្តេយ្យឲ្យបានជិតដល់នឹងជួយអភិវឌ្ឍន៍បញ្ញាស្មារតី និងអភិវឌ្ឍន៍សង្គម**

ក្នុងអំឡុងពេលជាង ៤០ ឆ្នាំកន្លងទៅនេះ កម្មវិធីអក្ខរកម្មបានកែប្រែពីវិធីសាស្ត្រ "ការសិក្សាមួយមុខអាចបំរើគ្រប់មុខ" ដែលពីដំបូងជាគំនិត "អក្ខរកម្មដ៏សំខាន់" ដែលជំរុញដោយអង្គការ UNESCO នៅទសវត្សរ៍ ១៩៩០ ដែលជួយទ្រទ្រង់ដល់កម្មវិធីសម្រាប់ក្រុមវិជ្ជាជីវៈជាក់លាក់។ វិធីសាស្ត្របន្តបន្ទាប់ទៀតបានបង្កើតឡើងដោយផ្អែកលើខ្នាតគំរូខាងលើដោយដាក់បញ្ចូលខ្លឹមសារទាំងឡាយស្ដីពីសុខភាព បរិស្ថាន អាហារូត្ថម្ភ អនាម័យ និងការថែទាំងសុខភាព។ ការមានគ្រូបង្រៀនដែលមានជំនាញភ្ជាប់គំនិតធ្វើឲ្យសិស្សយល់ និងមានចំណេះដឹងខ្ពស់លើមុខវិជ្ជាគឺជាកត្តាសម្រេចជោគជ័យ។ តាមវប្បធម៌មួយចំនួន ការអប់រំមនុស្សពេញវ័យទទួលលទ្ធផលប្រសើរបំផុតនៅពេលគ្រូបង្រៀន និងសិស្សមានភេទដូចគ្នា។ ការបណ្ដុះបណ្ដាលដោយសង្ខេបឡើងវិញម្ដងហើយម្ដងទៀត ការវាយតម្លៃការសិក្សាទៀងទាត់ និងចេញវិញ្ញាបនប័ត្រ គឺមានទំនាក់ទំនងគ្នាជាមួយនឹងកម្មវិធីលើកកំពស់គុណភាព។ ភស្តុតាងទាំងឡាយបញ្ជាក់ថា មនុស្សប្រមាណ ៨០% ដែលចុះឈ្មោះចូលរៀនក្នុងថ្នាក់អក្ខរកម្ម ដែលមានការគ្រប់គ្រងល្អ មនុស្សបានរៀនរហូតបញ្ចប់វគ្គសិក្សា។ ការសិក្សាដែលរៀបចំឡើងសម្រាប់រយៈពេល ៤០០ ម៉ោងអាចធ្វើឲ្យមនុស្សចាស់ ដែលមិនបានចូលរៀនសោះ និងមិនចេះអក្សរអាចមានកម្រិតអក្ខរកម្មជាមូលដ្ឋាន។



© AMI VITALE/PANOS/EDITINGSERVER.COM

សកម្មភាពដ៏ស្វាហាប់របស់គ្រូ : ក្រោយពីឆ្លងកាត់ឧបសគ្គសង្គមដ៏លំបាក ឡាលីតា នារីម្នាក់មកពីវណ្ណៈទាបកំពុងរីករាយបង្រៀនគណិតដល់សិស្សស្រីនៅក្នុងភូមិរបស់គាត់នៅឃុំកូប្រា។

ជំពូក ៣

# រង្វាយតម្លៃអំពីភាពជឿនលឿនឈានទៅសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា

- វិសមភាពយេនឌ័រនៅគ្រប់កម្រិតទាំងអស់
- គម្លាតប្រាំចំណុចនិយាពីរយៈពេលចូលរៀនក្នុងសាលា
- រវាងប្រទេសអ្នកក្រ និងអ្នកមាន
- គ្រូបង្រៀន : វិបត្តិខ្វះសមត្ថភាព
- បញ្ហាសិស្សរៀនមិនសូវបានលទ្ធផលល្អមាននៅគ្រប់កន្លែង
- សន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នា

ការវាយតម្លៃពីផ្នែកចម្រុះនៃគុណភាពអប់រំនៅតែរាំងស្ទះដោយសារកង្វះសន្ទស្សន៍ស្តង់ដា។ ថ្វីបើតួលេខមិនអាចឆ្លុះបញ្ចាំងឲ្យបានគ្រប់គ្រាន់ពីភាពស្មុគស្មាញនៃដំណើរការរៀនសូត្រក៏ដោយ ក៏សន្ទស្សន៍ភាគច្រើនដែលមានសម្រាប់ប្រើក្នុងការវាយតម្លៃគុណភាពគឺទាក់ទងនឹងសន្ទស្សន៍គុណវិស័យ។ សន្ទស្សន៍ទាំងនោះអាចឆ្លុះបញ្ចាំងឲ្យឃើញពីកម្រិតគុណភាពមួយ បើទោះបីជាគុណភាពពុំមានលក្ខណៈពេញលេញក៏ដោយ។ ជំពូកនេះលើកមកនិយាយអំពីដំណើរការរីកចម្រើនរួមឈានទៅសម្រេចគោលដៅទាំង ៦ នៃការអប់រំសម្រាប់ទាំងអស់គ្នា ដោយយកចិត្តទុកដាក់លើគុណភាពអប់រំ តាមរយៈការឆ្លុះបញ្ចាំងពីកត្តាមួយចំនួនទាក់ទងនឹងសាលារៀន និងលទ្ធផលនៃការសិក្សា ដូចជាការចំណាយប្រាក់របស់រដ្ឋាភិបាលទៅលើការអប់រំ អត្រាផលធៀបគ្រូ/សិស្ស កម្រិតវប្បធម៌របស់គ្រូបង្រៀន រយៈពេលនៃការសិក្សាក្នុងសាលារបស់សិស្ស និងពិន្ទុតេស្ត។ ជារួមការរីកចម្រើនក្នុងការសម្រេចគោលដៅត្រូវជាកាមានរៀបរាប់ដោយសង្ខេបតាមរយៈសន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នា ដែលមានបង្ហាញក្នុងរបាយការណ៍ត្រួតពិនិត្យការអប់រំសម្រាប់ទាំងអស់គ្នាជាសកលឆ្នាំ ២០០៣។

## សកលកម្មអប់រំបឋមសិក្សា : ការប្រែប្រួលមិនសមហេតុផល

ការពន្យារពេលចូលរៀននៅសាលាគឺជាសកម្មភាពជួយកាត់បន្ថយយឺតៗនៃចំនួនសិស្សគ្រប់អាយុចូលរៀននៅបឋមសិក្សាដែលមិនបានចូលរៀនពីចំនួន ១០៦.៩ លាននាក់នៅឆ្នាំ ១៩៩៨ ទៅប្រមាណជា ១០៣.៥ លាននាក់នៅ ឆ្នាំ ២០០១។ អត្រានៃការធ្លាក់ចុះនេះពុំទាន់មានលក្ខណៈគ្រប់គ្រាន់ដើម្បីធានាសម្រេចសកលកម្មអប់រំបឋមសិក្សាឲ្យបានមុន ឬត្រឹមឆ្នាំ ២០១៥ ទេ។ សិស្សស្រីមាន ចំនួន ៥៧% នៃចំនួនសិស្សសរុប (ច្រើនជាង ៦០% នៅរដ្ឋអារ៉ាប់ និង អាស៊ីខាងត្បូង និងខាងលិច) ដែលនៅក្នុងឆ្នាំ ១៩៩៨ មានតែចំនួន ៥៩,៥%ប៉ុណ្ណោះ។

ក្រាហ្វ : ៣.១ អត្រាចុះឈ្មោះចូលរៀនពិត និងអត្រាចុះឈ្មោះចូលរៀនសរុបនៅបឋមសិក្សា នៅប្រទេសដែលមានអត្រាចុះឈ្មោះចូលរៀនពិតក្រោម ៩៥%– ២០០១




ប្រភព និងកំណត់សំគាល់ : អានជំពូក ៣ របាយការណ៍អប់រំសម្រាប់ទាំងអស់គ្នា

អត្រាចុះឈ្មោះចូលរៀនពិត (NER) ស្ទើរតែក្លាយទៅជាសូចនាករណ៍មួយបញ្ជាក់ពីគុណភាពនៃការអប់រំដោយសារតែអត្រានេះឆ្លុះបញ្ចាំងពីវិសាលភាពដែលក្នុងនោះកុមារដែលស្ថិតក្នុងក្រុមអាយុចូលរៀនផ្លូវការធ្វើការចុះឈ្មោះចូលរៀន។ អត្រាចុះឈ្មោះចូលរៀនពិតមិនរាប់បញ្ចូលកុមារ ដែលបានចុះឈ្មោះចូលរៀន ប៉ុន្តែស្ថិតនៅក្រៅក្រុមអាយុចូលរៀនផ្លូវការដោយសារការចុះឈ្មោះចូលរៀនមុន ឬយឺតយ៉ាវ ឬក៏ត្រួតថ្នាក់នោះទេ។

ភាពខុសគ្នានៅថ្នាក់តំបន់មានកម្រិតខ្ពស់។ ក្នុងប្រទេសនៅអនុតំបន់សាហារ៉ាអាព្រិចជាច្រើន ប្រទេសនៅអារ៉ាប់មួយចំនួន និងប្រទេសប៉ាគីស្ថាន អត្រាចុះឈ្មោះចូលរៀនពិតគឺស្ថិតនៅក្រោម ៧០%។ អត្រាចុះឈ្មោះចូលរៀនពិតនៅក្នុងប្រព័ន្ធអប់រំក្នុងប្រទេសជាច្រើននៅអឺរ៉ុបកណ្ដាល និងខាងកើតស្ថិតនៅចន្លោះរវាង ៧០% ទៅ ៩០%។ ការចូលរៀនក្នុងសាលាបឋមសិក្សារបស់ក្មេងស្រីនៅទាបជាងក្មេងប្រុសយ៉ាងខ្លាំងក្នុងប្រទេសចំនួន ៧១ ក្នុងចំណោម ប្រទេសចំនួន ១៧៥។ ប្រទេសទាំងអស់ លើកលែងតែប្រទេសបីប៉ុណ្ណោះ ដែលមានអត្រាសមភាពយេនឌ័រគិតជាតួលេខក្រោម ០,៩០ គឺជាប្រទេសស្ថិតនៅអនុតំបន់សាហារ៉ាអាព្រិច (ពោលគឺអាព្រិចខាងលិច) រដ្ឋនៅអារ៉ាប់ អាស៊ីខាងត្បូង និងខាងលិច។

កត្តានានា ដូចជាតម្លៃចំណាយសម្រាប់សិស្សចុះឈ្មោះចូលរៀន និងចម្ងាយពីផ្ទះទៅសាលាជាញឹកញាប់បង្កឲ្យមានការចុះឈ្មោះចូលរៀនយឺតយ៉ាវ។ នៅក្នុងអនុតំបន់សាហារ៉ានៃទ្វីបអាព្រិច កុមារប្រមាណជា ២០% ទៅ ៤០% ដែលបានចូលរៀនថ្នាក់ទី ១ មានអាយុច្រើនជាងអាយុត្រូវចូលរៀនផ្លូវការចំនួនពីរ ឬបីឆ្នាំ។ ជាងនេះទៅទៀត ប្រព័ន្ធអប់រំពេលខ្លះខិតខំទទួលសិស្សដល់ចំនួនកំណត់ ជាពិសេសនៅក្នុងប្រទេសទាំងឡាយណា ដែលមានអត្រាចុះឈ្មោះសរុប (GER) ស្ថិតនៅក្រោម ១០០% ហើយប្រទេសច្រើនជាង ៤០ មានអត្រាចុះឈ្មោះចូលរៀនសរុបនៅក្រោម ១០០% និងអត្រាចុះឈ្មោះពិតនៅក្រោម ៩០% ដែលជាការឆ្លុះបញ្ចាំងឲ្យឃើញពីតម្រូវការលើកកំពស់សមត្ថភាពរបស់ប្រព័ន្ធអប់រំ (ក្រាហ្វ ៣.១)។

២. ផលធៀបតម្លៃយេនឌ័រគិតជាតួលេខរវាងស្រី និងប្រុស។ សន្ទស្សន៍សមភាពយេនឌ័រគិតជាតួលេខចន្លោះពី ០.៩៧ និង ១.០៣ បង្អួលបង្ហាញពីតួលេខជិតស្មើគ្នារវាងភេទទាំងពីរ។

៣. អត្រាសិស្សចុះឈ្មោះចូលរៀនសរុបជាសូចនាករណ៍បង្អួលបង្ហាញអំពីសមត្ថភាពរបស់សាលាតាមទិន្នន័យបរិវិស័យ។ អត្រានេះជាផលធៀបចំនួនសិស្សចុះឈ្មោះចូលរៀននៅកម្រិតណាមួយ (ឧ.បឋមសិក្សា) ដោយមិនប្រកាន់អាយុ ប្រៀបធៀបនឹងចំនួនសិស្សសរុបរៀននៅកម្រិតនោះ (ឧ.អាយុពី ៦ – ១២ ឆ្នាំ)។

ការបញ្ចប់ការអប់រំនៅសាលាបឋមសិក្សានៅតែជាបញ្ហាដ៏ចំបងមួយ។ នៅប្រទេសដែលមានប្រាក់ចំណូលទាប កុមារជាច្រើនត្រូវបង្ខំចិត្តបោះបង់ចោលសាលាដោយសារការចំណាយ បរិយាកាសក្នុងថ្នាក់រៀនមិនសមស្រប ឬដោយសារតែតម្រូវការឲ្យជួយរកប្រាក់ចំណូលសម្រាប់គ្រួសារ។ ទោះបី ជាអត្រាសិស្សរៀនបន្តពីថ្នាក់ទី ១ ដល់ទី ៥ បានកើនឡើងនៅក្នុងប្រទេសជាច្រើនក្នុងទសវត្សរ៍ ១៩៩០ (ហើយនៅ ក្នុងករណីមួយចំនួនមានការកើនឡើងរហូតដល់ជាង ១០ ភាគរយពីឆ្នាំ ១៩៩៨ ទៅឆ្នាំ ២០០១) ប្រទេស ៣០ ក្នុងចំណោមប្រទេស ៩១ មិនបានសម្រេចអត្រា ចុះឈ្មោះចូលរៀនចំនួន ៧៥% នេះបើយោងតាមទិន្នន័យដែលមានស្រាប់ ហើយ មានអត្រាចុះឈ្មោះចូលរៀនទាបជាង ៦៦% នៅក្នុងប្រទេសអនុតំបន់សាហារ៉ា អាព្រិចចំនួនពាក់កណ្ដាល (ក្រាហ្វ ៣.២)។ ការធ្លាក់ចុះដ៏ខ្លាំងក្លាក្នុងប្រទេសជាច្រើនបានឆ្លុះបញ្ចាំងឲ្យឃើញពីការធ្លាក់ចុះគុណភាពនៃការអប់រំ។

**នៅប្រទេសដែលមានចំណូលទាបជាច្រើន កុមារត្រូវបង្ខំចិត្តបោះបង់ចោលសាលាដោយសារការចំណាយ បរិយាកាសក្នុងថ្នាក់រៀនមិនសមស្រប ឬដោយសារតម្រូវការឲ្យជួយរកប្រាក់ចំណូលសម្រាប់គ្រួសារ**

## ការអប់រំនៅមធ្យមសិក្សា និងសាកលវិទ្យាល័យៈ លំនាំពីរ៉ាមីតចង្អៀត

ក្នុងខណៈពេលដែលប្រទេសជាច្រើន (ប្រមាណជា ១៤៤ ប្រទេស)បានប្ដេជ្ញាប្រែក្លាយការអប់រំមធ្យមសិក្សាទៅជាកាតព្វកិច្ច សិស្សបញ្ចប់សាលាបឋមសិក្សាជាច្រើនជាញឹកញាប់មិនបន្តការរៀនសូត្ររហូតដល់មធ្យមសិក្សាទេ ជាពិសេសសិស្សបឋមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍ។ នៅឆ្នាំ ២០០១ អត្រាចុះឈ្មោះចូលរៀនសរុបជាមធ្យមក្នុងកម្រិតមធ្យមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍគឺមានតែ ៥៧% ដែលចំនួននេះបើប្រៀបធៀបជាមួយនឹងប្រទេសអភិវឌ្ឍមានតែចំនួនពាក់




**ក្រាហ្វ ៣.២ : អត្រាសិស្សរៀនបន្តរហូតចប់ថ្នាក់ទី ៥ និងចំនួនថ្នាក់ដែលមានសិស្សបោះបង់ចោលសាលានៅបឋមសិក្សាឆ្នាំ ២០០១**




តារាងនេះបង្ហាញតែប្រទេសដែលមានអត្រាសិស្សបន្តរៀនចប់ថ្នាក់ទី ៥ ក្រោម ៨០%
ប្រភព និងកំណត់សំគាល់ : អានជំពូក ៣ របាយការណ៍អប់រំសម្រាប់ទាំងអស់គ្នា

កណ្ដាលប៉ុណ្ណោះ។ គម្លាតនេះកាន់តែធំឡើងនៅកម្រិតសាកលវិទ្យាល័យដែល អត្រាចុះឈ្មោះចូលរៀនសរុបមានចំនួន ៥៥%ក្នុងប្រទេសអភិវឌ្ឍ និងចំនួន ១១% ក្នុងប្រទេសកំពុងអភិវឌ្ឍ។ រវាងពីឆ្នាំ ១៩៩៨ និង ២០០១ អត្រាចុះឈ្មោះចូលរៀនសរុបកើនឡើងជាង ២% ក្នុងប្រទេស ៨០ ក្នុងចំណោមប្រទេស ១៣១ ដែលចំនួននេះបានមកពីទិន្នន័យនៅកម្រិតមធ្យមសិក្សា និងក្នុងប្រទេស ៥៦ ក្នុងចំណោមប្រទេស ៩៥ នៅកម្រិតសាកលវិទ្យាល័យ។ វិសមភាពយេនឌ័រគិតជាតួលេខ

កើនឡើងនៅគ្រប់កម្រិតអប់រំទាំងអស់។ ទិន្នន័យដែលប្រមូលបាននៅតាមកម្រិតអប់រំទាំង ៣ កម្រិតក្នុងប្រទេសកំពុងអភិវឌ្ឍ ៨៣ ប្រទេសចំនួនពាក់កណ្តាលបានសម្រេចជោគជ័យលើសមភាពយេនឌ័រគិតជាតួលេខក្នុងការអប់រំបឋមសិក្សា ប៉ុន្តែតិចជាង ១ ភាគ ៥ ក្នុងកម្រិតមធ្យមសិក្សា និងមានតែ ៤ ប្រទេសប៉ុណ្ណោះមានសមភាពយេនឌ័រនៅសាកលវិទ្យាល័យ។

## រយៈពេលចូលរៀនក្នុងសាលា : គម្លាត ៥ ចំណុចរវាងប្រទេសអ្នកមាន និងអ្នកក្រ

ការបូកបញ្ចូលគ្នានៃការចុះឈ្មោះចូលរៀនគិតតាមអាយុនៅកម្រិតទាំងបីនៃការអប់រំ តើមនុស្សម្នាក់ៗអាចរំពឹងថានឹងស្ថិតនៅសាលារៀនបានរយៈពេលយូរប៉ុន្មាន? ការគិតគូរពីរយៈពេលនេះគឺជាការចាំបាច់ចំពោះវិធានការរំពឹងទុកនៃការចំណាយពេលវេលាក្នុងសាលារៀនដែលគិតបញ្ចូលទាំងការត្រួតថ្នាក់ផងដែរ។ កុមារនៅក្នុងពិភពលោកបានចំណាយពេលថែមមួយឆ្នាំនៅក្នុងសាលារៀននៅអំឡុងទសវត្សរ៍ ១៩៩០ ឡើងរហូតដល់ ៩,២ ឆ្នាំនៅបឋមសិក្សា និងមធ្យមសិក្សា និង ១,១ ឆ្នាំ នៅក្រោយការអប់រំមធ្យមសិក្សាដែលមានចំនួនឆ្នាំសរុប ១០,៣ ឆ្នាំ។ ជាមធ្យមកុមារម្នាក់នៅអនុតំបន់សាហារ៉ាអាព្រិចនឹងទទួលការសិក្សានៅសាលាបឋម សិក្សា និង មធ្យមសិក្សាតិចជាងកុមារនៅអឺរ៉ុប និងអាមេរិកចំនួន ៥ ទៅ ៦ ឆ្នាំ។

**កុមារមួយនាក់នៅអាព្រិចសាប់សាហារាអាចមានសង្ឃឹមទទួលបានការអប់រំបឋមសិក្សា និងមធ្យមសិក្សាពី ៥ ទៅ ៦ ឆ្នាំច្រើនជាងកុមារម្នាក់នៅអឺរ៉ុបខាងលិច ឬអាមេរិក**

ការបាត់បង់ឱកាសអប់រំធ្ងន់ធ្ងរនៅកើតមានឡើងនៅអាស៊ីខាងត្បូង និងខាងលិច និងរដ្ឋអារ៉ាប់មួយចំនួនដែលមិនទាន់បានសម្រេចសកលកម្មអប់រំបឋមសិក្សានៅឡើយ។ ភាពខុសគ្នារវាងប្រទេសដែលមានការរំពឹងទុកនៃការចំណាយពេលវេលានៅសាលាខ្ពស់បំផុត និងទាបបំផុតគឺមានចំនួនរហូតដល់៥ដង។ ការកំណត់ក្រុមដែលនៅតែគ្មានឱកាសចូលរៀននៅសាលាបឋមសិក្សាបន្ទាប់ពីមានការពង្រីកការផ្គត់ផ្គង់នៃការអប់រំមធ្យមសិក្សាគឺជាភារកិច្ចបន្ទាន់នៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន ដូចជាប្រទេសនៅអាមេរិកឡាទីន ការាប៊ីន អាស៊ីខាងកើត និងប៉ាស៊ីហ្វិក។

## ការបង្ហាត់បង្រៀន : គឺជាមុខរបរប្រកបដោយភាពធុញថប់ក្នុងចិត្ត

ដូចបានធ្វើការកត់សំគាល់ជាញឹកញាប់នៅក្នុងរបាយការណ៍នេះគ្រូបង្រៀនមានឥទ្ធិពលខ្លាំងក្លាបំផុតទៅលើការរៀនសូត្ររបស់សិស្ស។ ទិន្នន័យដែលមានស្រាប់បញ្ជាក់ថា គ្រូនៅសាលាបឋមសិក្សាភាគច្រើនមានកង្វះខាតកម្រិតវប្បធម៌ការបណ្តុះបណ្តាល និងយល់ដឹងជ្រៅជ្រះពីខ្លឹមសារនៃការអប់រំ ជាពិសេសគ្រូបង្រៀនក្នុងប្រទេសកំពុងអភិវឌ្ឍ។ ស្តង់ដាកម្រិតវប្បធម៌ជាតិសម្រាប់គ្រូបឋមសិក្សាមានចាប់ពីការអប់រំក្នុងសាលារៀនពី ១២ ឆ្នាំដល់១៧ ឆ្នាំក្នុងប្រទេសចំនួន ២៦ នៃអនុតំបន់សាហារ៉ាអាព្រិច ដែលបានស្រាវជ្រាវនៅឆ្នាំ ២០០១។ គ្រូបង្រៀនតិចជាង ១០%នៅក្នុងប្រទេសមួយចំនួនតូចបានឆ្លើយតបទៅនឹងស្តង់ដាអប្បបរមានៃការអប់រំអនុវិទ្យាល័យ ហើយមានប្រទេសជាច្រើនមិនបានឆ្លើយតបទៅនឹងស្តង់ដាដែលបានកំណត់នៅតាមសាលាមធ្យមសិក្សាទេ។ ទាក់ទងនឹងការយល់ដឹងស៊ីជម្រៅរបស់គ្រូបង្រៀនទៅលើកម្មវិធីសិក្សា ការស្រាវជ្រាវថ្មីមួយក្នុងប្រទេសចំនួន ៧ នៅអាព្រិចខាងត្បូងបានឲ្យដឹងថា គ្រូបង្រៀនគណិតវិទ្យានៅសាលាបឋមសិក្សាមានចំណេះដឹងតែទៅលើលេខនព្វន្តមូលដ្ឋានប៉ុណ្ណោះ ហើយតាមពិត គ្រូទាំងនោះប្រលងគណិតវិទ្យាបានពិន្ទុទាបជាងមុខវិជ្ជាផ្សេង។

គ្រូបង្រៀនសាលាបឋមសិក្សាថ្មីៗមួយចំនួនដែលមានចំណេះដឹងឆ្លើយតបទៅនឹងស្តង់ដាជាតិបានធ្លាក់ចុះនៅប្រទេសជាច្រើនក្នុងអនុតំបន់សាហារ៉ាអាព្រិច។ ឧទាហរណ៍ គ្រូ៣០%ប៉ុណ្ណោះដែលបានបង្រៀននៅឆ្នាំដំបូងមានចំណេះដឹងឆ្លើយតបទៅនឹងស្តង់ដាជាតិក្នុងប្រទេសហ្កាមបៀរ។ ចំនួនភាគរយកាន់តែធ្លាក់ចុះតទៀតក្នុងប្រទេសបូតស្វាណា (១០%) ឡេសូថូ (១១%) និងឆាដ (១៩%) ដែលស្តង់ដានៃប្រទេសទាំងនោះគឺការអប់រំមធ្យមសិក្សា និងប្រទេសតូហ្គោ (២%) ហ្គីនេប៊ីសាវ (១៥%) និងកាមារ៉ូន (១៥%) ដែលជាទូទៅស្តង់ដានៃប្រទេសទាំងនេះគឺអនុវិទ្យាល័យ។ និន្នាការនេះអាចឆ្លុះបញ្ចាំងពីការកើនឡើងនៃការជ្រើសរើសគ្រូបង្រៀន ដោយមិនបានពិចារណាទៅលើកម្រិតវប្បធម៌ចាំបាច់ដើម្បីឆ្លើយតបទៅនឹងសម្ពាធដែលកើតឡើងដោយសារការចុះឈ្មោះចូលរៀននៅគ្រប់កម្រិតអប់រំមានការកើនឡើងច្រើន។ លើសនេះទៀត ការបែងចែកគ្រូបង្រៀនពុំមានភាពស្មើគ្នានៅទូទាំងប្រទេស ដោយមានតំបន់ដាច់ស្រយាលមួយចំនួន ជាធម្មតាមានគ្រូដែលពុំមានការបណ្តុះបណ្តាលខ្ពស់។ ស្ថានភាពដូចនោះធ្វើឲ្យកាន់តែអាក្រក់ដល់កាលៈទេសៈលំបាកមួយចំនួន ដូចជាប្រទេសទាំងឡាយដែលមានជម្លោះ ឬទើបតែងើបចេញពីជម្លោះ។

ទោះបីជាទិន្នន័យត្រូវបានប្រមូលមិនតាមលំដាប់លំដោយក៏ដោយ ក៏ការសិក្សាស្រាវជ្រាវព្រាវៗក្នុងប្រទេសជាច្រើនបញ្ជាក់ថា អវត្តមាន និងកង្វះគ្រូបង្រៀននៅតែជាបញ្ហារ៉ាំរ៉ៃមួយដដែល។ តម្រូវការដើម្បីថែរក្សាការងារទីពីរ កង្វះខាតការថែទាំស្តង់ដារវិជ្ជាជីវៈ និងកង្វះខាតការគាំទ្រពីស្ថាប័នអប់រំគឺជាបុព្វហេតុទូទៅ។

ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍គឺកំពុងតែធ្វើឲ្យធ្លាក់ចុះយ៉ាងធ្ងន់ធ្ងរនូវការផ្តល់ការអប់រំប្រកបដោយគុណភាព នាំឲ្យមានអវត្តមានគ្រូបង្រៀន និងមានផលប៉ះពាល់ដល់ការអប់រំ។ ប្រទេសហ្កាមប៊ីបានប៉ាន់ស្មានថា គ្រូបឋមសិក្សាចំនួន ៨១៥ នាក់ស្លាប់ដោយសារជំងឺអេដស៍នៅឆ្នាំ ២០០១ ដែលត្រូវជា ៥៤% នៃគ្រូដែលបានទទួលការបណ្តុះបណ្តាលនៅឆ្នាំនោះ។ ក្រសួងសុខាភិបាលប្រទេសកេនយ៉ាបានអះអាងថា មេរោគអេដស៍/ជំងឺអេដស៍បានធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រសិទ្ធភាពនៃវិស័យអប់រំដែលធ្វើឲ្យមានការកើនឡើងនៃអត្រាស្លាប់ក្នុងចំណោមគ្រូបង្រៀន និងប៉ះពាល់ដល់វិស័យអប់រំក្នុងអំឡុងពេលមួយទសវត្សរ៍កន្លងទៅនេះ។ ដោយសារការរាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ក្នុងប្រទេសជាច្រើន (ជាពិសេសប្រទេសនៅអឺរ៉ុបខាងកើត និងអាស៊ី) មេរោគ/ជំងឺនេះអាចជ្រាបចូលទៅវាយប្រហារដល់ប្រព័ន្ធអប់រំកាន់តែខ្លាំងក្លាឡើង។

ផលធៀបសិស្ស និងគ្រូបង្រៀនត្រូវបានប្រើសម្រាប់ឆ្លុះបញ្ចាំងពីគុណភាពអប់រំ។ ទោះបីជាផលប៉ះពាល់ទៅលើលទ្ធផលនៃការអប់រំនៅតែជាប្រធានបទសម្រាប់ពិភាក្សាក្តី ក៏ការអង្កេតបង្ហាញថា សិស្សក្នុងថ្នាក់រៀននៃសាលាបឋមសិក្សាក្នុងប្រទេសកំពុងអភិវឌ្ឍមានចំនួនច្រើន (គ្រូម្នាក់បង្រៀនសិស្ស ៦០ នាក់) ដែលចំនួននេះមិនសមស្របដល់ការរៀនសូត្រឡើយ។ នៅក្នុងប្រទេសដែលមានអត្រាផលធៀបគ្រូ និងសិស្សខ្ពស់បំផុតស្ទើរតែគ្មានសិស្សចំនួន ១ ភាគ ៣ ដែលបានចូលរៀនបឋមសិក្សា រៀនរហូតដល់ថ្នាក់ទី ៥។ អត្រាផលធៀបគ្រូ និងសិស្សមានការកើនឡើងក្នុងពេលមួយទសវត្សរ៍កន្លងទៅនេះក្នុងប្រទេសទាំងឡាយដែលអត្រាចុះឈ្មោះចូលរៀនពិតមានការកើនឡើង ជាពិសេស នៅអនុតំបន់សាហារ៉ាអាព្រិច និងអាស៊ីខាងត្បូង និងខាងលិច។ ដូចនេះ ចំនួនគ្រូនៅជាបញ្ហាចោទមួយក្នុងប្រទេសដែលប្រព័ន្ធអប់រំបឋមសិក្សាកើនឡើងច្រើន។ គុណភាពនៃការអប់រំនឹងមានភាពមិនច្បាស់លាស់ ប្រសិនបើតម្រូវការចូលបង្រៀនរបស់គ្រូមានការបន្ធូរបន្ថយ ឬបន្ទុកការងាររបស់គ្រូបង្រៀនមានការកើនឡើង។

## ការផ្ដល់មូលនិធិ : តើរដ្ឋាភិបាលបានប្ដេជ្ញាចិត្តប៉ុន្មាន?

ការចំណាយរបស់រដ្ឋាភិបាលសម្រាប់ការអប់រំគឺជាសូចនាករណ៍ដ៏ល្អមួយបញ្ជាក់ពីការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីគុណភាពអប់រំ បើទោះបីជាមានកង្វះខាតទិន្នន័យពិស្ដារទាក់ទងនឹងអគារ និងសម្ភារបំពាក់ក្នុងអគារ ព្រមទាំងសម្ភារបង្រៀន និងរៀនក៏ដោយ។ លទ្ធផលពីកម្មវិធីសម្រាប់វាយតម្លៃសិស្សអន្តរជាតិ (PISA) បង្ហាញឲ្យឃើញថា សិស្សក្នុងប្រទេសទាំងឡាយណាដែលធ្វើវិនិយោគធនធានច្រើនទៅលើការអប់រំទទួលបានជំនាញអក្ខរកម្មល្អប្រសើរ។ ទំនាក់ទំនងនេះមានបង្ហាញយ៉ាងច្បាស់លាស់ក្នុងប្រទេសកំពុងអភិវឌ្ឍខ្លះ ដូចជាប្រទេសទាំងឡាយនៅអឺរ៉ុបកណ្ដាល និងខាងកើត និងប្រទេសមួយចំនួនទៀតនៅអឺរ៉ុបខាងលិចដែលមានកម្រិតនៃការចំណាយទាប។ លទ្ធផលនៃការសិក្សា PISA ផ្សេងទៀតបង្ហាញថា ធនធានអាចមានឥទ្ធិពលខ្លាំងទៅលើលទ្ធផលនៃការអប់រំនៅពេលការចំណាយដំបូងមានកម្រិតទាប ប៉ុន្តែឥទ្ធិពលនោះត្រូវបញ្ឈប់ទៅវិញនៅពេលមានការកើនឡើងនៃការចំណាយ។

ការចំណាយសាធារណៈលើការអប់រំឆ្លុះបញ្ចាំងឲ្យឃើញពីសមាមាត្រនៃផលិតផលក្នុងស្រុកសរុបក្នុងប្រទេសអ្នកមានច្រើនជាងប្រទេសក្រីក្រ ដែលប្រទេសអ្នកមានទាំងនោះបានសម្រេចគោលដៅការអប់រំសម្រាប់ទាំងអស់គ្នា (មធ្យមភាគតំបន់ : ៥,២% នៅអាមេរិកខាងជើង និងអឺរ៉ុបខាងលិច)។ នេះតម្រូវឲ្យមានការពង្រីកប្រព័ន្ធអប់រំដែលមានកង្វះខាតធនធានស្រាប់ ពោលគឺកង្វះខាតនៃការគ្របដណ្ដប់របស់ប្រព័ន្ធអប់រំទាំងនោះ (មធ្យមភាគតំបន់ : ៣,៣% ក្នុងអនុតំបន់សាហារ៉ាអាព្រិច និង៣,៩% នៅអាស៊ីខាងកើត និងប៉ាស៊ីហ្វិក។ គ្មានព័ត៌មានទាក់ទងនឹងបញ្ហាចំណាយក្នុងប្រទេសអាស៊ីខាងត្បូង និងខាងលិច និងអារ៉ាប់ឡើយ)។


© X. DESMIER/RAPHO

មាតាបិតាចេះអក្សរច្រើនចង់អប់រំកូនឲ្យចេះអក្សរ : ឪពុកមួយនាក់កំពុងរៀនអាន និងសរសេរនៅប្រទេសហ្គីនេ

ក្រាហ្វ ៣.៣ បង្ហាញពីការប្រែប្រួលនៃការចំណាយពិតប្រាកដក្នុងប្រទេសមួយចំនួននៅឆ្នាំ ១៩៩៨ និង ២០០១។ ជាទូទៅ ការចំណាយពុំមានការប្រែប្រួលឡើយក្នុងប្រទេសអភិវឌ្ឍក្នុងពេលនោះ ប៉ុន្តែប្រទេសកំពុងអភិវឌ្ឍមួយចំនួនតូចបានបង្កើនការចំណាយយ៉ាងច្រើន ដូចជាប្រទេសនៅអាស៊ីខាងកើត និងអាស៊ីប៉ាស៊ីហ្វិក អាមេរិកឡាទីន និងការីប៊ីន។ ទោះជាយ៉ាងនេះក៏ដោយ ប្រទេសធំៗមួយចំនួនបានកាត់បន្ថយការចំណាយយ៉ាងសម្បើមដែលរួមមានប្រទេស ហ្វីលីពីន (ចំនួន ២៤%) និង ប្រទេសឥណ្ឌូនេស៊ី (ចំនួន ៨%)។

**ក្រាហ្វ ៣.៣ : បំរែបំរួលនៃការចំណាយសរុបក្នុងវិស័យអប់រំតាមការដាក់ស្ដែងឆ្នាំ ១៩៩៨ – ២០០១**




ប្រភព និងកំណត់សំគាល់ : អានជំពូក ៣ របាយការណ៍អប់រំសម្រាប់ទាំងអស់គ្នា

ការជជែកនានាបន្តធ្វើឡើងទាក់ទងនឹងការចំណាយលើប្រាក់ខែគ្រូបង្រៀនក្នុងកម្រិតសមស្របដែលការចំណាយលើប្រាក់ខែ គឺជាការចំណាយច្រើនបំផុត ជាពិសេស ក្នុងប្រទេសកំពុងអភិវឌ្ឍដែលជាញឹកញាប់ ការចំណាយលើសៀវភៅសិក្សា និងសម្ភារបង្រៀនផ្សេងៗទៀតក្នុងប្រទេសទាំងនោះមានចំនួនស្ទើរតែមិនដល់ ១% ផង។ តម្រូវការសន្សំធនធានសម្រាប់ការចំណាយលើការអប់រំត្រូវតែមានតុល្យភាពជាមួយនឹងតម្រូវការចំណាយលើគ្រូបង្រៀនដើម្បីទាក់ទាញ និងរក្សាគ្រូបង្រៀនដែលមានសមត្ថភាព។

**តម្រូវការសន្សំធនធានសម្រាប់ការចំណាយលើការអប់រំត្រូវតែមានតុល្យភាពជាមួយនឹងតម្រូវការចំណាយលើគ្រូ បង្រៀនដើម្បីទាក់ទាញនិងរក្សាគ្រូបង្រៀនដែលមានសមត្ថភាព។**

ភាពជាដៃគូរវាងផ្នែកសាធារណៈ និងផ្នែកឯកជនត្រូវបានលើកកំពស់កាន់តែខ្លាំងឡើងដោយចាត់ទុកជាមធ្យោបាយមួយសម្រាប់កាត់បន្ថយភាពមិនប្រាកដប្រជា និងកង្វះខាតនៃការចំណាយថវិការដ្ឋ។ មានបញ្ហាកើតឡើងមិនចុះសំរុងគ្នាទាក់ទងនឹងគុណភាព និងសមធម៌។ សហគមន៍ មានលទ្ធភាពខុសគ្នាក្នុងការទាក់ទាញការចំណាយពីរដ្ឋាភិបាល និងសុំមូលនិធិពីផ្នែកឯកជន។

## តើសិស្សអាចសិក្សាចេះដឹងបានកម្រិតណា?

ទិន្នន័យពីការវាយតម្លៃជាតិ និងអន្តរជាតិបង្ហាញថា កុមារក្នុងប្រទេសជាច្រើនពុំមានជំនាញមូលដ្ឋានច្បាស់លាស់ឡើយ។ លទ្ធផលទាបនេះមាននៅគ្រប់ទីកន្លែង។ ប្រទេសដែលសិស្សមានជំនាញមូលដ្ឋានទាបគឺជាប្រទេសទាំងឡាយណាដែលមានប្រព័ន្ធអប់រំទន់ខ្សោយ ដូចជាការចុះឈ្មោះចូលរៀនរបស់សិស្ស និងធនធានសម្រាប់ការអប់រំ។ ចូរពិនិត្យឧទាហរណ៍នានាដូចខាងក្រោម:

**អាមេរិកឡាទីន** ការវាយតម្លៃជាតិក្នុងប្រទេសអាមេរិកឡាទីន ៤ បញ្ជាក់ឲ្យឃើញពីកម្រិតទាបនៃលទ្ធផលនៃការអប់រំក្នុងចំណោមសិស្សភាគច្រើននៅពេលរៀនចប់បឋមសិក្សា។ នៅក្នុងប្រទេស នីការ៉ាហ្គ័រ (២០០២) សិស្សចំនួន ៧០% រៀនបានលទ្ធផលអប្បបរមាលើមុខវិជ្ជាភាសានិងសិស្សច្រើនជាង៨០% រៀនបានលទ្ធផលអប្បបរមាលើមុខវិជ្ជាគណិត។ នៅអ៊ុយរ៉ូហ្គាយ (១៩៩៩) ការសិក្សាមុខវិជ្ជាភាសារបស់សិស្សថ្នាក់ទី ៦ ចំនួន ៤០% គឺ "ខ្សោយ" ឬ "ខ្សោយបំផុត"។ នៅប្រទេសអែលសាល់វ៉ាឌ័រ (១៩៩៩) សិស្សថ្នាក់ទី ៦ ចំនួន ៤០% រៀនបានលទ្ធផលអប្បបរមាលើមុខវិជ្ជាភាសា គណិតវិទ្យា វេជ្ជសាស្ត្រ និង សិក្សាសង្គម។ នៅហុងឌុយរ៉ាស់ (២០០២) ការរៀនសូត្រលើមុខវិជ្ជាភាសា និងគណិតសាស្ត្ររបស់សិស្សថ្នាក់ទី ៦ ចំនួន ៩០% គឺខ្សោយ។

**អាព្រិច** ការស្រាវជ្រាវមួយដែលបានធ្វើឡើងដោយក្រុមអង្គការអាព្រិចខាងត្បូងសម្រាប់ត្រួតពិនិត្យគុណភាពអប់រំ (១៩៩៥-៩៨) បានវាស់ស្ទង់អំពីលទ្ធភាពចេះអានរបស់សិស្សបឋមសិក្សាដោយធ្វើការប្រៀបធៀបទៅនឹងស្តង់ដាដែលបង្កើតឡើងដោយជំនាញការអានថ្នាក់ជាតិ និងគ្រូបង្រៀនថ្នាក់ទី ៦។ ក្នុងចំណោមប្រទេសទាំងប្រាំពីរមានប្រទេស ៤ ដែលសិស្ស ថ្នាក់ទី ៦ តិចជាងពាក់កណ្តាលមានសមត្ថភាពអប្បបរមាលើការអាន។ លទ្ធផលទាបនេះក៏បានបង្ហាញយ៉ាងច្បាស់ផងដែរក្នុងការស្រាវជ្រាវដោយ PASEC (១៩៩៦-២០០១) ដែលបានធ្វើឡើងក្នុងប្រទេសអាព្រិច ៦ និយាយភាសាបារាំង : ១៤% ក្នុងចំណោមសិស្សថ្នាក់ទី ៥ ចំនួន ៤៣%មាន លទ្ធផលទាបលើមុខវិជ្ជា ភាសាបារាំង ឬមុខវិជ្ជាគណិតវិទ្យា។ ឧទាហរណ៍ នៅប្រទេសសេនេហ្កាល់ សិស្សជាង ៤០% ជួបការលំបាកក្នុងការរៀនលេខទសភាគដែលមានលេខពីរខ្ទង់។

**អង្កេតតំបន់ចម្រុះ** យោងតាមការវិវត្តរីកចម្រើនលើការស្រាវជ្រាវពីសមត្ថភាពអានអន្តរជាតិ (PIRLS ២០០១) សិស្សថ្នាក់ទី ៤ យ៉ាងច្រើនក្នុងប្រទេសមួយចំនួនមានជំនាញអានមិនទូលំទូលាយ។ ក្នុងប្រទេសដែលមានប្រាក់ចំណូលមធ្យមដូចជា អាហ្សង់ទីន បេលី កូឡុំប៊ី អ៊ីរ៉ង់ និងម៉ារ៉ុក សិស្សជាងពាក់កណ្តាលទទួលលទ្ធផលក្រោមកម្រិតកំណត់ ២៥ ភាគរយ (ដែលជាពិន្ទុកំណត់ជាអន្តរជាតិ)។ ការ ស្រាវជ្រាវមួយរបស់ PISA ក្នុងប្រទេស ៤៣ ឲ្យដឹងថា សិស្សអាយុ ១៥ ឆ្នាំ ចំនួន ១៨% ក្នុងប្រទេស OECD (ដែលភាគច្រើនមានប្រាក់ចំណូលខ្ពស់) មានចំណេះដឹងលើការអានទាបបំផុត ចំណែកសិស្សដែលមានអាយុដូចគ្នាក្នុងប្រទេសមានប្រាក់ចំណូលទាប និងមធ្យមគឺមានចំនួន៤០%។

សិស្សក្នុងតំបន់ជនបទ និងពីគ្រួសារដែលមានស្ថានភាពសេដ្ឋកិច្ចសង្គមទាបមានលទ្ធផលទាបជាងនេះទៅទៀត។ ទំនាក់ទំនងរវាងការរៀនសូត្ររបស់សិស្ស និងស្ថានភាពសេដ្ឋកិច្ចសង្គមដែលជាទូទៅត្រូវបានវាស់ស្ទង់តាមរយៈកម្រិតសិក្សារបស់ម្តាយឪពុកផ្តល់ព័ត៌មានដ៏សំខាន់ទាក់ទងទៅនឹងលទ្ធផលនៃការរៀនសូត្ររបស់សិស្ស។ ឧទាហរណ៍ ការស្រាវជ្រាវមួយដែលបានធ្វើឡើងក្នុងប្រទេស ១២ ដោយ LLECE បានបង្ហាញថា សិស្សក្នុងប្រទេស គុយបាទទួលលទ្ធផលលើ

ញាំអាហារជង និងធ្វើកិច្ចការផ្ទះជងនៅវូជី ប្រទេសចិន



ការរៀនសូត្រខ្ពស់បំផុត និងម្តាយឪពុកបានទទួលការសិក្សាខុសគ្នាតិចតួចបំផុត។ សិស្សក្នុងប្រទេសដែលមានប្រាក់ចំណូលមធ្យមមានលទ្ធផលស្ថិតក្រោមមធ្យមភាគ OECD ដែលលទ្ធផលទាំងនោះមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធជាមួយនឹងស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច ចំណែកឯក្នុងប្រទេសធំៗមួយចំនួន (ដូចជាប្រទេសឥណ្ឌូនេស៊ី) បើទោះបីជាមានស្ថានភាពគ្រួសារធូរខ្លាំងក៏ដោយ ក៏លទ្ធផលរៀនសូត្ររបស់សិស្សទាបជាងសិស្ស OECD ដែលមានស្ថានភាពគ្រួសារទន់ទាបបំផុតដោយសារតែដំណើរការមិនល្អនៃប្រព័ន្ធអប់រំក្នុងប្រទេសទាំងនោះ។

## ការធានាគុណភាព ការពង្រីកឱកាសចូលរៀន

តើអត្រាចុះឈ្មោះពិត និងពិន្ទុតេស្តអាចមានទំនាក់ទំនងគ្នាដែរឬទេ? ការនេះទំនងជាពុំមានទំនាក់ទំនងគ្នាឡើយ។ បញ្ហាគន្លឹះនោះគឺថា តើប្រទេសទាំងឡាយសម្រេចបានយ៉ាងណា បើគេចង់បានទាំងគុណភាពទាំងបរិមាណនៃការសិក្សានោះ? តំបន់ដែលមានឱកាសចូលរៀនបឋមសិក្សានៅតែមានការលំបាកចំពោះប្រជាជនមួយចំនួន ដូចជានៅអនុតំបន់សាហារ៉ាអាព្រិច អាស៊ីខាងត្បូង និងខាងលិច និងរដ្ឋអារ៉ាប់មួយចំនួនតម្រូវឲ្យបង្កើតគោលនយោបាយតឹងរឹងសម្រាប់កសាងប្រព័ន្ធអប់រំឡើងវិញ រីឯប្រទេសខ្លះទៀតតម្រូវឲ្យយកចិត្តទុកដាក់លើផ្នែកជាក់លាក់មួយចំនួននៃគោលនយោបាយអប់រំ ជាពិសេសលើផ្នែកលទ្ធផលនៃការរៀនសូត្រ ឬឱកាសចូលសិក្សារបស់ក្រុមមនុស្សដែលមិនសូវមានឱកាស និងជួបការលំបាក។

## ការលើកកំពស់ឱកាស: ការគាំពារ និងអប់រំកុមារតូច

ការរីកចម្រើនទៅលើឱកាសប្រើប្រាស់កម្មវិធីគាំពារ និងអប់រំកុមារតូចមុនបឋមសិក្សាឲ្យបានកាន់តែទូលំទូលាយមានកម្រិតយឺតៗចាប់ពីឆ្នាំ១៩៩៨។ ប្រទេស ជាច្រើននៅអនុតំបន់សាហារ៉ាអាព្រិច រដ្ឋអារ៉ាប់ អាស៊ីកណ្តាល និងអាស៊ីខាងត្បូង និងខាងលិចមានអត្រាចុះឈ្មោះចូលរៀនទាបនៅកម្រិតមុនបឋមសិក្សាក្នុងប្រទេសក្រីក្រមួយចំនួនដែលមានជំពាក់បំណុលច្រើន ការចូលរៀនក្នុងកម្មវិធីគាំពារ និងអប់រំកុមារតូចបានធ្លាក់ចុះរវាងឆ្នាំ ១៩៩៨ និង ២០០១។ គិតជាមធ្យម កុមារម្នាក់នៅអាព្រិចម្នាក់អាចរំពឹងថានឹងចំណាយពេលតែចំនួន ០,៣ ឆ្នាំសម្រាប់ការគាំពារ និងបណ្តុះបណ្តាលកុមារមុនរៀនបឋមសិក្សា បើប្រៀបធៀបទៅនឹង ១,៦ ឆ្នាំរបស់ក្មេងម្នាក់នៅអាមេរិក ឡាទីន និងការ៉ាប៊ី និង ២,២ ឆ្នាំរបស់ក្មេងម្នាក់នៅអឺរ៉ុបខាងត្បូង និងអាមេរិកខាងជើង។ បើទោះបីជាភាពខុសគ្នានៃយេនឌ័រគិតជាតួលេខពុំមានលក្ខណៈទូលំទូលាយនៅកម្រិតគាំពារ និងអប់រំកុមារតូចមានចំនួនតិចជាងនៅបឋមសិក្សាក្តី ក៏គម្លាតនៃការចូលរៀនរបស់កុមារា និងកុមារីនៅតែមានទំហំធំក្នុងប្រទេសមួយចំនួនដោយរួមទាំងប្រទេសម៉ូរ៉ុក និងប៉ាគីស្ថាន ដែលនៅក្នុងប្រទេសទាំងពីរនេះ អត្រាចុះឈ្មោះចូលរៀនសរុបរបស់កុមារីគឺមានចំនួន ៣ ភាគ ៤ នៃអត្រាចុះឈ្មោះចូលរៀនរបស់កុមារា ឬអត្រាចុះឈ្មោះចូលរៀនសរុបតិចជាងនេះទៅទៀត។ កុមារមកពីគ្រួសារក្រីក្របំផុតទទួលបានផលប្រយោជន៍ច្រើនបំផុតពីកម្មវិធីគាំពារ និងអប់រំកុមារតូច បើពិនិត្យទៅលើការគាំពារសុខភាព និងការអប់រំ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ទិន្នន័យបង្ហាញថា កុមារជាច្រើននាក់ពុំបានទទួលកម្មវិធីនោះទេ។ កម្មវិធីនោះមានលំអៀងទៅប្រជាពលរដ្ឋរស់នៅក្នុងទីប្រជុំជន និងគ្រួសារអ្នកមាន។

**កុមារកូនគ្រួសារក្រីក្រនឹងទទួលបានប្រយោជន៍ច្រើនពីការផ្តល់សេវាគាំពារ និងអប់រំកុមារតូច។ កម្មវិធីនោះនឹងយកចិត្តទុកដាក់លើការថែទាំ អនាម័យសុខភាព និងអប់រំ ហើយបើតាមទិន្នន័យបង្ហាញថា កុមារទាំងនោះច្រើនត្រូវគេទាត់ចោលមិនឲ្យទទួលការអប់រំ**

ការវាយតម្លៃគុណភាពនៃកម្មវិធីគាំពារ និងអប់រំកុមារតូចគឺជាការលំបាកទាំងទ្រឹស្តី និងការអនុវត្តជាក់ស្តែង ហើយការនេះពុំបានដោះស្រាយឲ្យបានគ្រប់គ្រាន់នៅឡើយនៅកម្រិតអន្តរជាតិ។ ការស្រាវជ្រាវភាគច្រើនដែលធ្វើឡើងក្នុងគោលបំណងវាយតម្លៃលទ្ធផលនៃការរៀនសូត្របានវាស់វែងពីឥទ្ធិពលនៃការចូលរៀនក្នុងកម្មវិធីគាំពារ និងអប់រំកុមារតូច ពោលគឺការរីកចម្រើន និងលទ្ធផលនៅសាលាបឋមសិក្សា។ អត្រាផលធៀបសិស្ស/គ្រូនៅកម្រិតគាំពារ និងអប់រំកុមារតូចមានកម្រិតខ្ពស់បំផុតនៅអនុតំបន់សាហារ៉ាអាព្រិច (២៥:១ ឬច្រើនជាងនេះនៅក្នុងប្រទេសស្ទើរតែពាក់កណ្តាល) និងមានកម្រិតទាបបំផុតនៅអឺរ៉ុបកណ្តាល និង ខាងកើត និងអាស៊ីកណ្តាល (ក្រោម ១៥:១ ក្នុងប្រទេស ៣នៃប្រទេស ៤)។ ភស្តុតាងពីប្រទេសមានប្រាក់ចំណូលមធ្យម និងខ្ពស់បង្ហាញថា បុគ្គលិកនៅកម្រិតមុនបឋមសិក្សាត្រូវបានគេចាត់ទុកថា មានកម្រិតវប្បធម៌ស្មើគ្នានឹងគ្រូបឋមសិក្សា។ ផ្ទុយទៅវិញ គ្រូជាច្រើនក្នុងប្រទេសរកប្រាក់ចំណូលទាបគឺជាគ្រូជាប់កិច្ចសន្យាទទួលបានប្រាក់ខែតិច និងឆ្លងកាត់ការបណ្តុះបណ្តាលវិជ្ជាជីវៈតិចតួច ឬគ្មានទាល់តែសោះ។

## អក្ខរកម្ម : កាតព្វកិច្ចលំបាកដែលត្រូវបំពេញក្នុងប្រទេស ៩

មានអនក្ខរជនមនុស្សពេញវ័យប្រមាណ ៨០០ លាននាក់ក្នុងពិភពលោកដែលត្រូវជា ១៨,៣% នៃប្រជាពលរដ្ឋពេញវ័យ។ អនក្ខរជនស្ទើរតែ ២ ភាគ ៣ ដែលត្រូវជា ៦៤% ក្នុងពិភពលោកគឺជាស្ត្រី។ អនក្ខរកម្មកម្រិតធ្ងន់ធ្ងរគឺមាននៅអនុតំបន់ សាហារ៉ាអាព្រិច រដ្ឋអារ៉ាប់ និងអាស៊ីខាងត្បូង និងខាងលិចដែលតំបន់ទាំងនោះ មានអត្រាអក្ខរកម្មតែចំនួនប្រមាណជា ៦០% ប៉ុណ្ណោះ។ អនក្ខរជនពេញវ័យជាង ៧០% របស់ពិភពលោក (៥៦២ លាននាក់) រស់នៅប្រទេស ៩ ប៉ុណ្ណោះគឺឥណ្ឌា (៣៤%) ចិន (១១%) បង់ក្លាដែស (៦,៥%) និង ប៉ាគីស្ថាន (៦,៤%)។ ការសម្រេចគោលដៅអក្ខរកម្មក្នុងការអប់រំសម្រាប់ទាំងអស់គ្នាត្រូវពឹងផ្អែកយ៉ាងសំខាន់លើគោលនយោបាយដែលបានអនុវត្តក្នុងប្រទេសទាំងនោះ។

ក្នុងអំឡុងទសវត្សរ៍ ១៩៩០ កម្រិតអក្ខរកម្មមានការរីកចម្រើនខ្លាំងក្នុងប្រទេសមួយចំនួន។ ឧទាហរណ៍ នៅប្រេស៊ីល អត្រាអក្ខរកម្មបានកើនពី ៨០,១%ដល់ ៨៨% ក្នុងរយៈពេល ១ ទសវត្សរ៍ ដោយមានអត្រាអក្ខរកម្មរបស់ស្ត្រីចំនួន ៨៨,៣%។

ជំនាញអក្ខរកម្មក្នុងចំណោមមនុស្សពេញវ័យក៏អាចមានទំនាក់ទំនងគ្នាជាមួយនឹងការរីកចម្រើនឈានទៅសម្រេចសកលកម្មអប់រំបឋមសិក្សាដែរ។ ការស្រាវជ្រាវមួយដែលបានធ្វើឡើងក្នុងប្រទេសនីហ្សេ ឡាវ និងបូលីវី បានបង្ហាញថា កត្តាដែលនាំឲ្យកុមារបោះបង់ចោលសាលាមានកម្រិតខ្ពស់បំផុតនៅក្នុងចំណោមមាតាដែលមានជំនាញអក្ខរកម្មទាប។ នៅប្រទេសនីហ្សេ កុមារគ្រប់អាយុចូលរៀន

៤. វិទ្យាស្ថានស្ថិតិ UNESCO បានប៉ាន់ស្មានឡើងវិញអំពីចំនួនអនក្ខរជនដោយប្រើទិន្នន័យថ្មីចុងក្រោយ។ អត្រាស្មានបច្ចុប្បន្នប្រហែលតិចជាង ៨៦២ លាននាក់ក្នុងឆ្នាំ ២០០០ ក្នុងរបាយការណ៍សកលលោកតាមដានការអប់រំសម្រាប់ទាំងអស់គ្នា ២០០៣/៤។ ការប្រើទិន្នន័យថ្មីបណ្តាលមកពីកត្តាច្រើនយ៉ាង ដូចជា ទិន្នន័យបានមកពីជំរឿន និងអង្កេតថ្មីរបស់បណ្តាប្រទេសជាច្រើន។ ឧ. ជំរឿនឆ្នាំ ២០០០ របស់ចិនផ្តល់ទិន្នន័យដល់វិទ្យាស្ថានសម្រាប់គណនាចំនួនអនក្ខរជនមនុស្សចាស់នៅប្រទេសនេះ ដែលបានថយចុះជាង ៥០ លាននាក់។

បឋមសិក្សាចំនួន ៧០% ដែលមានមាតាមិនចេះអក្សរមិនបានចូលរៀនឡើយ បើប្រៀបធៀបជាមួយកុមារដែលម្តាយចេះអាន និង សរសេរយ៉ាងច្បាស់លាស់មានចំនួនតែ ៣០% ប៉ុណ្ណោះ ។

អត្រាអក្ខរកម្មក្នុងចំណោមយុវវ័យ (អាយុ ១៥-២៤ ឆ្នាំ) គឺជាសូចនាករណ៍ដ៏សំខាន់មួយបង្ហាញពីការរីកចម្រើនរបស់ការអប់រំសម្រាប់ទាំងអស់គ្នា និង គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ពីព្រោះថាសូចនាករណ៍នោះឆ្លុះបញ្ចាំងថា តើប្រព័ន្ធអប់រំកាលពីមួយទសវត្សរ៍កន្លងទៅបានផ្តល់ជំនាញអក្ខរកម្មមូលដ្ឋានបានល្អកម្រិតណា។ អត្រាអក្ខរកម្មក្នុងចំណោមយុវវ័យគឺមានចំនួនច្រើនជាង ៧០% នៅតាមតំបន់ទាំងអស់ ហើយវិសមភាពយេនឌ័រគិតជាតួលេខសម្រាប់យុវវ័យត្រូវបានគេយកចិត្តទុកដាក់តិចជាងវិសមភាពយេនឌ័រគិតជាតួលេខក្នុងចំណោមមនុស្សពេញវ័យ។

## បំណិនជីវិត : ការខិតខំប្រឹងប្រែងវាយតម្លៃនានា

គោលដៅទី ៣នៃក្របខ័ណ្ឌសកម្មភាពក្រុងដាកាគឺសំដៅលើកកំពស់ឱកាសចូលរៀនសម្រាប់យុវវ័យ និងមនុស្សចាស់ជាពិសេសសិស្សដែលមិនបានទទួលផលប្រយោជន៍ពីការអប់រំមូលដ្ឋាន ឬសិស្សដែលបានបោះបង់ចោលសាលា។

ប្រទេសឡាវ ម៉ាលី នេប៉ាល់ និងសេនេហ្គាល់បានចាប់ផ្តើមពិនិត្យគោលនយោបាយរួមគ្នាលើគោលដៅនេះ ដោយចាត់ទុកថាជាការអភិវឌ្ឍជំនាញ។ ប្រទេសទាំងនេះបានចាប់ផ្តើមដោយធ្វើការប៉ាន់ស្មានពីតម្រូវការឲ្យមានកម្មវិធីសិក្សាដោយយកចិត្តទុកដាក់លើមូលដ្ឋាននៃកត្តាប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម ហើយបានសន្និដ្ឋានថា កម្មវិធីអប់រំក្រៅប្រព័ន្ធ និងការបណ្តុះបណ្តាលវិជ្ជាជីវៈមធ្យមសិក្សាមិនឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គលម្នាក់ៗ និងសង្គមឡើយ។ ជាងនេះទៅទៀត កម្មវិធី និងភ្នាក់ងារផ្តល់ការអប់រំច្រើនឆ្លុះបញ្ចាំងពីតម្រូវការផ្សេងៗ ប៉ុន្តែធ្វើឲ្យការត្រួតពិនិត្យមានការលំបាក។ ទិន្នន័យអំពីវិសាលភាព និងប្រសិទ្ធភាពនៃកម្មវិធីទាំងនោះកំររកបានណាស់។ ក្របខ័ណ្ឌត្រួតពិនិត្យសាមញ្ញមួយអាចកើតមានរូបរាងឡើង ប្រសិនបើគំនិតផ្តួចផ្តើមនៃប្រទេសទាំង ៤ នេះត្រូវបានពង្រីកឲ្យបានទូលំទូលាយ។

## ការវាស់វែងពីការរីកចម្រើនជាសកល : សន្ទស្សន៍នៃការអភិវឌ្ឍអប់រំសម្រាប់ទាំងអស់គ្នា

ចាប់តាំងពីបានបង្ហាញនៅក្នុងរបាយការណ៍ឆ្នាំ ២០០៣ សន្ទស្សន៍នៃការអភិវឌ្ឍអប់រំសម្រាប់ទាំងអស់គ្នាមានបញ្ចូលសន្ទស្សន៍សម្រាប់គោលដៅ៤នៃគោលដៅក្រុងដាកាទាំងអស់ពោលគឺ សកលកម្មអប់រំបឋមសិក្សា អក្ខរកម្មមនុស្សចាស់ សមភាពយេនឌ័រគិតជាតួលេខ និងគុណភាពអប់រំ។ ទិន្នន័យទាំងនេះមិនទាន់បានកំណត់ស្តង់ដាឲ្យបានគ្រប់គ្រាន់សម្រាប់ដាក់បញ្ចូលទៅក្នុងកម្មវិធីគាំពារ និងអប់រំកុមារតូច (គោលដៅទី ១) និងបំណិនជីវិត (គោលដៅទី៣) នៅឡើយទេ។

សូចនាករណ៍មួយត្រូវបានគេជ្រើសរើសធ្វើជាតំណាងនៃគោលដៅនីមួយៗ ដូចជាអត្រាចុះឈ្មោះចូលរៀនពិតតំណាងឲ្យ សកលកម្មអប់រំបឋមសិក្សា អត្រាអក្ខរកម្មក្នុងចំណោមមនុស្សអាយុ ១៥ ឆ្នាំ និង លើសពី ១៥ ឆ្នាំ សម្រាប់អក្ខរកម្មជនពេញវ័យ សន្ទស្សន៍នៃការអប់រំសម្រាប់ទាំងអស់គ្នាដែលទាក់ទងនឹងយេនឌ័រ (សន្ទស្សន៍សមភាពយេនឌ័រគិតជាតួលេខសម្រាប់អត្រាចុះឈ្មោះចូលរៀនសរុបនៅបឋមសិក្សា និងមធ្យមសិក្សា និងអត្រាអក្ខរកម្មក្នុងចំណោមមនុស្សពេញវ័យ) សម្រាប់យេនឌ័រ និងអត្រា នៃការបន្តរៀនសូត្ររហូតដល់ថ្នាក់ទី ៥។ សន្ទស្សន៍នេះប្រើប្រាស់ក្នុងប្រទេស ១២៧ នៅឆ្នាំ ២០០១[៥] (ចូលមើលក្នុងប្រអប់)។

### ប្រទេសនានាស្ថិតនៅទីតាំងណាតាមសន្ទស្សន៍អភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នា

- ប្រទេស ៤១ (១ ភាគ ៣នៃប្រទេសទាំងអស់) ដែលប្រទេសទាំងនោះស្ថិតនៅអាមេរិកខាងជើង និងអឺរ៉ុបខាងលិច កណ្តាល និងខាងកើតបានសម្រេច ឬស្ទើរតែបានសម្រេចគោលដៅទាំង ៤។
- ប្រទេស ៥១ មានតម្លៃសន្ទស្សន៍នៃការអភិវឌ្ឍអប់រំសម្រាប់ទាំងអស់គ្នាចន្លោះពី ០,៨០ និង ០,៩៤។ ជិតពាក់កណ្តាលនៃប្រទេសទាំងនេះដែលភាគច្រើនស្ថិតនៅអាមេរិកឡាទីនមានការអន់ថយលើគោលដៅគុណភាពនៃការអប់រំ។ កុមារក្នុងប្រទេសទាំងនោះ ដែលមានឱកាសចូលរៀន បោះបង់ចោលការរៀនសូត្រមុនកំណត់មួយផ្នែកដោយសារគុណភាពនៃការអប់រំទាប។
- ប្រទេស៣៥ មានការលំបាកខ្លាំងក្នុងការធានាសម្រេចគោលដៅគុណភាពអប់រំដែលមានតម្លៃនៃសន្ទស្សន៍ការអភិវឌ្ឍអប់រំសម្រាប់ទាំងអស់គ្នានៅកម្រិត មួយក្រោម ០,៨០។ ក្រៅពីនេះ មាន ២២ ប្រទេសនៅអនុតំបន់សាហារ៉ាអាព្រិច។ បញ្ហានេះក៏កើតមានក្នុងប្រទេស ៣ ដែលមានប្រជាជនច្រើនដែរ គឺប្រទេសឥណ្ឌា បង់ក្លាដែស និងប៉ាគីស្ថាន។ បញ្ហាចម្រុះទាំងនេះត្រូវតែលើកមកដោះស្រាយឲ្យបានព្រមៗគ្នា ប្រសិនបើចង់ធ្វើការវាស់វែងការអប់រំសម្រាប់ ទាំងអស់គ្នាសម្រាប់គោលដៅគុណភាពនៃ ការអប់រំនេះ។

**ការបញ្ជាក់ឲ្យឃើញថា ការរីកចម្រើនឆាប់រហ័សនៃការអប់រំសម្រាប់ទាំងអស់គ្នាអាចកើតមានឡើងបាន បើទោះបីជានៅក្នុងប្រទេសក្រីក្របំផុតក៏ដោយឲ្យតែមានការប្តេជ្ញាចិត្ត និងគោលនយោបាយសមស្រប។**

ការវិភាគនិន្នាការក្នុងប្រទេស៧៤ ដែលមានទិន្នន័យសម្រាប់សន្ទស្សន៍ទាំង៤ក្នុងឆ្នាំ១៩៩៨ និង២០០១ បង្ហាញឲ្យឃើញពីដំណើរច្បាស់លាស់ឆ្ពោះទៅសម្រេចការអប់រំសម្រាប់ទាំងអស់គ្នាប៉ុន្តែដំណើរនោះពុំមែនលក្ខណៈជាសកលឡើយ។ ៣ ភាគ ៤ នៃប្រទេសទាំងនោះមានតម្លៃនៃសន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នាមានការកើនឡើង។ ប្រទេសដែលមានសន្ទស្សន៍នៃការអភិវឌ្ឍអប់រំសម្រាប់ទាំងអស់គ្នាទាបរួមមានប្រទេសលីបេរីយ៉ា ម៉ូហ្សំប៊ិក តូហ្គោ និងយេម៉ែនមានការកើនឡើងតិចតួចបំផុតគឺ ១៥% (បើប្រៀបធៀបមធ្យមភាគ ២%នៃសន្ទស្សន៍ទាំងមូល) ចន្លោះពី ១៩៩៨ និង ២០០១។ ការនេះបញ្ជាក់ឲ្យឃើញថា ការរីកចម្រើនឆាប់រហ័សឈានទៅសម្រេចការអប់រំសម្រាប់ទាំងអស់គ្នាអាចធានាបាន ទោះបីជានៅក្នុងប្រទេសក្រីក្របំផុតក៏ដោយ ឲ្យតែមានការប្តេជ្ញាចិត្ត និងគោលនយោបាយសមស្រប។ ប្រទេសយេម៉ែនមានការរីកចម្រើនខ្លាំងនៅក្នុងផ្នែកទាំងបួននៃសន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នា។ សន្ទស្សន៍នៃការអភិវឌ្ឍអប់រំសម្រាប់ទាំង អស់គ្នាក្នុងប្រទេសចំនួន ២០ មានការធ្លាក់ចុះមួយផ្នែក គឺការធ្លាក់ចុះ លើអត្រាបោះបង់ការរៀនសូត្រដល់ថ្នាក់ទី ៥។

៥. តម្លៃសន្ទស្សន៍នៃការអភិវឌ្ឍការអប់រំសម្រាប់ទាំងអស់គ្នាអាចមានចន្លោះពី ០ – ១។ កាលណាតម្លៃរំកិលជិត ១ មានន័យថា ប្រទេសនោះជិតឈានសម្រេចគោលដៅរបស់ខ្លួន ហើយការអប់រំក៏សម្រេចកាន់តែច្រើនដែរ។

ជំពូក ៤

# គោលនយោបាយសម្រាប់ធ្វើឱ្យគុណភាពកាន់តែល្អប្រសើរ




សិស្សក្លាហានមួយនាក់នៅប្រទេសអេរីត្រេ

- អ្នករៀនសូត្រប្រភេទផ្សេងគ្នា ការឆ្លើយតបដោយដាក់បញ្ចូលរួមគ្នា
- ការធ្វើឲ្យមានភាពខុសគ្នានៅក្នុងថ្នាក់រៀន : ពេលវេលា កម្មវិធីសិក្សា សៀវភៅសិក្សា និងភាសា
- សកម្មភាពបង្រៀន: រៀបចំតាមរចនាសម្ព័ន្ធ និងយកសិស្សជាមជ្ឈមណ្ឌល
- សម្ភារ ឬអគារសមស្រប
- ការបណ្តុះថ្នាក់ដឹកនាំ និងគ្រប់គ្រងសាលារៀន
- ការពង្រីកលំហូរចំណេះដឹង
- ប្រាក់ចំណូល និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន
- នយោបាយលើកកំពស់គុណភាពអប់រំ: ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ កសាង ការទទួលខុសត្រូវ ធានាភាព ម្ចាស់ការ

ប្រើបើសិស្សមួយចំនួនមិនបានទទួលជំនាញមូលដ្ឋានច្បាស់លាស់នៅពេលបញ្ចប់ការសិក្សានៅបឋមសិក្សាយ៉ាងណាក៏ដោយ ក៏ការវិនិយោគដើម្បីលើកកំពស់ការរៀនសូត្រគឺជាការចាំបាច់ផងដែរ។ រដ្ឋាភិបាលភាគច្រើនកំពុងរងសម្ពាធពីសិស្ស ពីម្តាយឪពុក អ្នកគ្រប់គ្រងសាលា និងពីគ្រូបង្រៀន ដែលមិនត្រឹមតែទាមទារឲ្យពង្រីកឱកាសចូលរៀនប៉ុណ្ណោះទេ តែថែមទាំងជំរុញស្ថានប័នអប់រំ និងកម្មវិធីអប់រំឲ្យអនុវត្តការងារឲ្យមានប្រសិទ្ធភាព និងឲ្យបានល្អប្រសើរជាងមុន។ ទោះជាយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលក្នុងប្រទេសមានប្រាក់ចំណូលទាប និងប្រទេសផ្សេងៗទៀតដែលមានឧបសគ្គខ្វះខាតធនធានធ្ងន់ធ្ងរប្រឈមមុខនឹងជម្រើសដ៏លំបាកក្នុងការអនុវត្តការងាររបស់ខ្លួន។

ការវែងគំនិតបានកើតឡើងត្រង់ចំណុចដែលថា រដ្ឋាភិបាលគួរវិនិយោគថវិកាយ៉ាងតិច ៦% នៃផលិតផលជាតិសរុប (GNP) លើវិស័យអប់រំ បើទោះបីជាធ្វើដូច្នេះមិនធានាផ្តល់គុណភាពអប់រំក៏ដោយ។ ទោះបីស្ថិតនៅក្នុងកម្រិតវិនិយោគទាបសម្រាប់ពេលបច្ចុប្បន្ន ក៏រដ្ឋាភិបាលអាចមានជម្រើសដ៏ប្រពៃដើម្បីសម្រួលដល់លក្ខខណ្ឌនៃការរៀនសូត្រឲ្យបានកាន់តែប្រសើរដែរ។

ដ្យ៉ាក្រាមខាងក្រោមបញ្ជាក់ពីក្របខ័ណ្ឌគោលនយោបាយមួយក្នុងការលើកកំពស់គុណភាពនៃការបង្រៀន និងរៀនដោយយកចិត្តទុកដាក់នៅតាមកម្រិតផ្សេងៗ និងភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងសកម្មភាពអប់រំ។




## ដាក់អ្នករៀនសូត្រទាំងអស់ឲ្យបានចូលរៀនជាមួយគ្នា

អ្នករៀនសូត្រគឺជាតួអង្គដ៏សំខាន់នៅក្នុងដំណើរការបង្រៀន និងរៀន។ ដំណើរការនេះមើលទៅហាក់បីដូចជាការជាក់ស្តែង ប៉ុន្តែ ជានិច្ចកាលពុំមានការពិតឡើយ។ មេរោគអេដស៍/ជំងឺអេដស៍ ពិការភាព ជម្លោះ និងការប្រើប្រាស់ពលកម្មកុមារធ្វើឲ្យកុមាររាប់លាននាក់ជួបប្រទះនឹងគុណវិបត្តិធ្ងន់ធ្ងរ។ នៅអនុតំបន់សាហារ៉ាអាព្រិច កុមារជាង ១១ លាននាក់ ដែលមានអាយុក្រោម ១៥ ឆ្នាំ បាត់បង់យ៉ាងតិចឪពុក ឬម្តាយដោយសារមេរោគអេដស៍/ជំងឺអេដស៍។ ឱកាសចូលរៀនរបស់កុមារទាំងនោះ ជាញឹកញាប់ត្រូវបាត់បង់ដោយសារតម្រូវការថែទាំសមាជិកគ្រួសារមានជំងឺ ឬតម្រូវការជួយរកប្រាក់ចំណូលចិញ្ចឹមគ្រួសារ។ ស្ថានភាពដូច្នេះអំពាវនាវឲ្យមានគោលនយោបាយលំអិតដែលអាចឆ្លើយតបទៅនឹងតម្រូវការ និងកាលៈទេសៈ ផ្សេងៗរបស់កុមារគ្រប់ប្រភេទ។

សុខភាពទ្រុឌទ្រោម និងកង្វះអាហារូបត្ថម្ភមានឥទ្ធិពលទៅលើសមត្ថភាពរៀនសូត្ររបស់កុមារ។ នៅក្នុងប្រទេសជាច្រើន បញ្ហាសុខភាព និងអាហារូបត្ថម្ភត្រូវបានដោះស្រាយប្រកបដោយជោគជ័យតាមរយៈកម្មវិធីយកសាលាជាមូលដ្ឋានដែលជាទូទៅ កម្មវិធីនោះជួយផ្តល់ទឹកស្អាត អនាម័យគ្រប់គ្រាន់ ការព្យាបាលសុខភាព ដូចជាការបញ្ចុះសត្វល្អិតក្នុងខ្លួន អាហារនៅសាលា និងបង្រៀនជំនាញសុខភាពជាមូលដ្ឋាន។ ចំណែកប្រទេសដែលមានអត្រាឆ្លងមេរោគអេដស៍/ជំងឺអេដស៍ខ្ពស់វិញ មុខងារនៃការអប់រំក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃមេរោគដ៏ប្រល័យនេះមានប្រសិទ្ធភាពខ្ពស់បំផុត។

កុមារយ៉ាងច្រើននៅលើពិភពលោកបានទទួលនូវភាពអយុត្តិធម៌ដោយសារការបដិសេធន៍មិនឲ្យទទួលផលប្រយោជន៍ពីការអប់រំ ព្រោះកុមារទាំងនោះមានលក្ខណៈផ្សេងពីកុមារដទៃ។ តាមការប៉ាន់ស្មានឲ្យដឹងថា នៅលើសកលលោក មានកុមារពិការប្រមាណជា ១៥០ លាននាក់ ហើយក្នុងចំណោមនោះមានកុមារតិចជាង ២% ដែលបានចុះឈ្មោះចូលរៀននៅសាលា។ ការពិភាក្សាលើជម្រើសវិធីគាំទ្រដោយដាក់បញ្ចូលកុមារទាំងនោះទៅក្នុងសាលាទូទៅ និងការទាមទារឲ្យមានសាលាពិសេសសម្រាប់កុមារប្រភេទនោះពុំទាន់ត្រូវបានដោះស្រាយនៅឡើយទេ។ បើពិនិត្យលើគុណភាពអប់រំ វិធីមួយក្នុងចំណោមវិធីទាំងពីរនេះមានចំណុចដែលត្រូវពិចារណាច្រើន។ នៅក្នុងប្រទេសមួយចំនួន គ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាលពិសេសទទួលបានប្រាក់កម្រៃតិចជាងកម្រិតស្តង់ដាដោយសារគ្រូទាំងនោះត្រូវបង្រៀនសិស្សតិចជាងគ្រូធម្មតា។ ការអប់រំដោយការដាក់បញ្ចូលគ្នាដែលល្អត្រូវចំណាយច្រើន – សម្រាប់កែលំអកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូ

សិស្សខំប្រឹងរៀនក្រោមពន្លឺភ្លើងទាននៅប្រទេសហ្គាតេម៉ាឡា



© Miguel Dewever Plana/AGENCE VU

បង្កើតសម្ភារៀន និងបង្រៀននឹងជួយសម្រួលដល់លទ្ធភាពទៅសាលារៀនរបស់កុមារទាំងនោះ។ ថ្វីបើការអប់រំដោយដាក់បញ្ចូលគ្នាជាគោលដៅល្អមួយក៏ដោយ ក៏វិធីសាស្ត្រទាំងពីរនេះអាចដាក់បញ្ចូលគ្នាឲ្យទៅជា "វិធីសាស្ត្រភ្លោះ" ដែលអ្នករៀនអាចជ្រើសរើសបាននៅក្នុងបរិបទគោលនយោបាយដាក់បញ្ចូលគ្នា។

កុមារក្នុងប្រទេសដែលទទួលរងគ្រោះដោយសារជម្លោះ ឬទើបងើបចេញពីជម្លោះទាមទារជាបន្ទាន់នូវឱកាសចូលរៀន និងការគាំទ្រខាងស្មារតី។ ការស្រាវជ្រាវថ្មីមួយក្នុងប្រទេស ១០ ដែលមានជម្លោះបានរកឃើញថា កុមារ និងយុវវ័យជាង ២៧ លាននាក់មិនមានលទ្ធភាព និងឱកាសទទួលការអប់រំក្នុងប្រព័ន្ធឡើយ។ ជាការប្រសើរ កម្មវិធីសិក្សាគួរយកចិត្តទុកដាក់លើអាហារូបត្ថម្ភ និងអនាម័យ ការយល់ដឹងពីគ្រាប់មីន សកម្មភាពវប្បធម៌ កីឡា និងតម្លៃផ្សេងៗដែលជួយធានារក្សាសន្តិភាព។ បណ្តាញការងារអន្តរស្ថាប័នទទួលបន្ទុកកិច្ចការអប់រំក្នុងពេលអាសន្ន[6] កំពុងបង្កើតកម្រិតស្តង់ដាអប្បបរមាមួយដើម្បីជួយដល់សមាជិកសហគមន៍អន្តរជាតិ និងភាគីសំខាន់ផ្សេងទៀតដើម្បីធានាថា កុមារក្នុងស្ថានភាពលំបាកនោះអាចទទួលបានការអប់រំដែលមានគុណភាពគ្រប់គ្រាន់។

> **កុមារក្នុងប្រទេសដែលទទួលរងគ្រោះដោយសារជម្លោះ ឬទើបតែងើបចេញពីជម្លោះទាមទារជាបន្ទាន់នូវឱកាសចូលរៀន និងការគាំទ្រខាងស្មារតី**

ជម្រើសផ្សេងៗសម្រាប់ផ្តល់ការអប់រំក្នុងប្រព័ន្ធ និងជម្រើសដែលមានភាពទន់ភ្លន់តម្រូវឲ្យមានជាចាំបាច់ដើម្បីឲ្យកុមារមួយចំនួនដែលប្រឈមមុខនឹងការលំបាកមានឱកាសទទួលការអប់រំ ។ រដ្ឋអាជ្រាប៉ាដែសនៃប្រទេសឥណ្ឌាអនុវត្តកម្មវិធីរៀនពីចម្ងាយដែលមានសិស្សសិក្សាក្នុងកម្មវិធីប្រមាណជាង ១០០០០០ នាក់ រួមមានសិស្សបោះបង់ចោលសាលា កុមារមកពីគ្រួសារវណ្ណៈទាប និងកុមារពិការ។ កម្មវិធីនេះមានតម្លៃប្រហាក់ប្រហែលនឹងការអប់រំបឋមសិក្សាក្នុងប្រព័ន្ធដែរ។

## ការលើកកំពស់សកម្មភាពបង្រៀន និងរៀន

ដំណើរការបង្រៀន និងរៀនគឺជាជីវិតរបស់កម្មវិធីសិក្សា។ ដំណើរការនេះកំណត់សកម្មភាពនៅក្នុងថ្នាក់រៀន និងគុណភាពនៃលទ្ធផលរៀនសូត្រ។ ការអនុវត្តដំណើរការនេះឲ្យបានល្អត្រូវយកចិត្តទុកដាក់លើបញ្ហាគោលនយោបាយជាគន្លឹះ៦ចំណុចដែលមានឥទ្ធិពលផ្ទាល់ទៅលើការបង្រៀន និងរៀនរបស់សិស្ស។ ការអនុវត្តដំណើរការនេះក៏ទាមទារឲ្យយកចិត្តទុកដាក់លើធនធានផ្សេងៗដែលជួយដោយប្រយោលដល់ដំណើរការបង្រៀន និងរៀនសូត្រផងដែរ។

## គោលនយោបាយទាំង ៦ ចំណុច

### គោលបំណងសមស្រប

ការពិភាក្សាលើគោលនយោបាយត្រូវតែធ្វើឡើងតាមកម្រិតគោលបំណងពាក់ព័ន្ធ និងមានតុល្យភាពដោយរៀបរាប់ថា តើអ្នករៀនសូត្រគួររៀនអំពីអ្វី ហើយហេតុអ្វីគួររៀនមេរៀនបែបនោះ។ ការអភិវឌ្ឍជំនាញវិភាគ ច្នៃប្រឌិត និងចំណេះដឹងសង្គមគឺត្រូវបញ្ចូលដោយខានមិនបាន ប៉ុន្តែមានការបារម្ភអំពីតម្លៃ ទាំងនៅថ្នាក់សកលលោក តួយ៉ាងការគោរពសិទ្ធិមនុស្ស បញ្ហាបរិស្ថាន សន្តិភាព និង ភាពអត់ឱន និងទាំងនៅតាមមូលដ្ឋាន ដូចជា ភាពខ្វែងគំនិតគ្នាខាងវប្បធម៌ជាដើម។ ប្រទេសជាច្រើនកំពុងអនុវត្តការងារតម្រង់ឆ្ពោះទៅរកការដាក់បញ្ចូលគ្នាតាមដែលសមស្របនឹងតម្លៃសកល និងតម្លៃមូលដ្ឋាន ដោយការច្របាច់បញ្ចូលគ្នានូវកម្មវិធីសិក្សា និងជីវិតសេដ្ឋកិច្ច សង្គមកិច្ចក្នុងសហគមន៍ និងថ្នាក់ជាតិ។ ទិន្នន័យស្តីពីកម្មវិធីសិក្សាថ្នាក់ជាតិនៃប្រទេស ១០៨ បង្ហាញថា ការយកចិត្តទុកដាក់លើកម្មវិធីសិក្សាមានការប្រែប្រួលមួយចំនួនក្នុងរយៈពេល ២០ ឆ្នាំកន្លងទៅនេះ។ ទោះបីជាជំនាញមូលដ្ឋាននៅតែជាផ្នែកមួយដ៏ចាំបាច់ តម្លៃសកលដែលទាក់ទងនឹងពលរដ្ឋវិជ្ជា និង លទ្ធិប្រជាធិបតេយ្យ និងការអប់រំសិទ្ធិមនុស្សត្រូវបានគេយកចិត្តទុកដាក់កាន់តែច្រើនឡើង។

### តុល្យភាពមុខវិជ្ជា

ទោះបីគោលដៅ និងគោលបំណងនៃកម្មវិធីសិក្សាត្រូវបានឆ្លុះបញ្ចាំងតាមរយៈមុខវិជ្ជាដែលត្រូវបង្រៀននៅក្នុងសាលាក៏ដោយ ក៏មានការពិភាក្សាលើគោលនយោបាយទាក់ទងនឹងគំនិតដែលថា តើមុខវិជ្ជាទាំងនោះត្រូវកំណត់យ៉ាងណា មុខវិជ្ជាប៉ុន្មានត្រូវយកទៅបង្រៀន ហើយមុខវិជ្ជានីមួយៗត្រូវការរយៈពេលបង្រៀនប៉ុន្មាន។ តាមការជាក់ស្តែង មុខវិជ្ជាមួយចំនួនដែលមាននៅក្នុងកម្មវិធីសិក្សាក្នុងប្រព័ន្ធនៅលើពិភពលោកនេះមានការប្រែប្រួលតិចតួចប៉ុណ្ណោះក្នុងអំឡុងពេល ២ ទសវត្សរ៍កន្លងទៅនេះ។ ទោះជាយ៉ាងនេះក៏ដោយ ក៏សមាសភាពនៃមុខវិជ្ជាទាំងនោះមានការកែប្រែខ្លះ ជាពិសេសដោយមានការដាក់បញ្ចូលនូវមុខវិជ្ជាថ្មីៗទាក់ទងនឹងសុខភាព សិទ្ធិមនុស្ស បរិស្ថាន និងបច្ចេកវិទ្យាដែលត្រូវបន្ថែមលើមុខវិជ្ជា "គ្រឹះ" ទាក់ទងផ្ទាល់ទៅនឹងអក្សរសាស្ត្រ និងលេខនព្វន្ត។ ផ្នែកសំខាន់របស់កម្មវិធីសិក្សាគ្រឹះគឺការបង្រៀនឲ្យសិស្សចេះអាន និងរៀនអាន។ អក្សរសាស្ត្រគឺជាវិធានដ៏ចាំបាច់មួយសម្រាប់រៀនឲ្យពូកែលើមុខវិជ្ជាផ្សេងៗទៀត។ អក្សរសាស្ត្រក៏ជាសូចនាករណ៍មួយក្នុងចំណោមសូចនាករណ៍ដ៏ល្អបំផុតបញ្ជាក់ពីលទ្ធផលទទួលបានពីការរៀនសូត្រយូរអង្វែង។ ដូច្នេះ រៀនអានត្រូវចាត់ទុកជាមុខវិជ្ជាអាទិភាពមួយសម្រាប់លើកកំពស់គុណភាពអប់រំមូលដ្ឋាន ជាពិសេសសម្រាប់សិស្សមកពីគ្រួសារក្រីក្រជួបការលំបាក។

### ការប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាព

ការស្រាវជ្រាវបង្ហាញពីទំនាក់ទំនងវិជ្ជមាន និងទៀងទាត់រវាងពេលវេលានៃការផ្តល់មេរៀន និងលទ្ធផលរៀនសូត្ររបស់សិស្សទាំងនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ សំខាន់ជាងនេះទៅទៀត ទំនាក់ទំនងនេះកាន់តែមានភាពរឹងមាំនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ការស្រាវជ្រាវនៅពេលថ្មីៗបង្ហាញថា តាមការពិនិត្យជាសកល ពេលវេលាសម្រាប់ការបង្រៀនដែលបានរៀបចំទុកប្រចាំឆ្នាំមិនបានកើនឡើងឡើយ តែផ្ទុយទៅវិញមានប្រទេសជាច្រើនបានកាត់បន្ថយពេលវេលាបង្រៀនមួយផ្នែក ដោយសារសម្ពាធឆ្លើយតបទៅនឹងតម្រូវការខ្ពស់ នៅពេលដែលមានការលំបាកខ្វះធនធាន។ ការសិក្សាតូចៗមួយចំនួនបង្ហាញថា ពេលវេលាជាច្រើនដែលបានរៀបចំសម្រាប់បង្រៀនត្រូវបានបាត់បង់ដោយសារអវត្តមានរបស់គ្រូ និងសិស្ស កង្វះខាតបន្ទប់រៀន កង្វះខាតសម្ភារៀនសូត្រ និងវិន័យសាលាមិនល្អ។ ទោះបីជារយៈពេល ១០០ ម៉ោងក្នុងមួយឆ្នាំត្រូវទទួលបានការឯកភាពយ៉ាងទូលំទូលាយថា ជាពេលវេលាគ្រឹះសម្រាប់ការរៀន និងបង្រៀនក៏ដោយ ក៏មានប្រទេសតិចតួចប៉ុណ្ណោះបានទទួលជោគជ័យលើការប្រើប្រាស់ពេលវេលានេះ។ ការគ្រប់គ្រងសាលារៀនបានល្អ និងយុទ្ធសាស្ត្របង្រៀនមានប្រសិទ្ធភាពអាចជួយឲ្យសម្រេចនិន្នាការនេះ។

### វិធីសាស្ត្រចិត្តគរុកោសល្យជួយសិស្សឲ្យរៀនបានល្អប្រសើរ

នៅក្នុងប្រទេសជាច្រើន របៀប និងវិធីសាស្ត្របង្រៀនដែលគ្រូយកទៅប្រើជាទូទៅមិនបានជួយសិស្សឲ្យរៀនបានប្រសើរឡើយ។ អ្នកជំនាញអប់រំជាច្រើនឯកភាពថា គរុកោសល្យយកគ្រូជាគោលមជ្ឈមណ្ឌល ដោយឲ្យសិស្សមានមុខងារជាអ្នកទទួលសុទ្ធសាធពុំប្រសើរសម្រាប់ការរៀនសូត្ររបស់សិស្សឡើយ ប៉ុន្តែវិធីសាស្ត្រនេះត្រូវបានអនុវត្តនៅក្នុងបន្ទប់រៀនយ៉ាងច្រើននៅអនុតំបន់សាហារ៉ាអាព្រិច និងកន្លែងផ្សេងៗទៀត។ កម្មវិធីសិក្សាសំខាន់ៗទាំងឡាយគេប្រទះឃើញនៅក្នុងតំបន់

6. http://www.ineesite.org

ទាំងអស់ជំរុញលើកទឹកចិត្តឲ្យប្រើគរុកោសល្យយកសិស្សជាគោលមជ្ឈមណ្ឌល វិធីរៀនសូត្រដោយការចូលរួម និងអភិវឌ្ឍន៍ជំនាញគិតវិភាគ និងជំនាញដោះស្រាយបញ្ហា។ ឧទាហរណ៍នៃកម្មវិធីទាំងនោះរួមមានកម្មវិធី Escula Nueva នៅប្រទេសកូឡុំប៊ី កម្មវិធីសាលា–សហគមន៍នៅប្រទេសអេហ្ស៊ីប កម្មវិធីគរុកោសល្យ Convergent នៅប្រទេសម៉ាលី និងសាលាជាច្រើនដែលគ្រប់គ្រង និងដំណើរការដោយគណៈកម្មការអភិវឌ្ឍជនបទបង់ក្លាដែស។ ការប្រឹងប្រែងកែសម្រួលដើម្បីប្រើប្រាស់វិធីសាស្ត្រថ្មីនេះបានក្លាយទៅជាផ្នែកតស៊ូមួយលើការកែលំអគរុកោសល្យនៅអនុតំបន់សាហារ៉ាអាព្រិច ប៉ុន្តែពុំទាន់មានការសន្និដ្ឋានលទ្ធផលនៅឡើយ ហើយមានការចំណាយខ្ពស់។

ទាក់ទងនឹងវិធីសាស្ត្របង្រៀនបែបប្រពៃណី "សរសេរ និងនិយាយ" និងវិធីសាស្ត្រ "បង្រៀនដោយការចូលរួម" មានអ្នកអប់រំជាច្រើននាក់គាំទ្រដល់ការបង្រៀនដោយមានរចនាសម្ព័ន្ធត្រឹមត្រូវ ពោលគឺការបង្រៀនដែលមានដាក់បញ្ចូលគ្នានូវការណែនាំផ្ទាល់ ការអនុវត្តដោយមានការណែនាំជាមុន និងការរៀនដោយម្ចាស់ការ។ ជាធម្មតា គ្រូបង្ហាញខ្លឹមសារមេរៀនមួយចំនួន (ដោយធ្វើយ៉ាងណាឲ្យសិស្សយល់ពីខ្លឹមសារមេរៀននោះសិន) ហើយបំផុសឲ្យសិស្សរៀនស្វែងយល់។ ភស្តុតាងជាច្រើនបង្ហាញថា ការបង្រៀនដោយមានរចនាសម្ព័ន្ធនេះទទួលបានលទ្ធផលប្រសើរជាងវិធីសាស្ត្របង្រៀនដោយការចូលរួមសម្រាប់កុមារដែលមានស្ថានភាពលំបាក កុមារដែលមានការលំបាកក្នុងការរៀនសូត្រ និងកុមាររៀនក្នុងថ្នាក់ដែលមានសិស្សច្រើន។ វិធីនេះក៏នៅតែអាចបង្កើតឲ្យមានបរិយាកាសរៀនសូត្រយកសិស្សជាគោលមជ្ឈមណ្ឌលដែរ ពោលគឺសិស្សនៅតែមានឱកាសស្រាវជ្រាវ និងស្វែងយល់ដោយខ្លួនឯង។

តំបន់ដាច់ស្រយាលអាចត្រូវការវិធីសាស្ត្រអប់រំពិសេស ដូចជាកម្មវិធីរៀនពីចម្ងាយ ថ្នាក់រៀនចល័ត និងការបង្រៀនដោយមានថ្នាក់ចម្រុះ។ កម្មវិធីសិក្សាទៀតសោតត្រូវតែកែសម្រួលទៅតាមស្ថានភាពជាក់ស្តែង ហើយគ្រូបង្រៀនគួរទទួលបានការបណ្តុះបណ្តាលដើម្បីបង្កើតវិធីសាស្ត្រគរុកោសល្យ សមស្រប ដូចជាការរៀនសូត្រជាមួយមិត្តភក្តិ ការសិក្សាជាក្រុម និងការសិក្សាដោយខ្លួនឯង។

### គោលនយោបាយភាសា

ប្រជាជនប្រមាណ ១,៣ លាននាក់ ដែលត្រូវជា ២០% នៃប្រជាជនពិភពលោកមាន "ភាសាក្នុងស្រុក" ជាភាសាកំណើត។ នៅក្នុងករណីជាច្រើន ការជ្រើសរើសភាសាសម្រាប់ប្រើនៅក្នុងសាលារៀនគឺមានសារៈសំខាន់បំផុតសម្រាប់ជួយលើកកំពស់គុណភាពនៃការបង្រៀន និងរៀន។ ភស្តុតាងស្រាវជ្រាវបង្ហាញថា ការចាប់ផ្តើមបង្រៀនដោយប្រើភាសាកំណើតរបស់អ្នករៀនជួយលើកកំពស់លទ្ធផលនៃការរៀនសូត្រ ចំណាយតិច កាត់បន្ថយអត្រាធ្លាក់ថ្នាក់ និងអត្រាបោះបង់ចោលសាលា។ វិធីសាស្ត្រគំរូដែលទទួលបានជោគជ័យបំផុតនោះគឺថា បន្ទាប់ពីបានចំណាយពេលសិក្សាដំបូងនៅសាលាជាច្រើនឆ្នាំរួចមក គួរបញ្ចូលភាសាទីពីរជាបណ្តើរៗ។ ប្រទេសហ្សមប៊ីបានបង្កើតវិធីសាស្ត្រគំរូទ្វេភាសា ហើយពេលនេះបានប្រកាន់ភ្ជាប់យ៉ាងហ្មត់ចត់ក្នុងការកែទម្រង់អប់រំដើម្បីលើកកំពស់គុណភាព។ ប្រទេសប៉ាពួរញូគីនេ៊ូរប្រើប្រាស់ជាង ៤៣៤ ភាសាសម្រាប់បង្រៀននៅថ្នាក់ដំបូងៗក្នុងចំណោមភាសាចម្រុះរបស់ប្រជាជនប្រមាណ ៨៣០ ភាសា។ របៀបវារៈកែទម្រង់វិស័យអប់រំឆ្នាំ ១៩៩៥ បានប្រែក្លាយភាសានិយាយទៅជាភាសាសម្រាប់បង្រៀននៅឆ្នាំទី ១ និងទី ២ ហើយភាសាអង់គ្លេសត្រូវបញ្ចូលនៅចុងឆ្នាំទី៣។ ការបង្រៀនដោយប្រើប្រាស់ភាសាផ្សេងៗគ្នាគឺជាជម្រើសគោលនយោបាយមួយដែលមានឥទ្ធិពលទៅលើកម្មវិធីសិក្សា ខ្លឹមសារនៃមុខវិជ្ជា និងវិធីសាស្ត្រចិត្តគរុកោសល្យ។ តុល្យភាពភាសាចាំបាច់ត្រូវធ្វើឡើងរវាងភាសាដែលជួយឲ្យអ្នករៀនប្រើប្រាស់ភាសាក្នុងស្រុកសម្រាប់ការរៀនសូត្រ និងធ្វើយ៉ាងណាឲ្យសិស្សទាំងនោះមានលទ្ធភាពប្រើប្រាស់ភាសាសកលលោកបាន។

> **ភស្តុតាងបង្ហាញថា ការចាប់ផ្តើមបង្រៀនដោយប្រើភាសាកំណើតរបស់អ្នករៀនជួយលើកកំពស់ លទ្ធផលនៃការរៀនសូត្រចំណាយតិច កាត់បន្ថយអត្រាធ្លាក់ថ្នាក់ និងអត្រាបោះបង់ចោលការសិក្សា**

### រៀនសូត្រ និងដកពិសោធន៍ពីការវាយតម្លៃ

ការវាយតម្លៃទៀងទាត់យកជាការបាន និងទាន់ពេលវេលាគឺជាកត្តាគន្លឹះក្នុងការលើកកំពស់លទ្ធផលនៃការរៀនសូត្រ។ នៅតាមបន្ទប់រៀន ការវាយតម្លៃអាចបែងចែកជាការវាយតម្លៃសរុប (វាយតម្លៃលទ្ធផលតាមរយៈតេស្តដែលមានការរៀបចំទុកជាមុន) ឬការវាយតម្លៃតាមដានការរីកចម្រើន (វិភាគអំពីរបៀបដែលសិស្សម្នាក់ៗសិក្សារៀនសូត្រតាមរយៈការសង្កេត)។ គោលដៅនៃការវាយតម្លៃនេះគឺដើម្បីរកគំនិតឆ្លុះបញ្ចាំងសម្រាប់ផ្តល់ឲ្យសិស្សវិញ និងដើម្បីលើកកំពស់សកម្មភាពបង្រៀន និងរៀនសូត្រ។ ប្រទេសមួយចំនួន (ដូចជាប្រទេសហ្គាណា អាមេរិកខាងត្បូង និងស្រីលង្កា) បានជ្រើសរើសយកការវាយតម្លៃតាមដានការរីកចម្រើនធ្វើជាផ្នែកបំពេញបន្ថែមទៅលើការប្រលងផ្លូវការ។ នៅក្នុងប្រទេសជាច្រើន កាលៈទេសៈនៅមូលដ្ឋានបង្កឧបសគ្គដល់ការពង្រីកការវាយតម្លៃឲ្យបានទូលំទូលាយ ដូចជា តម្រូវការឲ្យមានធនធានគ្រប់គ្រាន់ ការបណ្តុះបណ្តាលគ្រូបង្រៀនអំពីបច្ចេកទេសវាយតម្លៃ និងចំនួនសិស្សក្នុងថ្នាក់រៀនតិច។

## ធនធានដែលជួយដល់ការបង្រៀន និងរៀនឲ្យបានល្អ

### គោលនយោបាយសៀវភៅសិក្សាថ្នាក់ជាតិ

សៀវភៅសិក្សាពិតជាជួយសម្រួលដល់ការកែប្រែគុណភាពនៃការបង្រៀន និងរៀនរបស់សិស្សផងដែរ ប៉ុន្តែការស្រាវជ្រាវត្រូវបានធ្វើឡើងតិចតួចក្នុងអំឡុងពេលកន្លងទៅ។ កង្វះសៀវភៅសិក្សាអាចបណ្តាលមកពីប្រព័ន្ធនៃការបែងចែកពុំមានប្រសិទ្ធភាព ការអនុវត្តមិនត្រឹមត្រូវ ឬអំពើពុករលួយ។ ការសិក្សាក្នុងប្រទេសហ្សមប៊ី (ឆ្នាំ២០០០) រកឃើញថា សៀវភៅតិចជាង ១០% ត្រូវបានយកទៅប្រើប្រាស់ក្នុងបន្ទប់រៀន។ ការកែទម្រង់ទីផ្សារសៀវភៅសិក្សាបានធ្វើឲ្យមានសៀវភៅសិក្សាសម្បូរបែបសម្រាប់សិស្ស និងមានតម្លៃថោកនៅក្នុងប្រទេសជាច្រើន។ នៅក្នុងប្រទេសយូហ្គាន់ដា តម្លៃសៀវភៅបានចុះថ្លៃ ៥០% ដោយសារលទ្ធផលនៃការចែកចាយបានល្អ។ នៅក្នុងប្រទេសផ្សេងៗទៀត (ដូចជាសហព័ន្ធរុស្ស៊ី) ទីផ្សារទូលំទូលាយបានលក់សៀវភៅនៅក្នុងតំបន់មួយច្រើនជាងតំបន់មួយទៀត។ ការផលិតសៀវភៅសិក្សាឲ្យមានសមធម៌ ដោយរួមបញ្ចូលទាំងការលើកកំពស់ការបោះពុម្ពសៀវភៅនៅតាមតំបន់ទាមទារឲ្យមានកិច្ចសម្របសម្រួលខ្លាំងក្លាពីរដ្ឋាភិបាល ជាពិសេសតាមរយៈស្ថាប័នជំនាញថ្នាក់ជាតិ និងដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធ ផ្នែកឯកជន និងសង្គមស៊ីវិល ក៏ដូចជាអនុវត្ត ឬបង្កើតគោលនយោបាយថ្នាក់ជាតិស្តីពីសៀវភៅសិក្សា។ ការគាំទ្រខ្លាំងក្លាពីគោលនយោបាយជាតិធ្វើឲ្យរដ្ឋាភិបាលប្រទេសប្រេស៊ីលអាចផ្គត់ផ្គង់សៀវភៅសិក្សាសម្រាប់ដាក់បណ្ណាល័យនៅស្ទើរតែគ្រប់សាលាបឋមសិក្សាទាំងអស់តាមរយៈកម្មវិធីបណ្ណាល័យសៀវភៅសិក្សាថ្នាក់ជាតិ។

### បរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព និងទាក់ទាញអារម្មណ៍

ដើម្បីសម្រេចសកលកម្មអប់រំបឋមសិក្សាតម្រូវឲ្យប្រទេសនានាមានការរៀបចំតុបតែង និងកសាងបន្ទប់រៀន ដែលពុំធ្លាប់មានពីមុនមក។ សាលាត្រូវរៀបចំបង្កលក្ខណៈងាយស្រួលដល់សិស្សពិការ និងមានអគារ ឬបន្ទប់រៀនដើម្បីធានាឲ្យមានបរិយាកាសរៀនសូត្រប្រកបដោយផាសុកភាព។ ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ គឺជាកត្តាដ៏សំខាន់។ នៅអនុតំបន់សាហារ៉ាអាព្រិច រហូតមកដល់ពេលថ្មីៗ

គម្រោងសាងសង់សាលារៀនកម្រមានបញ្ចូលបង្គន់អនាម័យ ឬប្រព័ន្ធទឹកស្អាតណាស់។ ឧទាហរណ៍ នៅប្រទេសម៉ូរីតានី និងប្រទេសឆាដ ការបញ្ចូលបង្គន់អនាម័យ និងប្រពន្ធ័ទឹកទៅក្នុងគម្រោងសាងសង់សាលាបឋមសិក្សាបានកើតមានពីឆ្នាំ ២០០១-២០០២ ប៉ុណ្ណោះ។ ការថែទាំបង្គន់អនាម័យ និងប្រព័ន្ធទឹកគឺជាវិធានការដែលមានការចំណាយតិច ប៉ុន្តែជួយលើកកំពស់ជីវិត និងគុណភាពអគារសិក្សា។ តែទោះជាយ៉ាងនេះក៏ដោយ ក៏ការថែទាំជាញឹកញាប់ត្រូវបានគេមើលរំលងនៅក្នុងគម្រោងជំនួយ និងថវិការដ្ឋ។ ផ្ទុយទៅវិញ ការទទួលខុសត្រូវគឺជាបន្ទុករបស់សហគមន៍ដែលអាចខ្វះធនធានសម្រាប់ការថែទាំជាមូលដ្ឋាន។

## គ្រូបង្រៀន : ការវិនិយោគដ៏សំខាន់

ការធ្វើវិនិយោគលើគ្រូបង្រៀនដែលជាមនុស្សដ៏សំខាន់ក្នុងការកែទម្រង់វិស័យអប់រំដើម្បីលើកកំពស់គុណភាព គឺជាផ្នែកដ៏សំខាន់បំផុតនៅក្នុងថវិការដ្ឋ។ វិធីសាស្ត្រលើកកំពស់ការជ្រើសរើសគ្រូបង្រៀន ការបណ្តុះបណ្តាល និង លក្ខខណ្ឌការងាររបស់គ្រូបង្រៀនគឺជាបញ្ហានយោបាយដ៏សំខាន់។

### ការបណ្តុះបណ្តាលដែលត្រូវគិតគូរឡើងវិញ

ដើម្បីទាក់ទាញឲ្យមានបេក្ខជនគ្រូបង្រៀនទាំងក្នុងប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍបានបញ្ចុះស្តង់ដាសម្រាប់ជ្រើសរើសគ្រូឲ្យចូលរៀនក្នុងវគ្គបណ្តុះបណ្តាលគ្រូ។ ទោះបីជាជម្រើសនោះគួរតែត្រូវបានធ្វើឡើងដោយយកចិត្តទុកដាក់ក៏ដោយ ក៏នៅមានវិធីផ្សេងៗដែលមានលក្ខណៈបត់បែន និងទន់ភ្លន់សម្រាប់បញ្ចូលគ្រូទៅក្នុងវិជ្ជាជីវៈបង្រៀនបានដែរ។ ឧទាហរណ៍ ទេពកោសល្យ និង ចំណង់ចំណូលចិត្តគួរចាត់ទុកថាមានតម្លៃដូចគ្នាទៅនឹងការអប់រំក្នុងប្រព័ន្ធមួយចំនួនផងដែរ។

តាមវិធីសាស្ត្រគំរូដ៏សំខាន់នៃការបណ្តុះបណ្តាលដំបូងៗ ការអប់រំក្នុងប្រព័ន្ធត្រូវធ្វើឡើងពីឆ្នាំដំបូងរហូតដល់ឆ្នាំទី ៥ ដែលរយៈពេលនៃការបណ្តុះបណ្តាលជាក់ស្តែងអាចខ្លី ឬវែង ហើយជាញឹកញាប់មានការចំណាយច្រើន។ វិធីសាស្ត្រគំរូដែលទាក់ទងទៅនឹងផ្នែកអនុវត្តជាក់ស្តែងរយៈពេលវែងតម្រូវឲ្យមានសាលារៀនគ្រប់គ្រាន់ដែលមានសមត្ថភាពបណ្តុះបណ្តាលគ្រូបង្រៀន។ នៅប្រទេសគុយបា ការបណ្តុះបណ្តាលមុនពេលចូលបង្រៀនទាំងអស់ គឺធ្វើឡើងនៅតាមសាលារៀន។ ពេលខ្លះការបណ្តុះបណ្តាលដោយយកសាលាធ្វើជាមូលដ្ឋានអាចដាក់បញ្ចូលការរៀនសូត្រពីចម្ងាយ ប្រសិនបើសិក្ខាកាមគ្រូបង្រៀនទាំងនោះទទួលបានសម្ភាររៀនសូត្រ និងការគាំទ្រគ្រប់គ្រាន់។ កម្មវិធីបណ្តុះបណ្តាលនានាធ្វើការប៉ាន់ស្មានមិនបានត្រឹមត្រូវអំពីរយៈពេលដែលសិក្ខាកាមគ្រូត្រូវការដើម្បីយល់ដឹងឲ្យបានច្បាស់អំពីមុខវិជ្ជាដែលត្រូវយកទៅបង្រៀន។ សិក្ខាកាមគ្រូបង្រៀន ជាញឹកញាប់ ពុំបានស្វែងយល់ពីការពិតប្រចាំថ្ងៃនៅក្នុងសាលារៀនទេ។

អ្នកបង្កើតគោលនយោបាយនៅក្នុងប្រទេសនានាអាចពិចារណាពីតុល្យភាពរវាងការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលក្នុងពេលបំពេញការងារ។ គ្រូបង្រៀនដែលទើបតែបញ្ចប់ការបណ្តុះបណ្តាលតម្រូវឲ្យមានការគាំទ្រខ្លាំងក្លាជាពិសេស ក្នុងអំឡុងពេលនៃការបង្រៀនឆ្នាំដំបូង។ ទម្រង់វិនិយោគមានទំនោរទៅរកការបណ្តុះបណ្តាលគឺមានផលប្រយោជន៍ច្រើន។ ការគាំទ្របន្តឲ្យបានល្អ វិជ្ជាជីវៈគ្រូបង្រៀនគឺជារចនាសម្ព័ន្ធលើកទឹកចិត្ត ដែលធ្វើឲ្យគ្រូបង្រៀនមើលឃើញផលប្រយោជន៍លើការលើកកំពស់ការបង្រៀន ហើយជំរុញសាលាឲ្យគិតថាការលើកកំពស់ការរៀនសូត្រឲ្យល្អប្រសើរគឺជាមូលដ្ឋាននៃចក្ខុវិស័យអប់រំ។

### ការរកចំណូលថយចុះ

នៅក្នុងប្រទេសកំពុងអភិវឌ្ឍមួយចំនួន ការរកប្រាក់ចំណូលរបស់គ្រូបង្រៀនមានកម្រិតទាបខ្លាំងរហូតដល់មិនអាចមានកម្រិតជីវភាពសមរម្យ (មើលប្រអប់)។

**ប្រទេសសេរ៉ាឡេអូន : គ្រូបង្រៀនបឋមសិក្សាប្រឈមមុខនឹងការខ្វះខាតគ្រប់យ៉ាង**

នៅពេលបញ្ចប់សង្គ្រាមស៊ីវិលអស់ ១១ ឆ្នាំក្នុងប្រទេសសេរ៉ាឡេអូននៅឆ្នាំ ២០០១ ថ្លៃចំណាយសម្រាប់ការអប់រំត្រូវលុបចោល ហើយអាហារតាមសាលាត្រូវបានផ្តល់ជាទូទៅ ជាហេតុធ្វើឲ្យការចុះឈ្មោះចូលរៀននៅបឋមសិក្សាកើនឡើងយ៉ាងខ្លាំង។ ការចុះឈ្មោះចូលរៀនបានកើនឡើង ៣ ដង ក្នុងរយៈពេលតិចជាង ៤ ឆ្នាំ។ មួយថ្នាក់មានសិស្សជាង ៧០ នាក់។ គ្រូបង្រៀនបឋមសិក្សាជាង ២០% នៅសាលារដ្ឋពុំមានឈ្មោះក្នុងបញ្ជីទទួលប្រាក់កម្រៃពីរដ្ឋ។ គ្រូភាគច្រើនជាគ្រូស្ម័គ្រចិត្តដោយទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈបន្តិចបន្តួច ឬពុំបានទទួលសោះ។ គ្រូមួយចំនួនទទួលប្រាក់ឧបត្ថម្ភពីសហគមន៍។ ប្រាក់ខែគ្រូបឋមសិក្សារបស់រដ្ឋនៅចុងឆ្នាំ ២០០៣ ជាមធ្យមបានប្រហែល ៥០ ដុល្លាអាមេរិក។ តាមពិត ប្រាក់ខែគ្រូបានធ្លាក់ចុះច្រើនជាងពាក់កណ្តាលចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ ១៩៩០។ គ្រូភាគច្រើនមានបន្ទុកចិញ្ចឹមសមាជិកគ្រួសារពី ៤ ទៅ ៥ នាក់ ជាមួយនឹងប្រាក់ចំណូលតិចជាង ២ ដុល្លាក្នុងមួយថ្ងៃ។ ការបើកប្រាក់ខែជាញឹកញាប់យឺត។ គ្រូនៅទីក្រុងអាចរកប្រាក់ចំណូលបន្ថែមតាមរយៈការបង្រៀនឯកជន។ គ្រូមួយចំនួនមិនបង្រៀនសិស្សតាមកម្មវិធីឲ្យបានពេញលេញទេ ផ្ទុយទៅវិញបង្ខំសិស្សឲ្យចូលរៀនឯកជន។ គ្រូនៅជនបទជាធម្មតាលក់នំ និងស្ករគ្រាប់ឲ្យសិស្សនៅពេលសំរាក។ ទោះជាសីលធម៌គ្រូធ្លាក់ចុះក្តី គ្រូធ្លាប់អវត្តមាន ២០% នៅចុងឆ្នាំ ២០០១ ហាក់ដូចជាធ្លាក់ចុះបន្តិច។

ក្នុងរយៈពេលកន្លងទៅនេះ ប្រាក់ចំណូលរបស់គ្រូបានធ្លាក់ចុះ។ នៅក្នុងប្រទេសកំពុងអភិវឌ្ឍប្រាក់ខែគ្រូបឋមសិក្សាជាមធ្យមភាគនៅឆ្នាំ ១៩៧៥ គឺច្រើនជាង ៦ ដងនៃផលិតផលក្នុងស្រុកសរុបរបស់មនុស្សម្នាក់ៗ ប៉ុន្តែនៅឆ្នាំ ២០០០ អត្រានេះត្រូវធ្លាក់ចុះស្ទើរតែពាក់កណ្តាល។ និន្នាការនេះត្រូវបានកត់សំគាល់ឃើញជាពិសេសនៅអាព្រិចនិយាយភាសាបារាំង ដែលនៅទីនោះអត្រានេះបានធ្លាក់ចុះរហូតដល់ ១/៣ (មើលតារាង ៤.១)។

**នៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន ប្រាក់ខែគ្រូទិចតួចមិនគ្រប់គ្រាន់សម្រាប់ជីវភាពសមរម្យទេ**

នៅប្រទេសដែលមានចំណូលមធ្យម និងចំណូលខ្ពស់មួយចំនួន គ្រូបង្រៀនក្លាយជាក្រុមអ្នកមានរហូតដល់ទស្សវត្សរ៍ ១៩៩០ ចំណែកគ្រូបង្រៀននៅប្រទេសដែលមានប្រាក់ចំណូលទាបមួយចំនួន ប្រាក់ចំណូលពិតរបស់គ្រូបង្រៀនត្រូវធ្លាក់ចុះប្រមាណ ២០%។ នៅប្រទេសជាច្រើននៅអាព្រិច ប្រាក់ចំណូលរបស់គ្រូបង្រៀនក្នុងឆ្នាំ ២០០០ ទទួលបានតិចជាងកាលពីអំលុងឆ្នាំ ១៩៧០។

**តារាង ៤.១ : ផលធៀបប្រាក់ខែគ្រូបឋមសិក្សា និងផលិតផលជាតិសរុបតាមតំបន់ ១៩៧៥–២០០០ (ប្រទេសមានប្រាក់ចំណូលក្រោម ២០០០ ដុល្លាអាមេរិក ១៩៩៣)**

| | ១៩៧៥ | ១៩៨៥ | ១៩៩២ | ២០០០ |
|---|---|---|---|---|
| ប្រទេសដែលមានប្រាក់ចំណូលក្រោម២០០០ ដុល្លាក្នុងមួយឆ្នាំ | ៦.៦ | ៤.៦ | ៤.៣ | ៣.៧ |
| អាព្រិច | ៨.៦ | ៦.៣ | ៦.០ | ៤.៤ |
| និយាយភាសាអង់គ្លេស | ៤.៤ | ៣.៥ | ៣.៦ | ៤.២ |
| និយាយភាសាបារាំង | ១១.៥ | ៨.០ | ៦.៣ | ៤.៨ |
| និយាយភាសាសាហែល | ១៧.៦ | ១១.៨ | ៨.២ | ៦.៤ |
| អាស៊ី | ៣.៧ | ២.៧ | ២.៥ | ២.៩ |
| អាមេរិកឡាទីន | ២.៧ | ២.៩ | ២.៣ | ២.៣ |
| មជ្ឈឹមបូព៌ា និងអាព្រិចខាងជើង | ៥.៦ | ២.៨ | ៣.៣ | ៣.៣ |

ប្រភព : ជំពូក ៤ របាយការណ៍អប់រំសម្រាប់ទាំងអស់គ្នា

ដំណើរឆ្ពោះទៅកាត់បន្ថយកម្រិតមធ្យមភាគនៃចំណូលរបស់គ្រូបង្រៀនបង្កការលំបាក ហើយប៉ះពាល់ដល់គុណភាពអប់រំធ្ងន់ធ្ងរ។ បន្ទុកនៃការចំណាយលើប្រាក់ខែអាចកាត់បន្ថយបានបន្តិចបន្តួចតាមរយៈវិធានការផ្សេងៗ ដូចជា ពង្រីកថ្នាក់ឲ្យធំ (បើធ្វើបាន) បង្រៀនចម្រុះថ្នាក់ និងការបង្រៀនដោយការមានការផ្លាស់ប្តូរវេន ប្រសិនអាចអនុវត្តដោយយកចិត្តទុកដាក់ទៅតាមកាលៈទេសៈសមស្រប។

## ការទាក់ទាញគ្រូបង្រៀន

ដើម្បីសម្រេចសកលកម្មអប់រំបឋមសិក្សាតម្រូវឲ្យមានគ្រូបន្ថែមច្រើននាក់។ អត្រាផលធៀបសិស្ស និងគ្រូ (៦០:១) ឬច្រើនជាងនេះត្រូវបានកត់ត្រាទុកនៅក្នុងប្រទេសជាច្រើន ដែលការចុះឈ្មោះចូលរៀនមានការកើនឡើងនៅពេលថ្មីៗនេះ។ ប្រទេសមួយចំនួននៅអាព្រិច និងអាស៊ីជ្រើសរើសគ្រូបំរុងជាប់កិច្ចសន្យារយៈពេលខ្លី ហើយគ្រូទាំងនោះទទួលបានប្រាក់ខែ និងកម្រៃផ្សេងៗតិចជាងសមភាគីគ្រូបង្រៀនអាជីព។ រដ្ឋាភិបាលកំពុងប្រឈមមុខនឹងការលំបាកក្នុងការទ្រទ្រង់គ្រូទាំងនោះដោយមិនបានពង្រឹងលក្ខខណ្ឌសេវាកម្មរបស់គ្រូអាជីពឡើយ។

**គួររៀបចំឲ្យមានជំនួយលើកទឹកចិត្តដល់គ្រូធ្វើដូចនេះ សាលាតាមជនបទដាច់ស្រយាលនឹងមានគ្រូដែលមានសមត្ថភាពគ្រប់គ្រាន់**

តម្រូវការក្របខណ្ឌការងារថ្នាក់ជាតិដែលមានការកំណត់ច្បាស់លាស់ដើម្បីធានាថា សាលាទាំងអស់មានបុគ្គលិកបំរើការងារគ្រប់គ្រាន់។ ការបញ្ជូនគ្រូទៅបង្រៀននៅសាលាជនបទ ដែលគ្រូទាំងនោះមិនអាចប្រើប្រាស់ភាសាមូលដ្ឋានច្បាស់លាស់អាចនាំឲ្យប៉ះពាល់ដល់គុណភាពនៃការអប់រំ។ ត្រូវការឲ្យមានការលើកចិត្ត (ដូចជា ឱកាសសម្រាប់ការរៀនសូត្របន្ថែម ជួយកន្លែងស្នាក់នៅ) ដើម្បីបំរើការងារនៅតាមទីកន្លែងដាច់ស្រយាលដើម្បីធានាថា សាលាទាំងអស់មានគ្រូបង្រៀនដែលមានកម្រិតវប្បធម៌ខ្ពស់។

## សាលាល្អ

គំនិតកែលំអសាលារៀនទាំងស្រុងដែលមានលក្ខណៈខុសគ្នាពីការពង្រឹងធនធាន ឬដំណើរការ សាលានីមួយៗបានទទួលការគាំទ្រនៅទូទាំងសកលលោក។ គំនិតនោះបង្ហាញពីការចាប់អារម្មណ៍ តាមក្របខ័ណ្ឌផ្សេងៗគ្នា ប៉ុន្តែមានទំនាក់ទំនងគ្នាទៅវិញទៅមក ដូចជា *ការលើកកំពស់សាលា ការអភិវឌ្ឍសាលាទាំងមូល និងសាលាដែលសិស្សចូលចិត្ត*។ គំរូបែបនេះប្រហែលជាអាចបង្ហាញពីការផ្តល់ស្វយ័តភាពច្រើនឡើងដល់សាលារៀន។ ការអះអាងគំនិតស្វ័យភាពនេះគឺថា សិទ្ធិសេរីភាពច្រើនជួយផ្តល់អំណាចដល់គ្រូបង្រៀនកាត់បន្ថយរបៀបធ្វើការបែប

រៀននៅសំយ៉ាបសាលានៅប្រទេសប៉ាគីស្ថាន


© R. & S. MICHAUD/RAPHO

ការិយាធិបតេយ្យ និងអំណាចនៃការធ្វើសេចក្តីសម្រេច។ ទោះជាយ៉ាងនេះក៏ដោយ រហូតមកដល់ពេលនេះពុំទាន់មានភស្តុតាងគ្រប់គ្រាន់អំពីឥទ្ធិពលនៃសាលាស្វយ័តទៅលើលទ្ធផលនៃការអប់រំនៅឡើយ។ កិច្ចព្រមព្រៀងរួមមួយបញ្ជាក់ថា លក្ខខណ្ឌមួយចំនួនត្រូវការបង្កើតឲ្យមានជាចាំបាច់ ប្រសិនបើត្រូវការលើកកំពស់គុណភាពអប់រំក្នុងសាលាស្វយ័ត។ លក្ខខណ្ឌទាំងនោះតម្រូវឲ្យមានយុទ្ធសាស្ត្ររដ្ឋាភិបាលកណ្តាលប្រកបដោយការគាំទ្រ និងច្បាស់លាស់ដើម្បីពង្រឹងសមត្ថភាព និងផ្តល់ការគាំទ្រផ្នែកវិជ្ជាជីវៈបង្រៀនដល់សាលា និងធានាឲ្យមានតម្លាភាព។ កត្តាជាគន្លឹះផ្សេងៗទៀតមានរចនាសម្ព័ន្ធត្រួតពិនិត្យតាមដាន និងធានាថា សាលាទាំងនោះទទួលបានព័ត៌មានគ្រប់គ្រាន់ទាក់ទងនឹងសកម្មភាពអនុវត្ត។

អ្នកដឹកនាំគ្រូបង្រៀនគឺជាមនុស្សដ៏សំខាន់សម្រាប់ជំរុញកិច្ចខិតខំប្រឹងប្រែងនេះ មានន័យថា ចរិតនៃការដឹកនាំរបស់គេអាចមានឥទ្ធិពលយ៉ាងខ្លាំងក្លាលើគុណភាពអប់រំ។ នៅក្នុងប្រទេសអភិវឌ្ឍមានស្ថានប័នជំនាញសម្រាប់ដុសខាត់ជំនាញដឹកនាំ គ្រប់គ្រងសាលា។ ការនេះកម្រកើតមាននៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាបណាស់ ផ្ទុយទៅវិញ នៅក្នុងប្រទេសទាំងនោះ ការតែងតាំងគ្រូឲ្យទៅជាអ្នកដឹកនាំពុំបានផ្តល់ការបណ្តុះបណ្តាលថែមទៀតអ្វីឡើយ។ ទោះជាយ៉ាងនេះក៏ដោយ ក៏និន្នាការទៅរកស្វ័យភាពទូលំទូលាយគឺមានន័យថា អ្នកដឹកនាំសាលាគួរមានតួនាទីគ្រប់គ្រងថ្មី និងស្មុគស្មាញជាងមុន។ អាព្រិចខាងត្បូងកំពុងបង្កើតគោលនយោបាយមួយស្តីពីការពង្រឹងថ្នាក់ដឹកនាំសាលា ហើយកម្មវិធីគ្រប់គ្រងសាលាបឋមសិក្សានៅប្រទេសកេនយ៉ា (PRISM) ក៏អភិវឌ្ឍជំនាញដល់គ្រូចំនួន ១៦៧០០ នាក់។ នៅក្នុងការកែទម្រង់ណាមួយសំដៅលើស្វ័យភាពទូលំទូលាយចាំបាច់ត្រូវកំណត់ការទទួលខុសត្រូវឲ្យបានច្បាស់លាស់។ ប្រសិនបើគ្មានគោលនយោបាយថ្នាក់ជាតិដ៏មានប្រសិទ្ធភាពទេ លទ្ធភាពនៃការអនុវត្តការងារខុសគ្នាពីសាលាមួយទៅសាលាមួយទៀតនឹងអាចកើតមានឡើងជាមិនខាន។

នៅក្នុងប្រទេសកំពុងអភិវឌ្ឍជាច្រើន ស្ថាប័នអប់រំចាំបាច់ត្រូវសម្រេចចិត្តដ៏លំបាកអំពីវិធីដើម្បីប្រើប្រាស់ធនធានដ៏កម្រឲ្យមានប្រសិទ្ធភាពបំផុត ជាពិសេសនៅក្នុងប្រទេសដែលអត្រាសិស្សចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាមានការកើនឡើងយ៉ាងឆាប់រហ័យ ប៉ុន្តែពុំមានការផ្តល់មូលនិធិថ្មីបន្ថែម។ ការផ្តល់ការអប់រំតាមរយៈកម្មវិធីផ្លាស់ប្តូរម៉ោងរៀនគឺជាជម្រើសមួយដែលអាចលើកកំពស់ការផ្គត់ផ្គង់ទីកន្លែងរៀនសូត្រ និងប្រើប្រាស់ធនធានដែលមានស្រាប់ ដូចជា អគារសិក្សា សម្ភារផ្សេងៗ សៀវភៅ និងគ្រូបង្រៀន។ ការធ្វើដូច្នេះនឹងដាក់សម្ពាធធ្ងន់ធ្ងរទៅលើអ្នកដឹកនាំសាលា ហើយអាចធ្វើឲ្យគុណភាពអប់រំធ្លាក់ចុះ។ ការផ្តល់ការអប់រំតាមរយៈកម្មវិធីផ្លាស់ប្តូរម៉ោងរៀនសូត្រត្រូវការចាំបាច់នូវការរៀបចំកម្មវិធីឲ្យបានល្អិតល្អន់ និងមានរចនាសម្ព័ន្ធគ្រប់គ្រងសមស្រប។

## ការឧបត្ថម្ភគាំទ្រសាលារៀន ត្រូវមានក្នុងគោលនយោបាយ

លទ្ធភាពទទួលចំណេះដឹងអំពីសកម្មភាពនានាដែលអាចអនុវត្តបានដើម្បីលើកកំពស់គុណភាពអប់រំអាចធ្វើឲ្យមានការប្រែប្រួលគួរជាទីកត់សំគាល់។ អ្នកជាប់ពាក់ព័ន្ធ និងស្ថាប័នជាប់ពាក់ព័ន្ធក្នុងការបង្កើត និងចែករំលែកចំណេះដឹងអាចបង្កើតហេដ្ឋារចនាសម្ព័ន្ធចំណេះដឹងថ្នាក់ជាតិបាន។ ដើម្បីលើកកំពស់ទំនាក់ទំនងនៃការស្រាវជ្រាវអំពីការអប់រំរវាងប្រទេសមួយចំនួន ដូចជា អាព្រិចខាងត្បូង និងប្រទេសតង់ហ្សានីបានបង្កើតឲ្យមានស្ថាប័នដែលមានការចូលរួមពីអ្នកធ្វើគោលនយោបាយ គ្រូបង្រៀន បណ្ឌិតសភា និងតំណាងរបស់អង្គការក្រៅរដ្ឋាភិបាល និងភ្នាក់ងារផ្តល់ជំនួយទាំងឡាយ។ ការស្រាវជ្រាវអំពីសកម្មភាព

ការងារក៏អាចជួយកាត់បន្ថយគម្លាតរវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង និងនាំទៅរកដំណោះស្រាយតាមវិធីសាស្ត្រមូលដ្ឋាន។ ប្រទេសជាច្រើនបានដាក់បញ្ចូលគ្នានូវស្ថាប័នវិជ្ជាជីវៈ និងស្ថាប័នទីប្រឹក្សាដើម្បីជួយសាលារៀន។ ស្ថាប័នទាំងនោះរួមមានមជ្ឈមណ្ឌលធនធានគ្រូបង្រៀនដែលមានតួនាទីផ្តល់ធនធានសម្រាប់បង្រៀន និងលើកកំពស់ការចែករំលែកគំនិតល្អៗផ្សេងៗក្នុងចំណោមគ្រូបង្រៀន អ្នកផ្តល់ការអប់រំ និងអ្នកបង្កើតគោលនយោបាយ។ វិនិយោគសម្រាប់បណ្តុះបណ្តាលការងារ និងកម្មវិធីកែប្រែដែលបានរៀបចំឡើងសម្រាប់បង្កើត និងចែករំលែកចំណេះដឹងអំពីការអប់រំអាចទទួលបានលទ្ធផលយ៉ាងប្រសើរតាមរយៈការជួយសាលាឲ្យរៀនសូត្រពីគ្នាទៅវិញទៅមក និងប្រើប្រាស់ឲ្យអស់លទ្ធភាពនូវធនធានដែលមានតិចតួច។ វិនិយោគនេះអាចជួយបង្កើតវប្បធម៌នៃការលើកកំពស់គុណភាពដោយឈរលើមូលដ្ឋានចំណេះដឹង និង ភស្តុតាងពាក់ព័ន្ធ។

## នយោបាយកែទម្រង់

ការកែប្រែ ឬកែទម្រង់គោលនយោបាយអប់រំណាមួយមានទំនាក់ទំនងនឹងការចំណាយ ប៉ុន្តែការដោះស្រាយលើការចំណាយនោះអាចធ្វើទៅបាន បន្ទាប់ពីមានការឯកភាពគ្នានៅថ្នាក់ជាតិអំពីគុណភាពនៃការអប់រំសិន។ បន្ទាប់ពីបានបំពេញតម្រូវការគោលនយោបាយនេះរួចហើយ គួរកំណត់ផ្នែកជាអាទិភាពដោយផ្អែកលើវិធីសាស្ត្រទូលំទូលាយមួយ។ ការកែទម្រង់អប់រំប្រកបដោយជោគជ័យអាចសម្រេចទៅបានក្នុងបរិបទនយោបាយទូលំទូលាយ និងក្នុងសង្គមដែលមានកម្រិតទ្រព្យធនខុសៗគ្នា។ នៅក្នុងចំណោមបញ្ហានានា ដែលមានឥទ្ធិពលផ្ទាល់ទៅលើថាតើការកែទម្រង់ដែលបានរៀបចំឡើងសម្រាប់លើកកំពស់គុណភាពអប់រំនឹងធ្វើឲ្យមានភាពខុសប្លែកឬយ៉ាងណានោះ កត្តាបីយ៉ាងដែលត្រូវយកចិត្តទុកដាក់យ៉ាងពិសេសគឺ ការបង្កើតដៃគូការងារជាមួយគ្រូបង្រៀន និងភាគីពាក់ព័ន្ធ ការពង្រឹងការទទួលខុសត្រូវ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ។

**ការកែទម្រង់អប់រំប្រកបដោយជោគជ័យអាចសម្រេចទៅបានក្នុងបរិបទនយោបាយទូលំទូលាយ និងក្នុងសង្គមដែលមានកម្រិតទ្រព្យធនខុសៗគ្នា**

## ភាពចន្លោះសម្រាប់ពិគ្រោះយោបល់

ទោះបីគ្រូមានមុខងារសំខាន់ក្នុងការលើកកំពស់គុណភាពអប់រំ ក៏ការចូលរួមរបស់គ្រូក្នុងក្រុមវិជ្ជាជីវៈ ជាពិសេសតាមរយៈសហជីពគ្រូបង្រៀន និងសមាគមវិជ្ជាជីវៈគឺជាការសំខាន់មិនអាចខ្វះបាន។ កម្រិតនៃការចូលរួមក្នុងការចរចាលើលក្ខខណ្ឌសេវាកម្មផ្សេងៗរបស់សហជីពគ្រូបង្រៀនមានលក្ខណៈខុសគ្នាធំមហិមាពីតំបន់មួយទៅតំបន់មួយ និងពីប្រទេសមួយទៅប្រទេសមួយ។ ការកកើតនៃរដ្ឋាភិបាលប្រកាន់លទ្ធិប្រជាធិបតេយ្យនៅអាមេរិកឡាទីនបានធ្វើឲ្យមានការកែលំអស្ថានភាពនៅទីនោះគួរជាទីចាប់អារម្មណ៍។ ចំណែកឯប្រទេសដែលកំពុងពង្រឹងលទ្ធិប្រជាធិបតេយ្យ (ដូចជាប្រទេសនៅអឺរ៉ុបខាងកើត និងអាព្រិចខាងត្បូង) ប្រឈមមុខនឹងបញ្ហាកសាងវប្បធម៌ពិភាក្សាចរចា។ រដ្ឋអារ៉ាប់ និងប្រទេសនៅអាស៊ីមួយចំនួនត្រូវប្រឹងប្រែងជាងប្រទេសខាងលើ។ សមត្ថភាពរបស់គ្រូបង្រៀនដើម្បីធ្វើការស្រាវជ្រាវក៏ត្រូវការឲ្យមានការគាំទ្រជាចាំបាច់ដែរ។ នៅលើឆាកអន្តរជាតិ កិច្ចពិភាក្សាដែលងាយសាបសូន្យ ប៉ុន្តែផ្តល់ក្តីសង្ឃឹមកំពុងដំណើរការដោយមានការចូលរួមពីអ្នកផ្តល់ជំនួយ សមាគមគ្រូបង្រៀន និងអង្គការក្រៅរដ្ឋាភិបាល។ ការឆ្លុះបញ្ចាំងពីកិច្ចពិភាក្សានេះមានលើកឡើងនៅក្នុងការពិនិត្យមើលឡើងវិញនៃការចូលរួមរបស់សហជីពគ្រូបង្រៀនក្នុងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលបានធ្វើនៅប្រទេសចំនួន ២៣ គាំទ្រដោយធនាគារពិភពលោក។

## ត្រូវមានគណនេយ្យភាពសម្រាប់មនុស្សគ្រប់រូប

ក្រុមសីលធម៌អាចជួយលើកកំពស់គុណភាពអប់រំដោយកំណត់ស្តង់ដាសីលធម៌ និងចែងគោលការណ៍គណនេយ្យភាពប្រកបដោយការយោគយល់គ្នា។ ជាធម្មតាក្រុមសីលធម៌ទាំងនោះពាក់ព័ន្ធនឹងបញ្ហានានា ដូចជាការអនុញ្ញាតឲ្យចូលរៀន លក្ខខណ្ឌការងាររបស់គ្រូ និងបុគ្គលិកសិក្សាដទៃទៀត ការប្រលង វិធីសាស្ត្រវាយតម្លៃ និងការស្វែងរកធនធាន។ ក្រុមសីលធម៌មួយចំនួនគ្របដណ្តប់ទៅលើប្រព័ន្ធអប់រំទាំងមូល និងក្រុមសីលធម៌មួយចំនួនទៀតទាក់ទងតែទៅលើគ្រូបង្រៀន។ ជាទូទៅ ក្រសួងអប់រំទទួលខុសត្រូវលើការពង្រឹងក្រុមសីលធម៌ទាំងនោះ។ ដើម្បីពង្រឹងក្រុមសីលធម៌មានឲ្យប្រសិទ្ធភាព ត្រូវបង្កើតឲ្យមានកិច្ចសហការជាមួយក្រុមវិជ្ជាជីវៈគ្រូបង្រៀន និងផ្សព្វផ្សាយឲ្យបានទូលំទូលាយ ព្រមទាំងតម្រូវឲ្យមានយន្តការច្បាស់លាស់សម្រាប់ធ្វើបណ្តឹង។ នៅពេលមានការយល់ច្បាស់ ហើយក្រុមសីលធម៌ទាំងនោះអាចជួយលើកកំពស់បរិយាកាសរៀនសូត្រក្នុងសាលារៀនជួយពង្រឹងការប្តេជ្ញាចិត្តបំរើការងាររបស់គ្រូបង្រៀនឲ្យកាន់តែមានប្រសិទ្ធភាព។

## ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

ការស្រាវជ្រាវជាច្រើនក្នុងអំឡុងពេលមួយទសវត្សរ៍កន្លងទៅបានយកចិត្តទុកដាក់ជាសំខាន់ទៅលើឥទ្ធិពលអវិជ្ជមាននៃអំពើពុករលួយទៅលើការអភិវឌ្ឍ។ អំពើពុករលួយដើម្បីរស់ និងអំពើពុករលួយគួរតែត្រូវបែងចែកឲ្យបានច្បាស់លាស់។ "អំពើពុករលួយដើម្បីរស់" គឺជាទម្រង់នៃការរកប្រាក់ខុសច្បាប់កម្រិតស្រាលដែលជាញឹកញាប់កើតចេញពីតម្រូវការចាំបាច់ដើម្បីរស់ ដូចជានៅពេលគ្រូបង្រៀនម្នាក់ខកខានមិនបានបង្រៀនសិស្ស ដោយសារគ្រូជាប់រវល់រកប្រាក់ដើម្បីបង្គ្រប់ប្រាក់ខែតិចតួច ឬបើកមិនទាន់ពេលវេលា។ "អំពើពុករលួយ" គឺជាទម្រង់នៃការរកប្រាក់ខុសច្បាប់កម្រិតធ្ងន់ធ្ងរ។ វិមជ្ឈការ ឯកជនភាវូបនីកម្ម និងការជួលគ្រូពីខាងក្រៅសាលាមកបង្រៀននាំទៅរកឱកាសថ្មីៗក្នុងការប្រព្រឹត្តអំពើពុករលួយ។ ការប្រព្រឹត្តអំពើពុករលួយអាចទាក់ទងទៅនឹងការលួចបន្លំ និងកេងប្រវ័ញ្ចនៅតាមផ្នែកផ្សេងៗ ដូចជាការសាងសង់សាលា ការផ្គត់ផ្គង់សៀវភៅ ការបង់លុយនៅពេលបើប្រាក់ ការបង់ប្រាក់សម្រាប់ធ្វើការងារនៅសាលា ឬសម្រាប់ឲ្យលទ្ធផលប្រលងខ្ពស់ដល់សិស្សខ្សោយ និងបក្សពួកនិយមក្នុងការជ្រើសរើសគ្រូ។ វិធានការ និងវិធីសាស្ត្រដែលមានប្រសិទ្ធភាពសម្រាប់បំបាត់អំពើពុករលួយមានការអនុវត្តច្បាប់ (ដោយមានបញ្ចូលទាំងការពង្រឹងសមត្ថភាព តាមស្ថាប័នដើម្បីពង្រឹងការអនុវត្តច្បាប់នោះ) និងការលើកកំពស់ភាពជាម្ចាស់នៃដំណើរការគ្រប់គ្រង។ ជំរុញសហគមន៍ឲ្យចេះដាក់សម្ពាធទៅលើអាជ្ញាធរដើម្បីដោះស្រាយអំពើពុករលួយនេះ។

ផ្នែកផ្សេងៗនៃគោលនយោបាយទាំងឡាយដែលបានរៀបរាប់នៅក្នុងជំពូកនេះឆ្លុះបញ្ចាំងឲ្យឃើញអំពីការអនុវត្តគោលនយោបាយលើកកំពស់គុណភាពអប់រំនៅជុំវិញពិភពលោកនេះ។ គំនិតពាក់ព័ន្ធសំខាន់រួមមាន ការយល់ដឹងអំពីតម្រូវការផ្សេងៗរបស់សិស្ស និងការគាំទ្រដល់ការកែទម្រង់ដែលយកចិត្តទុកដាក់លើលទ្ធផលខ្ពស់នៃការបង្រៀន និងរៀន ដូចជា ខ្លឹមសារមេរៀនពាក់ព័ន្ធ ពេលវេលារៀនសូត្រគ្រប់គ្រាន់ វិធីសាស្ត្របង្រៀនក្នុងថ្នាក់ដោយយកសិស្សជាគោលមជ្ឈមណ្ឌល និងការវាយតម្លៃ។ ការគាំទ្រដល់គ្រូបង្រៀនគឺជាការចាំបាច់ ហើយត្រូវធានាថា សាលាមានការគ្រប់គ្រងល្អ។ យុទ្ធសាស្ត្រទាំងនេះត្រូវតែមានលក្ខណៈសមស្របទៅនឹងចក្ខុវិស័យនៃការអប់រំយូរអង្វែង សមស្រប និងស៊ីចង្វាក់គ្នាដែលកើតចេញពីចំណេះដឹងរួមគ្នា។ យុទ្ធសាស្ត្រទាំងនេះត្រូវតែទទួលបានការគាំទ្រ និងលើកទឹកចិត្តពីឆន្ទៈនយោបាយរឹងមាំ និងពីធនធានគ្រប់គ្រាន់។

ជំពូក ៥

# ឆ្លើយតបនឹងការប្ដេជ្ញាជាអន្តរជាតិរបស់យើងទាំងអស់គ្នា



© Agnad Nasood/REUTERS

ស្ថាបនាប្រព័ន្ធអប់រំឡើងវិញ គឺជាមូលដ្ឋានគ្រឹះសម្រាប់កសាងសង្គមឡើងវិញនៅអាហ្គានីស្ថាន ឆ្នាំ

- ស្ថានភាពនៃការផ្ដល់ជំនួយ : នៅតិចតួចណាស់
- វាយតម្លៃប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយ
- តើជំនួយផ្ដោតលើសមភាពឬទេ?
- ការចាយវាយដែលទាក់ទងនឹងអ្នកផ្ដល់ជំនួយពហុភាគី
- កិច្ចខិតខំប្រឹងប្រែងដើម្បីឲ្យមានភាពស៊ីចង្វាក់គ្នា
- ការផ្ដួចផ្ដើមគំនិតដើម្បីពន្លឿនដំណើរការ : ឆ្នាំទី ៣

កាតព្វកិច្ចចំពោះមុខទាំងទ្វេដែលត្រូវបំពេញឲ្យបានគឺការពង្រឹងគុណភាព និងការពង្រីកឱកាសចូលរៀនឲ្យបានស្មើគ្នាទាមទារឲ្យមានការវិនិយោគដែលមាននិរន្តរភាព ដែលហួសពីសមត្ថភាពរបស់ប្រទេសមួយចំនួនធំ។ ជំពូកនេះនិយាយទាក់ទងនឹងបញ្ហាជំនួយ វិភាគពីការប្រឹងប្រែងដើម្បីពង្រឹងកិច្ចសហការរវាងអ្នកផ្ដល់ជំនួយ និងរដ្ឋាភិបាល និងតាមដានពិនិត្យភស្ដុតាងនៃប្រសិទ្ធភាពក្នុងការប្រើប្រាស់ជំនួយសម្រាប់ការអប់រំ។

## រូបភាពទូទៅ

ជំនួយសម្រាប់អភិវឌ្ឍន៍មានការកើនឡើងវិញ ដោយមានការបែងចែកសរុបជិត ៦ កោដិដុល្លាអាមេរិកនៅឆ្នាំ២០០២។ នេះគឺជាចំនួនដ៏ច្រើនជាងគេគិតចាប់តាំងពីឆ្នាំ ១៩៩២ មក។ ការកើនឡើងវិញនេះបង្ហាញពីការកើនឡើងនៃការផ្តល់ជំនួយទ្វេភាគី និងប្រហែលជាអាចដោយសារការសន្យាដែលគេបានធ្វើនៅឯសន្និសីទអន្តរជាតិស្តីពីហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍនៅឆ្នាំ ២០០២ នៅម៉ុងតេរី។ ប្រសិនជាគេអាចបំពេញបាននូវរាល់ការសន្យាទាំងអស់ដែលគេបានធ្វើនៅម៉ុងតេរី ជំនួយអាចឡើងរហូតដល់ ១៦ កោដិដុល្លាអាមេរិក – ពោលគឺ ប្រហែល ៣០% នៅត្រឹមឆ្នាំ ២០០៦។ ទោះបីជាជំនួយហាក់ដូចជាច្រើនសន្ធឹកសន្ធាប់ក៏ដោយ ក៏ចំនួននេះនៅតែតិចជាងចំនួនដែលគេគិតទុកដើម្បីសម្រេចគោលដៅអប់រំទាំង ៦ ដែលមានចំនួនប្រហែលជា ៥០ កោដិក្នុងមួយឆ្នាំ។ គ្មានការធានាណាមួយទេថា នឹងមានថវិកាបន្ថែមសម្រាប់គោលដៅអភិវឌ្ឍន៍ធនធានមនុស្សដូចជាការអប់រំសម្រាប់ទាំងអស់គ្នាជាដើម។

## ជំនួយទ្វេភាគី : សញ្ញានៃការកើនឡើង

ជំនួយទ្វេភាគីកំពុងតែកើនឡើង[៧] : នៅឆ្នាំ ២០០២ ចំនួនកើនឡើងលើសពី ៤ កោដិដុល្លាអាមេរិក។ នេះគឺជាការកើនឡើងលើកទី ១ ចាប់តាំងពី ឆ្នាំ ១៩៩៩ មក (មើលក្រាហ្វ ៥.១)។ ចំនួននេះតំណាងឲ្យប្រហែល ៩% នៃជំនួយអភិវឌ្ឍន៍ផ្លូវការសរុប។ គេសង្ឃឹមថា ចំណែកនេះនឹងមានការកើនឡើង បើតាមការសន្យាដែលគេបានធ្វើនៅក្នុងវិស័យអប់រំចាប់តាំងពីកិច្ចប្រជុំដាកាមក។ នៅឆ្នាំ ២០០១ និង ២០០២ ប្រទេសចំនួន ៨[៨] ប្តេជ្ញាផ្តល់យ៉ាងហោចណាស់ក៏ ១០០ លានដុល្លាដែរដល់វិស័យអប់រំទាំងអស់បញ្ចូលគ្នាទៅមានប្រហែលចំនួន ៨៥% នៃជំនួយអប់រំទ្វេភាគី។ ជំនួយអប់រំទ្វេភាគីទាំងអស់ច្រើនផ្តល់ទៅអនុតំបន់អាព្រិចសាហារ៉ា (៣០%) អាស៊ីបូព៌ា និងប៉ាស៊ីភិក (២៧%) និងរដ្ឋអារ៉ាប់ (១៨%)។

គេអាចវិភាគអាទិភាពដែលអ្នកផ្តល់ជំនួយផ្តល់ដល់ការអប់រំ[៩] ទោះបីជាគេត្រូវចងចាំថា នីតិវិធីធ្វើរបាយការណ៍អន្តរជាតិអាចប៉ាន់ប្រមាណជំនួយអប់រំទាបក៏ដោយ ដោយសារតែនិន្នាការចំពោះជំនួយដែលគាំទ្រថវិកាទូទៅ និងគម្រោងដែលមានសម្រាប់ច្រើនជាងមួយវិស័យក៏ដោយ។ ប្រទេសនូវែលសេឡង់ផ្តល់អាទិភាពចំនួន ៣.៥ ដងច្រើនជាងមធ្យមរបស់ប្រទេស OECD-DAC។ សហរដ្ឋអាមេរិកផ្តល់អាទិភាពតិចចំពោះការអប់រំនៅក្នុងកញ្ចប់ផ្តល់ជំនួយរបស់ខ្លួន។ ក្នុងចំណោមប្រទេសផ្តល់ជំនួយធំៗទាំង ៨ បារាំង អាល្លឺម៉ង់ កាណាដា និងអេស្ប៉ាញផ្តល់អាទិភាពដល់ការអប់រំ បើគិតតាមការវាស់វែងបែបនេះ។

៧. ការគណនានេះមិនគិតបញ្ចូលមូលនិធិផ្តល់ដោយភ្នាក់ងារផ្តល់ជំនួយតាមរយៈកម្មវិធីជំនួយទូទៅទេ និងជំនួយពហុភាគីទេ។ ជំនួយខ្លះផ្តល់ឲ្យវិស័យអប់រំ។ ប្រព័ន្ធសរសេររបាយការណ៍របស់ OECD-DAC មិនរាប់បញ្ចូលជំនួយក្នុងកម្មវិធីជំនួយទូទៅ និងជំនួយទ្វេភាគីសម្រាប់អប់រំទេ។

៨. ប្រទេសកាណាដា បារាំង អាឡឺម៉ង់ ជប៉ុន ហូឡង់ អេស្ប៉ាញ ចក្រភពអង់គ្លេស និងអាមេរិក។

៩. សូចនាករណ៍នេះចង្អុលបង្ហាញអំពីចំណែកថវិកាជំនួយ ដែលម្ចាស់អំណោយនីមួយៗផ្តល់ឲ្យសម្រាប់វិស័យអប់រំនៃចំណែករបស់ OECD-DAC។ តម្លៃលើ ១ មានន័យថា ម្ចាស់អំណោយផ្តល់សារប្រយោជន៍ដល់វិស័យអប់រំច្រើនជាងធម្មតាសម្រាប់គ្រប់ភ្នាក់ងារផ្តល់អំណោយទាំងអស់

### ក្រាហ្វ ៥.១ : ជំនួយទ្វេភាគីដែលបានសន្យាសម្រាប់ការអប់រំ ១៩៩៩ – ២០០២




ប្រភព : ជំពូក ៤ របាយការណ៍អប់រំសម្រាប់ទាំងអស់គ្នា

ជំនួយទ្វេភាគីដល់ការអប់រំមូលដ្ឋានកើនដល់ ០.៩ កោដិដុល្លាអាមេរិកក្នុងមួយឆ្នាំ ឬ ២៩% នៃការផ្តល់ជំនួយទ្វេភាគីទាំងអស់ដល់ការអប់រំនៅឆ្នាំ ២០០១–២០០២។ ក្នុងចំណោមប្រទេសទាំង ៨ នូវែលសេឡង់ ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិកបែងចែកថវិកាចំនួន ៧០%នៃការផ្តល់ជំនួយអន្តរជាតិរបស់គេដល់ការអប់រំមូលដ្ឋាន នៅពេលដែលអ្នកផ្តល់ជំនួយធំទាំង ៣ គឺ បារាំង ជប៉ុន និងអាល្លឺម៉ង់ហាក់ដូចជាចាប់អារម្មណ៍លើការអប់រំក្រោយមធ្យមសិក្សាវិញ។

**ប្រសិនជាគេអាចបំពេញបាននូវរាល់ការសន្យាទាំងអស់ដែលគេបានធ្វើនៅម៉ុងតេរី ជំនួយអាចឡើងរហូតដល់ ១៦កោដិដុល្លាអាមេរិក – ពោលគឺប្រហែល ៣០ ភាគរយនៅត្រឹមឆ្នាំ ២០០៦**

## ភ្នាក់ងារជំនួយពហុភាគី : ពុំមានការប្រែប្រួលច្រើនទេ

ភ្នាក់ងារពហុភាគី – លើកលែងតែធនាគារពិភពលោកចេញ – បែងចែកថវិកាចំនួន ០.៦៦ កោដិដុល្លាអាមេរិកសម្រាប់ឆ្នាំសិក្សា ២០០១–២០០២ ដល់វិស័យអប់រំ។ ចំនួននេះគឺបានតែចំនួន ១៧% នៃជំនួយទ្វេភាគីសរុបទាំងអស់ និងចំនួននេះតិចជាងចំនួនកាលពីឆ្នាំសិក្សា ១៩៩៩–២០០០ ដែលមានចំនួន ០.៨ កោដិដុល្លា។ ទោះបីជាគណៈកម្មការអឺរ៉ុបនៅតែបន្តជាអ្នកនាំមុខនៅក្នុងការផ្តល់ជំនួយដល់វិស័យអប់រំបានធ្លាក់ចុះ ១% ដែលនៅសល់តែ ៤% នៃជំនួយសហគមន៍អឺរ៉ុបសរុបទាំងអស់។

ធនាគារពិភពលោកនៅតែជាអ្នកផ្តល់ជំនួយដ៏ធំជាងគេបង្អស់តែមួយគត់ដល់ការអប់រំ។ ការផ្តល់ប្រាក់កម្ចីដល់ការអប់រំបានកើនឡើងពី ៣% នៅចុងទសវត្សរ៍ ១៩៦០ ដល់៧% នៅទសវត្សរ៍ ១៩៩០ មុនពេលចុះបន្តិចវិញដល់ ៦% នៅដើមទសវត្សរ៍ ២០០០។ នៅក្នុងអំឡុងទសវត្សរ៍ ១៩៩០ សមភាពនៃការផ្តល់ប្រាក់កម្ចីដល់ការអប់រំមានការផ្លាស់ប្តូរ : ការអប់រំមូលដ្ឋាននៅតែជាផ្នែកដ៏សំខាន់ជាងគេបង្អស់ ទោះបីជាជំនួយដល់ការអប់រំទូទៅមានការកើនឡើងគួរឲ្យកត់សំគាល់ក៏ដោយ[១០]។

១០. ធនាគារពិភពលោកឲ្យនិយមន័យអប់រំមូលដ្ឋានថា ចាប់ពីមត្តេយ្យ បឋមសិក្សា អប់រំក្រៅប្រព័ន្ធ និងអក្ខរកម្មមនុស្សចាស់។ អប់រំចំណេះទូទៅគិតទាំង គម្រោងអប់រំគ្រប់ទាំងអស់។

## បន្ថែមលើការសន្យា

ជំនួយទ្វេភាគី និងពហុភាគីដល់ការអប់រំមូលដ្ឋានមានចំនួន ១.៥៤ កោដិនៅក្នុងឆ្នាំសិក្សា ២០០១ – ២០០២ – លើសឆ្នាំសិក្សា ១៩៩៩–២០០០ បន្តិចបន្តួចប៉ុណ្ណោះ។ គម្លាតនៃការផ្តល់ហិរញ្ញវត្ថុនៅតែមាន បើទោះជាការសន្យាថ្មីៗត្រូវបានបំពេញហើយក៏ដោយ។ ប្រសិនជាអ្នកផ្តល់ជំនួយទាំងអស់ផ្តល់ជំនួយអភិវឌ្ឍន៍បន្ថែមចំនួន ១៦ កោដិនៅត្រឹមឆ្នាំ ២០០៦ ដូចដែលបានសន្យានៅមុំងតេរីមាន ន័យថា ក្នុងមួយឆ្នាំៗត្រូវបង្កើនជំនួយចំនួន ០.៤ កោដិសម្រាប់ការអប់រំមូលដ្ឋាន ប្រសិនជាគ្មានការប្រែប្រួលនៅក្នុងការបែងចែកទេនោះ។ ផ្នែកសម្របសម្រួលហិរញ្ញវត្ថុអន្តរជាតិ (ដែលស្នើដោយចក្រភពអង់គ្លេស) ដោយពិនិត្យមើលធនធានទីផ្សារពិភពលោកដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍសហសតវត្សរ៍នៅមុន ឬត្រឹមឆ្នាំ ២០១៥ នឹងត្រូវបង្កើនជំនួយឲ្យបាន ១.២៤ កោដិសម្រាប់ការអប់រំមូលដ្ឋានក្នុងមួយឆ្នាំ[១១]។ ធនធានអន្តរជាតិប្រចាំឆ្នាំសរុបសម្រាប់ការអប់រំមូលដ្ឋាននឹងកើនដល់ ៣.២ កោដិ – កើនឡើងពីរដងនៃជំនួយបច្ចុប្បន្ន ប៉ុន្តែនៅតែតិចជាងចំនួនដែលត្រូវការចំនួន ៥.៦កោដិនៅក្នុងធនធាន បន្ថែមប្រចាំឆ្នាំដែលតម្រូវឲ្យមានដើម្បីធានាសម្រេចសកលកម្មអប់រំបឋមសិក្សា និងសមភាពយេនឌ័រគិតជាតួលេខនៅក្នុងចូលរៀននៅសាលា។

## លើកកំពស់ជីវភាពរបស់អ្នកក្រ

បញ្ហាប្រសិទ្ធភាពនៃជំនួយ និងកម្រិតនៃជំនួយជួយឲ្យមានការកើនឡើងនៃលទ្ធផលសិក្សាមានសារៈសំខាន់ណាស់។ ការពិតទៅ ការប្រើប្រាស់ជំនួយឲ្យបានត្រឹមត្រូវសម្រាប់ពេលនេះនឹងនាំឲ្យមានការប្រឹងប្រែងកាន់តែប្រសើរនៅពេលក្រោយ។

> **ដោយមានការចង់សម្ព័ន្ធភាពជាសកលប្តេជ្ញាសម្រេចឲ្យបានគោលដៅអភិវឌ្ឍសហសវត្ស ពីការព្រមព្រៀងគ្នាយ៉ាងទូលំទូលាយមួយថា ការរីកចម្រើនដែលមាននិរន្តរភាពនៅក្នុងជីវភាពរស់នៅរបស់ជនក្រីក្រ គឺជាសូចនាករណ៍សំខាន់នៅក្នុងការវាយតម្លៃប្រសិទ្ធភាពជំនួយ។**

ដោយមានការចង់សម្ព័ន្ធភាពជាសកលប្តេជ្ញាសម្រេចឲ្យបានគោលដៅអភិវឌ្ឍសហសវត្សរ៍ ការព្រមព្រៀងគ្នាយ៉ាងទូលំទូលាយមួយថា ការរីកចម្រើនដែលមាននិរន្តរភាពនៅក្នុងជីវភាពរស់នៅរបស់ជនក្រីក្រ គឺជាសូចនាករណ៍សំខាន់នៅក្នុងការវាយតម្លៃប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយ។ គោលការណ៍សំខាន់ៗចំនួន ៣ នៃបទពិសោធន៍ល្អៗរបស់អន្តរជាតិរួមមាន : សារៈសំខាន់នៃគោលនយោបាយអភិវឌ្ឍដែលរៀបចំឡើងល្អគ្រប់ជ្រុងជ្រោយ ការបន្សុីគ្នាឲ្យជិតស្និទ្ធរវាងអ្នកផ្តល់ជំនួយ និងអាទិភាពរបស់រដ្ឋាភិបាល និងធ្វើឲ្យស្របគ្នានៃការអនុវត្តរបស់អ្នកផ្តល់ជំនួយទាំងអស់។ ភស្តុតាងដែលកើនឡើងបង្ហាញថា គោលនយោបាយជាតិល្អៗដើម្បីលុបបំបាត់ភាពក្រីក្រគឺជាការយកចិត្តទុកដាក់មួយ ដែលចេះតែមានសារៈសំខាន់ឡើង សម្រាប់ភ្នាក់ងារផ្តល់ជំនួយ នៅពេលដែលភ្នាក់ងារផ្តល់ជំនួយត្រូវសម្រេចថាតើជំនួយគួរតែផ្តល់ទៅវិស័យណាជាអាទិភាព។

ជំនួយសម្រាប់ការអប់រំគួរត្រូវគេបានឃើញនៅក្នុងបរិបទបែបនេះ។ ប្រសិនជាគោលនយោបាយរបស់ជាតិល្អៗគឺជាចំណុចចាប់ផ្តើមសម្រាប់ការប្រើប្រាស់ជំនួយឲ្យមានប្រសិទ្ធភាព វាពុំមានការខ្វះខាតផែនការអប់រំតាមផ្នែកនោះទេ។ ក្នុងចំណោមប្រទេសចំនួន ១៣៨ ដែលគេបានធ្វើការស្ទាបស្ទង់មានប្រទេសចំនួន ៧៦% មានផែនការអប់រំតាមអនុផ្នែក និង ៨៣% កំពុងតែរៀបចំផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នា។ ប្រទេសចំនួន ៥៨ (៤០%) មានយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្របណ្តោះអាសន្ន ឬពេញលេញ។ ប៉ុន្តែគេគួរតែអានតួលេខទាំងនេះដោយមានការប្រុងប្រយ័ត្នខ្ពស់។ តើផែនការតាមផ្នែក និងផែនការអប់រំសម្រាប់ទាំងអស់គ្នាជាផែនការដូចគ្នាឬទេ? ភស្តុតាងនៃការអនុវត្តផែនការទាំងអស់នេះនៅមានតិចតួចនៅឡើយ។ ខ្លះគ្រាន់តែជាអំណះអំណាងនៃបំណងប៉ុណ្ណោះដែលត្រូវបានគេសរសេរឡើងដើម្បីឆ្លើយតបទៅនឹងតម្រូវការអន្តរជាតិ។

## វាយតម្លៃជំនួយសម្រាប់ការអប់រំ

រង្វាយតម្លៃជាច្រើនអំពីគុណភាពនៃជំនួយសម្រាប់ការអប់រំត្រូវបានគេធ្វើឡើង។ ការស្រាវជ្រាវមួយរបស់ជំនួយសហគមន៍អឺរ៉ុបដល់ការអប់រំត្រូវបានគេធ្វើឡើងប្រទេសនៅក្នុងទ្វីអាព្រិច ការ៉ាប៊ីន និងប៉ាស៊ីភិក រវាងឆ្នាំ ១៩៩៣ និង២០០០ ហើយឃើញថាការសម្របសម្រួលរបស់អ្នកផ្តល់ជំនួយមានប្រសិទ្ធភាពជាងគេនៅពេលដែលយុទ្ធសាស្រ្តទូទាំងវិស័យត្រូវបានគេយកមកអនុវត្ត ហើយនេះគឺជាវិធីសាស្រ្តដែលគេចង់បានសម្រាប់ជំនួយកម្មវិធីអប់រំ។

ការវាយតម្លៃរួមគ្នានៃការគាំទ្រពីខាងក្រៅដល់ការអប់រំមូលដ្ឋាននៅក្នុងប្រទេសកំពុងអភិវឌ្ឍត្រូវបានធ្វើដោយភ្នាក់ងារទ្វេភាគី និងពហុភាគីចំនួន ១៣ នៅក្នុងប្រទេសបុលីវី ប៊ឺគីណាហ្វាសូ អ៊ូហ្គង់ដា និងហ្សមប៊ី។ ការសិក្សាបង្ហាញពីចំណុចខ្សោយក្នុងទំនាក់ទំនងរវាងការរៀបចំកម្មវិធី និងអ្វីដែលអាចដំណើរការល្អនៅតាមមូលដ្ឋាន ជាពិសេសទាក់ទងនឹងការអប់រំគ្រូបង្រៀន កម្មវិធីសិក្សា សម្ភារសិក្សា និងវិធីសាស្រ្តបង្រៀន។ ការសិក្សាសាកល្បងមិនត្រូវបានគេធ្វើនៅក្នុងកម្មវិធីធំៗទេ។ ការវាយតម្លៃបង្ហាញថា កង្វះធំជាងគេគឺចេតនា និងការប្តេជ្ញាចិត្តកែលំអគុណភាពអប់រំមូលដ្ឋាន តាមរយៈការរកដំណោះស្រាយតាមតំបន់រៀងខ្លួនដែលត្រូវបានគេរៀបចំឡើងពីក្រោមទៅលើ ជាជាងអ្វីដែលគេបានរៀបចំជាគំរូរួចជាស្រេចនៅកម្រិតអន្តរជាតិ។ ការសិក្សាបានសន្និដ្ឋានថា ដៃគូល្អស្ថិតនៅលើការប្រើប្រាស់ជំនួយសម្រាប់ការអប់រំប្រកបដោយប្រសិទ្ធភាព។ កត្តាដែលប៉ះពាល់ដល់គុណភាពនៃភាពជាដៃគូរួមបញ្ចូលពីវិធីសាស្រ្តដែលភ្នាក់ងារ និងក្រសួងរបស់រដ្ឋសហការគ្នា វិនិយោគនៅក្នុងការងារកសាង បច្ចេកទេស និងរដ្ឋបាល កិច្ចព្រមព្រៀងលើតួនាទី និងការទទួលខុសត្រូវដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់ និងទំនាក់ទំនងគ្នានៃជំនួយនៅក្នុងបរិបទនីមួយៗ។

រង្វាយតម្លៃទី ៣ សិក្សាពីជំនួយដែលផ្តល់ឲ្យការអប់រំនៅបឋមសិក្សានៅប្រទេសបង់ក្លាដេស ហ្គាណា ឥណ្ឌា ឥណ្ឌូណេស៊ី កែនយ៉ា និងម៉ាឡាវីដោយនាយកដ្ឋានសម្រាប់ការអភិវឌ្ឍអន្តរជាតិរបស់អង់គ្លេសពីឆ្នាំ ១៩៩៨ ទៅឆ្នាំ ២០០១។ ការវាយតម្លៃបញ្ជាក់ពីការលំបាករវាងការខិតខំប្រឹងប្រែងបង្កើនភាពម្ចាស់ការឲ្យអស់លទ្ធភាព និងការបង្កើនការចូលរួមរបស់អ្នកផ្តល់ជំនួយក្នុងការរៀបចំគោលនយោបាយ ការគ្រប់គ្រង និងការលំបាកនៃការឲ្យមានក្រសួងច្រើនចូលរួម និងកម្រិតផ្សេងគ្នារបស់រដ្ឋាភិបាល និងកង្វះមូលដ្ឋានទិន្នន័យពិស្តារ និងត្រឹមត្រូវ។

ការវាយតម្លៃទាំងបីបានសន្និដ្ឋានថា ទោះជាមានការរីកចម្រើនឲ្យមានយុទ្ធសាស្រ្តដែលមានការសម្របសម្រួលស៊ីចង្វាក់គ្នា ដើម្បីផ្តល់ជំនួយដល់ការអប់រំក៏ដោយ ការជ្រើសរើសជាក់ស្តែងនៅតែជាបញ្ហាដែលត្រូវតែសមស្រប និងទន់ភ្លន់។

១១. ការសន្និដ្ឋាននេះប្រើសម្រាប់ពន្យល់ឲ្យងាយយល់ប៉ុណ្ណោះ។ ការសន្និដ្ឋានប្រែហែលជាម្ចាស់អំណោយទាំងអស់មិនឯកភាពគ្នាទាំងស្រុង ហើយជំនួយរបស់ម្ចាស់អំណោយនីមួយអាចខុសគ្នា

វិធីសាស្ត្រទូទាំងវិស័យជួយពង្រឹងភាពម្ចាស់ការនៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍអប់រំ និងផ្តល់ឱកាសសម្រាប់អ្នកផ្តល់ជំនួយដោះស្រាយបញ្ហាគុណភាពអប់រំដែលមានជាយូរយារណាស់មកហើយ។ ការផ្លាស់ប្តូរវិធីសាស្ត្របានបង្កើនគម្រោងកាន់តែច្រើន ការចរចាគោលនយោបាយ និងការដាក់លក្ខខណ្ឌរបស់អ្នកផ្តល់ជំនួយ។ វិធីសាស្ត្រទាំងពីរអាចជាការប្រឈមមុខរបស់ម្ចាស់ការមូលដ្ឋាន បង្កើនតម្រូវការសម្របសម្រួល និងកាត់បន្ថយការអនុវត្តជាពិសេសនៅកន្លែងដែលការគ្រប់គ្រងហិរញ្ញវត្ថុរដ្ឋាភិបាលនៅខ្សោយ។ នៅក្នុងបរិបទនេះ ការកសាងសមត្ថភាព គឺជាប្រការដ៏សំខាន់។

## ជំនួយ និងគុណភាព : ធ្វើឲ្យមានទំនាក់ទំនងគ្នា

> **មានការស្រាវជ្រាវតែមួយចំនួនតូចប៉ុណ្ណោះដែលសិក្សាពីទំនាក់ទំនងរវាងជំនួយ និងលទ្ធផលសិក្សា**

មានការស្រាវជ្រាវតែមួយចំនួនតូចប៉ុណ្ណោះ ដែលសិក្សាពីទំនាក់ទំនងរវាងជំនួយ និងលទ្ធផលសិក្សា។ នៅប្រទេសហ្គាណាជំនួយឧបត្ថម្ភរបស់ធនាគារពិភពលោកដល់បឋមសិក្សាតាមរយៈការផ្តល់សៀវភៅសិក្សា និងកែលំអហេដ្ឋារចនសម្ព័ន្ធសាលាជួយឲ្យមានការកែលំអគុណភាពអប់រំ។

ប្រទេសមួយចំនួនបានបង្កើតសូចនាករណ៍សំខាន់ៗសម្រាប់វាស់វែងការរីកចម្រើននៅក្នុងប្រទេស។ នៅអ៊ូហ្គង់ដា ដែលបានទទួលថវិកាសម្រាប់ការអប់រំប្រហែល ៥០% ពីជំនួយបរទេស ក្រសួងអប់រំប្រើប្រាស់សូចនាករណ៍នោះដើម្បីពិនិត្យមើលគុណភាពអប់រំនៅបឋមសិក្សា។ សូចនាករណ៍ទាំងនេះរួមមានកម្រិតវប្បធម៌របស់គ្រូបង្រៀន ផលធៀបគ្រូ/សិស្ស និងភាគរយសិស្សរៀនដល់ថ្នាក់ទី៦ ដែលអាចមានចំណេះដឹងគ្រប់គ្រាន់អំពីជំនាញមូលដ្ឋានគ្រឹះមួយចំនួនដែលបានកំណត់ជាលក្ខណៈជាតិ។ គេវាយតម្លៃការរីកចម្រើនយ៉ាងទៀងទាត់ដោយសហការជាមួយអ្នកផ្តល់ជំនួយ។ ប្រហាក់ប្រហែលគ្នានេះដែរប្រទេសអេចូពីកត់សំគាល់សូចនាករណ៍គុណភាពចំនួន ៦ ដែលទាក់ទងនឹងកម្រិតវប្បធម៌គ្រូ ផលធៀបសិស្ស/សៀវភៅសិក្សា និងលទ្ធសិក្សារបស់សិស្ស។

ឧទាហរណ៍នេះបង្ហាញថា ភ្នាក់ងារផ្តល់ជំនួយមួយចំនួនបង្កើតការវាយតម្លៃរបស់ខ្លួនដើម្បីដឹងពីប្រសិទ្ធភាពនៃជំនួយលើគុណភាពអប់រំដោយប្រើសូចនាករណ៍សំខាន់ៗរបស់រដ្ឋាភិបាលធ្វើជាមូលដ្ឋានសម្រាប់វាស់វែងការរីកចម្រើនជាជាងការប្រើសូចនាករណ៍របស់អ្នកផ្តល់ជំនួយ។

ទោះបីជាវាមានការលំបាកក្នុងការវាយតម្លៃឥទ្ធិពលជំនួយលើគុណភាពប្រកបដោយលក្ខណៈជាប្រព័ន្ធច្បាស់លាស់ក៏ដោយ ក៏សូចនាករណ៍សំខាន់មួយចំនួនអាចជាជំនួយដ៏ប្រសើរ។ សូចនាករណ៍ទាំងនេះរួមមានគោលនយោបាយអប់រំល្អៗដែលមានទំនាក់ទំនងគ្នា និងអាចយកទៅអនុវត្តបាន។ គោលនយោបាយបែបនេះមានគោលបំណងច្បាស់លាស់សម្រាប់ផ្តល់ឱកាសចូលរៀន សមធម៌ គុណភាព និងសូចនាករណ៍។ សូចនាករណ៍ទាំងនេះជាខ្នាតវាស់វែងដ៏សំខាន់របស់រដ្ឋាភិបាល និងជាចំណុចដៅសម្រាប់អង្គការទាំងអស់វាស់វែងការរីកចម្រើន។ ក្នុងន័យនេះ ការយកចិត្តទុកដាក់លើការវាយតម្លៃឲ្យបានទៀតទាត់មានលក្ខណៈសំខាន់ណាស់។

## កម្មវិធីជំនួយដាច់ដោយឡែកពីគ្នា

គេក៏អាចមានការយល់ដឹងពីប្រសិទ្ធភាពជំនួយបានដែរដោយវិភាគអំពីការបែងចែកធនធានរបស់អ្នកផ្តល់ជំនួយឲ្យទៅក្រុមគោលដៅធំ ឬតូចរបស់ប្រទេស។ លទ្ធផលពីការស្រាវជ្រាវរបស់អ្នកផ្តល់ជំនួយទ្វេភាគីធំៗចំនួន២០ ដែលផ្តល់ជំនួយដល់ប្រទេសចំនួន ១៤៩ បង្ហាញថា ភ្នាក់ងារផ្តល់ជំនួយបែងចែកជំនួយដល់ប្រទេសចំនួន ៦៣។ បារាំង អាល្លឺម៉ង់ និងជប៉ុនប្តេជ្ញាចិត្តផ្តល់ជំនួយដល់ប្រទេសចំនួនជាង ១០០ នៅពេលដែលប្រទេសហ្វាំងឡង់ផ្តល់ជំនួយដល់ប្រទេសចំនួនតែ ៨ ប៉ុណ្ណោះ។ បីភាគបួននៃជំនួយអប់រំទ្វេភាគីបានផ្តល់ឲ្យប្រទេសតែ ៣៨ ប៉ុណ្ណោះ។ ការផ្តល់ជំនួយច្រើនគ្នាបែបនេះ ធ្វើឲ្យអស់ថ្លៃក្នុងការផ្ទេរប្រាក់ជាច្រើន។ គុណភាពនៃការផ្តល់ជំនួយអាចនឹងត្រូវពង្រឹង ប្រសិនជាចំនួនមធ្យមនៃប្រទេសទទួលជំនួយអប់រំត្រូវកាត់បន្ថយនោះ។ បញ្ហានេះអាចមានហួសពីវិស័យអប់រំទៀត។



© AMI VITALE/PANOS/EDITINGSERVER.COM



នៅអង់ហ្គោឡា ចំណុចប្រហោងស្នាមគ្រាប់កាំភ្លើងក្នុងជញ្ជាំងប្រាប់យើងអំពីសង្គ្រាមស៊ីវិលដែលធ្វើឲ្យមានជនអន្តោរប្រវេសន៍ដោយសារសង្គ្រាម២ លាននាក់

ផលលំបាកមួយគឺថា ប្រទេសទទួលជំនួយ – គិតជាមធ្យម – ត្រូវដោះស្រាយជាមួយអ្នកផ្តល់ជំនួយពី ៧ ទៅ ១២ – ដំណើរការដែលអាចធ្វើឲ្យមានការខាតបង់ថ្លៃដើមច្រើន លុះណាតែជំនួយទាំងនោះត្រូវបានសម្របសម្រួលឲ្យបានល្អប្រសើរមែនទែន។ តួលេខអាចច្រើនជាងនេះនៅក្នុងប្រទេសដែលពឹងផ្អែកលើជំនួយខ្លាំង។ ប្រទេសហ្សំប៊ីដែល ៤៣% នៃថវិកាអប់រំគឺជាជំនួយបរទេស ធ្វើការយ៉ាងជិតស្និទ្ធជាមួយអ្នកផ្តល់ជំនួយចំនួន ២០។ នៅចុងទសវត្សរ៍ ១៩៩០ ប្រទេសនេះមានកិច្ចព្រមព្រៀងលើកម្មវិធីវិនិយោគលើអនុវិស័យអប់រំមូលដ្ឋាន។ ជំនួយអប់រំត្រូវបានផ្តល់ និងគ្រប់គ្រងដោយក្រសួងអប់រំ ប៉ុន្តែការអនុវត្តជាក់ស្តែងវិញ ត្រូវបញ្ចូលលក្ខខណ្ឌផ្សេងៗគ្នារបស់ភ្នាក់ងារផ្តល់ជំនួយផងដែរ។ នៅប្រទេសម៉ូហ្សំប៊ិក (២៨% នៃថវិកាអប់រំបានមកពីជំនួយបរទេស) ផែនការយុទ្ធសាស្ត្រអប់រំត្រូវបានអនុម័តនៅឆ្នាំ ១៩៩៨ បង្កើតឲ្យមានផែនការរួម និងវត្តមាននៃការតាមដានត្រួតពិនិត្យ ដែលស្ថិតនៅក្រោមការដឹកនាំដ៏រឹងមាំរបស់រដ្ឋាភិបាល។

## ការផ្តួចផ្តើមគំនិតនៃការអនុវត្តបានមុនគេ (FTI) : ដៃគូអន្តរជាតិ

ការផ្តួចផ្តើមគំនិតនៃការអនុវត្តបានមុនគេ (FTI) ផ្តល់ការឆ្លើយតបអន្តរជាតិដាច់ដោយឡែកចំពោះការប្រឈមមុខនៃការធ្វើឲ្យស៊ីចង្វាក់គ្នារបស់អ្នកផ្តល់ជំនួយក្នុងការគាំទ្រគោលនយោបាយជាតិ។ ភាពជាដៃគូអន្តរជាតិនេះត្រូវបានរៀបចំដើម្បីបង្កើនការរីកចម្រើនឆ្ពោះទៅសម្រេចសកលកម្មអប់រំបឋមសិក្សានៅមុន ឬត្រឹមឆ្នាំ ២០១៥។ ប្រកាសដោយគណៈកម្មការអភិវឌ្ឍរបស់ធានាគារពិភពលោក/អង្គការរូបិវត្ថុអន្តរជាតិក្នុងឆ្នាំ២០០២ ឥឡូវនេះ ដៃគូមានរួមបញ្ចូលទាំងភ្នាក់ងារទ្វេភាគី និងពហុភាគី និងធនាគារអភិវឌ្ឍតំបន់ជាង ៣០ ផងដែរ។

នៅឆ្នាំ ២០០៤ ភ្នាក់ងារដៃគូឯកភាពគ្នាលើក្របខ័ណ្ឌមួយដើម្បីជាការណែនាំដល់ការអភិវឌ្ឍការផ្តួចផ្តើមគំនិតនៃការអនុវត្តមុនគេ (មើលតារាងខាងក្រោម)។

ឥឡូវត្រូវបានគេកំណត់ថា ជាការផ្តួចផ្តើមជាសកលដែលបើកចំហរដល់រាល់ភ្នាក់ងារផ្តល់ជំនួយដែលចាប់អារម្មណ៍ និងប្រទេសដែលមានប្រាក់ចំណូលទាបទាំងអស់។ ក្របខ័ណ្ឌនេះកំណត់គោលដៅចំនួន ៦ និងគោលការណ៍ចំនួន ៥ ដើម្បីដឹកនាំសកម្មភាពនៃការផ្តួចផ្តើមគំនិតដែលត្រូវអនុវត្តឲ្យបានមុនគេ។

| គោលដៅ FTI | គោលការណ៍ FTI |
|---|---|
| ■ ជំនួយដែលមានប្រសិទ្ធភាពខ្ពស់សម្រាប់អប់រំបឋមសិក្សា | ■ ម្ចាស់ការរបស់ប្រទេស |
| ■ បង្កើនជាបន្តបន្ទាប់នូវជំនួយដល់ការអប់រំបឋមសិក្សា | ■ ខ្នាតសម្រាប់វាស់វែង |
| ■ គោលនយោបាយតាមផ្នែកល្អៗនៅក្នុងការអប់រំ | ■ ទំនាក់ទំនងជំនួយ និងលទ្ធផល |
| ■ ការផ្តល់ហិរញ្ញវត្ថុក្នុងស្រុកគ្រប់គ្រាន់សម្រាប់ការអប់រំ | |
| ■ បង្កើនការទទួលខុសត្រូវចំពោះលទ្ធផល | ■ ចំណាយក្នុងការផ្ទេរប្រាក់តិច |
| ■ ចែករំលែកបទពិសោធន៍សកលនូវអ្វីដែលដំណើរការល្អ | ■ តម្លាភាព |

ទោះបីជាកិច្ចព្រមព្រៀងលើក្របខ័ណ្ឌតំណាងឲ្យការរីកចម្រើនល្អក៏ដោយ បញ្ហាជាច្រើននៅតែមាននៅឡើយ។ ការព្រួយបារម្ភដំបូងគឺទាក់ទងនឹងកម្រិតនៃ FTI ជាយន្តការផ្តល់ជំនួយផ្ទាល់។ រហូតដល់ខែមេសា ឆ្នាំ ២០០៤ មូលនិធិ Catalytic EFA-FTI បានទទួលជំនួយ ២៣៦ លានដុល្លាអាមេរិកពីអ្នកផ្តល់ជំនួយចំនួន ៤។ ជំនួយនេះមិនទាន់គ្រប់គ្រាប់នៅឡើយសូម្បីតែសម្រាប់តម្រូវការបន្ទាន់សម្រាប់ប្រទេសដែលបានចូល FTI មុនគេក៏ដោយ[១២]។ សំនួរទី ២ ទាក់ទងនឹងកម្រិតដែលសមាជិក FTI នឹងទាមទារឲ្យមានការអនុវត្តតាមខ្នាតវាស់វែងដែលមានដាក់បញ្ចូលនៅក្នុងក្របខ័ណ្ឌសូចនាករណ៍ដើម្បីសម្រេចសកលកម្មបឋមសិក្សាទាក់ទងនឹងគោលនយោបាយលើបញ្ហាដូចជាប្រាក់ខែគ្រូ និងប្រព័ន្ធហិរញ្ញវត្ថុ។ ជាគោលការណ៍ នៅពេលដែលអ្នកផ្តល់ជំនួយនៅក្នុងប្រទេសពេញចិត្តថា ផែនការអប់រំតាមផ្នែកដោះស្រាយបញ្ហាសំខាន់ៗត្រូវបានគេចាត់ទុកថាបានទទួលការគាំទ្រ FTI ថាតើធនាគារពិភពលោក និងភ្នាក់ងារផ្តល់ជំនួយផ្សេងទៀតទទួលយកការសម្រេចនេះឬមិនទទួលនៅមិនទាន់ច្បាស់នៅឡើយ។ ទី៣ ដូចបានរាយការណ៍ខាងដើមរួចមកហើយ ពីសមាជិកដែលផ្សារភ្ជាប់ជាមួយនឹងលក្ខណៈវិនិច្ឆ័យមួយចំនួនអាចនឹងមិនរាប់បញ្ចូលប្រទេសមួយចំនួនដែលការប្រឈមមុខរបស់ EFA មានលក្ខណៈធំធេងពេក។ ទី៤ ការយកចិត្តទុកដាក់ខ្លាំងជាងនេះទៀតជាការចាំបាច់ដើម្បីរៀបចំផែនការសម្រាប់ការអប់រំនៅក្នុងផ្នែកទូលំទូលាយមួយ និងការកែទម្រង់ដើម្បីលុបបំបាត់ភាពក្រីក្រ។

ទោះបីជាមានការរីកចម្រើនខ្លះនៅក្នុងការសម្របសម្រួលសម្រាប់ការអប់រំទាំងអស់គ្នាក៏ដោយ ក៏នៅតែមិនទាន់សមស្របដើម្បីឈានទៅសម្រេចគោលដៅក្រុងដាកាដែរ។ ជំរុញឲ្យមានឆន្ទៈនយោបាយអន្តរជាតិ និងការប្តេជ្ញាចិត្តនៅតែជាតម្រូវការដ៏ចាំបាច់។ កង្វះខាតធនធានបង្កើនសារៈសំខាន់នៃការធានាថា ជំនួយត្រូវតែប្រើឲ្យមានប្រសិទ្ធភាពតាមដែលអាចបាន និងតម្រង់ទិសទៅប្រទេសដែលត្រូវការជំនួយជាងគេបំផុត។ ការសម្របសម្រួលឲ្យបានកាន់តែប្រសើររវាងអ្នកផ្តល់ជំនួយ ការជ្រើសរើសត្រឹមត្រូវនូវនីតិវិធីផ្តល់ជំនួយ និងការតាមដានដោយទៀតទាត់នូវគុណភាពអប់រំអាចជួយលើកកំពស់គុណភាពអប់រំបានជាមិនខាន។ ■

១២. សម្រាប់ប្រទេស ១០ ដំបូង ដែលបានគាំទ្រ FTI គម្លាតហិរញ្ញវត្ថុអាចខុសគ្នាពី ២០៤.៥ លានដុល្លាអាមេរិកក្នុងឆ្នាំ ២០០៤ និង ២៣១.៥ លានដុល្លាអាមេរិកក្នុងឆ្នាំ ២០០៥។

ជំពូក ៦

# ដំណើរឈានទៅសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា : សារៈសំខាន់របស់គុណភាព

ប្រព័ន្ធអប់រំមួយមានគុណភាពខ្ពស់ ឬទាបអាចវាយតម្លៃបានអាស្រ័យលើថា តើការអប់រំនោះឆ្លើយតបនឹងគោលបំណងដែលបានកំណត់បានកម្រិតណា។ រដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល គ្រូ គ្រួសារនិង សិស្សប្រហែលជាមិនមានការយល់ឃើញបែបនេះទេ។ ប៉ុន្តែសម្រាប់អ្នកទាំងអស់ខាងលើពិតជាយល់ឃើញថា គោលបំណងរបស់អប់រំមានយ៉ាងហោចណាស់ ២ ដែរគឺ : បង្កើនពុទ្ធិ និងលើកកំពស់ឥរិយាបថ និងសីលធម៌ដែលអាចចាត់ទុកថាមានសារៈសំខាន់សម្រាប់ក្លាយខ្លួនជាពលរដ្ឋល្អ និងសម្រាប់ជីវិតប្រកបដោយប្រសិទ្ធភាពនៅក្នុងសហគមន៍។

ការវាយតម្លៃអំពីគុណភាពត្រូវគិតដល់សមធម៌ផងដែរ។ ប្រព័ន្ធអប់រំដែលមានវិសមភាពយេនឌ័រ ឬការរើសអើងប្រឆាំងនឹងក្រុមណាមួយដោយសារជនជាតិ ឬវប្បធម៌ខុសគ្នាគឺជាប្រព័ន្ធអប់រំដែលគ្មានគុណភាព។ ការខិតខំឲ្យមានសមធម៌មានន័យជាការលើកកំពស់គុណភាពអប់រំ។

របាយការណ៍នេះសង្កត់ធ្ងន់ថា ការអប់រំដែលមានគុណភាពគឺជាការអប់រំដែលធ្វើឲ្យមានការកែប្រែយ៉ាងសំខាន់នៅក្នុងចក្ខុវិស័យដើម្បីសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍទូទៅពីការអភិវឌ្ឍសុខភាពល្អប្រសើររហូតដល់ការបង្កើនប្រាក់ចំណូលឲ្យបានច្រើន និងអភិវឌ្ឍសក្ដានុភាពសេដ្ឋកិច្ច។

ដោយគ្រាន់តែសង្កត់ធ្ងន់លើគោលដៅបរិវិស័យ ដូចជាសកលកម្មអប់រំបឋមសិក្សា នោះការអប់រំសម្រាប់ទាំងអស់គ្នាមិនអាចសម្រេចបានទេ។ តាមទស្សនៈគោលនយោបាយ ហេតុផលចំបងមួយគឺថា នៅក្នុងប្រទេសជាច្រើនលើពិភពលោក គម្លាតដ៏ធំនៅតែមានរវាងអ្នកដែលបានបញ្ចប់ការសិក្សាពីសាលា និងអ្នកដែលមានចំណេះដឹង និង បេះគិតគួរពិចារណាពិតប្រាកដ។



និស្សិតទាមទារឲ្យលើកកំពស់គុណភាពអប់រំឲ្យកាន់តែប្រសើរថែមទៀត
ក្នុងអំឡុងពេលបាតុកម្មនៅមុខក្រសួងអប់រំរបស់ប្រទេសហុងឌូរ៉ាស (២០០២)

**តារាងទី ៦.១ : សូចនាករណ៍គុណវិស័យ និងបរិវិស័យនៃការចូលរៀននៅបឋមសិក្សា**

| សិក្សា | ប្រទេស | ក្រុមប្រទេស | %សិស្សចុះឈ្មោះ (អាយុ៦-១៤) | %សិស្សនៅរៀនត រហូតចប់ថ្នាក់ទី ៥ | %សិស្សរៀនចប់ ហើយ មានជំនាញអប្បបរមា | អត្រាចុះឈ្មោះចូលរៀន ពិតនៅបឋម មុនធ្វើតេស្ត |
|---|---|---|---|---|---|---|
| **SACMEQ (1995)** | | | | | | |
| តេស្តរៀនអានថ្នាក់ទី ៦ | ម៉ាឡាវី | ១០០ | ៩១ | ៣១ | ៧ | ៦៩ |
| | ម៉ូរីជួស | ១០០ | ៩៩ | ៩៨ | ៥២ | ៩៩ |
| | ណាមីប៊ី | ១០០ | ៩៧ | ៧៤ | ១៩ | ៨៤ |
| | សា.រ. តង់ហ្សានី | ១០០ | ៨៧ | ៧០ | ១៨ | ៥៤ |
| **PIRLS (2001)** | | | | | | |
| តេស្តរៀនអានថ្នាក់ទី ៤ | កូឡុំប៊ី | ១០០ | ៩៨ | ៦០ | ២៧ | ៨៧ |
| | ម៉ូរ៉ូកូ | ១០០ | ៩៩ | ៧៧ | ៥៩ | ៨១ |
| **PASEC (Mid 1999)** | | | | | | |
| តេស្តភាសាបារាំងថ្នាក់ទី៥ | បឺគីណាហ្វាសូ | ១០០ | ៣៥ | ២៥ | ២១ | ២៨ |
| | កាមេរូន | ១០០ | ៨៨ | ៤៥ | ៣៣ | ៧៣ |
| | កូដឺវ័រ | ១០០ | ៦៥ | ៤៥ | ៣៨ | ៤៩ |
| | ហ្គីនី | ១០០ | ៤៨ | ៣២ | ២១ | ៣៦ |
| | ម៉ាដាហ្គាស្កា | ១០០ | ៧៨ | ៣១ | ២០ | ៦៣ |

អត្រាជលផៀបសិស្សចុះឈ្មោះចូលរៀនពិត = NER

ប្រភព : ជំពូក ៤ របាយការណ៍អប់រំសម្រាប់ទាំងអស់គ្នា

តារាង ៦.១ បង្ហាញពីខ្នាតនៃការវាស់វែងបញ្ហានៅក្នុងប្រទេសអាហ្រ្វិច និងអាមេរិកឡាទីនមួយចំនួន។ តារាងនេះបង្ហាញថា នៅពេលដែលអត្រាចូលរៀនសរុបកើនខ្ពស់នៅប្រទេសជាច្រើន មានអ្នករៀនចប់មួយចំនួនតូចប៉ុណ្ណោះបានរៀនចេះដូចដែលបានកំណត់ដោយស្តង់ដារអប្បបរមាជាតិ។

ជាមធ្យម សម្រាប់ប្រទេសទាំងអស់ដែលបានបង្ហាញនៅក្នុងតារាង ៦.១ មានកុមារតិចជាង ២ ភាគ ៣ រៀននៅថ្នាក់ទី ៤ ដល់ថ្នាក់ទី ៦ ដែលមានចំណេះដឹងអប្បបរមាដូចដែលបានកំណត់នៅក្នុងស្តង់ដាជាតិ ទោះជាមានអត្រាចុះឈ្មោះចូលរៀនសរុបនៅប្រទេសទាំងនោះច្រើនជាង ៦៥% ក៏ដោយ។ គោលនយោបាយដែលព្យាយាមឲ្យបាន សម្រេចអត្រាចុះឈ្មោះឲ្យបាន ១០០%នៅប្រទេសទាំងនោះនឹងនាំឲ្យមានការគិតមិនដល់អំពីតម្រូវការសិក្សារបស់សិស្ស និងមិនបានសម្រេចផលប្រយោជន៍ពិតប្រាកដនៃការសិក្សារបស់ក្មេងមួយចំនួនធំដែលមិនមានចំណេះដឹងពិតប្រាកដដូចដែលបានកំណត់ដោយស្តង់ដាជាតិ។



នៅឥណ្ឌា អ្នកគ្រូម្នាក់កំពុងជជែកលេងជាមួយសិស្ស

រដ្ឋាភិបាលដែលព្យាយាមលើកកំពស់គុណភាពសិក្សារបស់សិស្សក៏ជួបប្រទះការលំបាកជាច្រើនដែរ ជាពិសេស នៅប្រទេសដែលមានប្រាក់ចំណូលតិច។ នៅប្រទេសទាំងនោះ ថ្នាក់រៀនមានសិស្សច្រើន ហើយគ្រូមានការអប់រំតិច។ វិធីសាស្ត្រមួយគឺការកំណត់ស្តង់ដាអប្បបរមាចាំបាច់ដែលសិស្សគ្រប់គ្នា និងសាលាទាំងអស់សង្ឃឹមថានឹងសម្រេចឲ្យបាន។ ប៉ុន្តែក៏មានការប្រថុយប្រថានផងដែរថាការសង្កត់ធ្ងន់លើស្តង់ដាអប្បបរមាអាចជាការកំហិតដល់សកម្មភាពផ្សេងទៀត។

របាយការណ៍នេះពណ៌នាអំពីគោលនយោបាយដែលមិនហួសពីសមត្ថភាពរបស់ប្រទេសក្រីក្រខ្វះធនធាន និងហិរញ្ញវត្ថុក្នុងការសម្រេចការអប់រំសម្រាប់ទាំងអស់គ្នា។ គោលនយោបាយចាប់ផ្តើមពីអ្នកសិក្សា និងសង្កត់ធ្ងន់លើភាពសម្បូរបែបនៃការរៀន និងបង្រៀនដែលគាំទ្រដោយស្នាដៃស្រាវជ្រាវដែលបង្ហាញពីអ្វីដែលមានប្រសិទ្ធភាពសម្រាប់សាលា និងគ្រូ។ កត្តាមួយចំនួន ដូចជា កម្មវិធីសិក្សា ចំនួនម៉ោងសិក្សា វិធីសាស្ត្របង្រៀន និងសម្ភារសម្រាប់រៀន និងបង្រៀនត្រូវបានគេផ្តល់ការយកចិត្តទុកដាក់យ៉ាងពិសេស។ ការវិនិយោគលើគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនគឺការវិនិយោគដ៏សំខាន់ដូចដែលបង្ហាញយ៉ាងច្បាស់ដោយបទពិសោធន៍មកពីប្រទេសមួយចំនួនទៀត។ ការដឹកនាំ និងគ្រប់គ្រងសាលា និងឱកាសសម្រាប់ផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមកមានតួនាទីយ៉ាងសំខាន់សម្រាប់ធ្វើដំណើរឆ្ពោះទៅរកវប្បធម៌គុណភាព។

ទំនាក់ទំនងរវាងធាតុផ្សេងៗទៀតនៅក្នុងការអប់រំអាចជួយលើកកំពស់គុណភាព។ ជាញឹកញាប់ ធាតុទាំងអស់នេះត្រូវបានគេធ្វើមិនដឹងមិនឮដោយស្ថាប័នរបស់រដ្ឋាភិបាល។ ការអប់រំកុមារតូច និងកម្មវិធីអប់រំជំរុញឲ្យមានការលើកកំពស់គុណភាពជាទូទៅ និងការសិក្សាមួយជីវិត។ អក្ខរកម្មជួយលើកកំពស់ការប្តេជ្ញាចិត្តរបស់មនុស្សពេញវ័យចំពោះការអប់រំកូន។ គោលនយោបាយដែលឆ្លើយតបនឹងតម្រូវការយេនឌ័រជួយលើកកំពស់គុណភាពអប់រំ និងលទ្ធផលនៃការសិក្សាដោយផ្ទាល់។

**ដំណើរការនយោបាយ នៅក្នុងប្រទេសអាច ជាអ្នកធានាសម្រេច ជោគជ័យលើកំណែទម្រង់**

ការកែទម្រង់គុណភាពដែលមានជោគជ័យទាមទារឲ្យមានតួនាទីដឹកនាំដ៏ខ្លាំង របស់រដ្ឋាភិបាល។ ទោះបីជាជំនួយបរទេសអាចបង្កើនធនធានគ្រប់កម្រិត និងជួយដល់ការគ្រប់គ្រងប្រព័ន្ធអប់រំក៏ដោយ ក៏មិនអាចមានប្រសិទ្ធភាពដោយពុំមានគម្រោងសង្គមសម្រាប់លើកកំពស់អប់រំ ឬអ្នកខាងក្រៅអាចរៀបចំគម្រោងបែបនេះបានទេ។ ដំណើរការនយោបាយនៅក្នុងប្រទេសគឺជាកត្តាធានាឲ្យមានកំណែទម្រង់ប្រកបដោយភាពជោគជ័យ។ ប្រសិនបើគាំទ្រឲ្យមានការកែប្រែជំនួយបរទេសអាចនឹងជួយឲ្យមានដំណើរឆ្ពោះទៅសម្រេចសកលកម្មអប់រំប្រកបដោយគុណភាពខ្ពស់សម្រាប់មនុស្សទូទៅ។

**ដំណើរការនយោបាយ នៅក្នុងប្រទេសអាច ជាកត្តាធានាសម្រេច ជោគជ័យលើកំណែទម្រង់**

**To order the EFA Global Monitoring Report 2005**
**The Report is for sale online at: http://unesco.org/publishing**

Yes I wish to order ____ copies of the **Education for All – THE QUALITY IMPERATIVE**
**EFA Global Monitoring Report 2005** (ISBN: 92-3-103976-8)
Price: €24 ____ x ____ = ____
Plus flat postage rate for any order: €4.57
Total ____

**Delivery address:**
Last Name: First Name:
Address:
City: Postcode: Country:

**Payment enclosed**
○ Cheque* ○ Visa ○ Eurocard ○ Mastercard
Card number: Expiry date:

*Cheques to the order of UNESCO Publishing in Euros drawn on a bank established in France.

Please send this order form to:
**UNESCO Publishing**, 7 place de Fontenoy, 75352 Paris 07 SP, France
www.unesco.org/publishing e-mail: publishing.promotion@unesco.org fax: +33 1 45 68 57 37

# របាយការណ៍សង្ខេប



គុណភាពស្ថិតក្នុងបេះដូងរបស់អប់រំ។ គុណភាពមានឥទ្ធិពលលើខ្លឹមសារមេរៀនដែលសិស្សរៀន មានឥទ្ធិពលលើសកម្មភាពរៀន លទ្ធផលនៃការសិក្សា និងមានឥទ្ធិពលលើផលប្រយោជន៍ដែលសិស្សទទួលបានពីការអប់រំ។ ដើម្បីធានាថា សិស្សសម្រេចការសិក្សាបានល្អ និងមានជំនាញ និងតម្លៃគុណធម៌ដែលសិស្សអាចយកទៅប្រើតាមផ្លូវល្អស្ថិតក្នុងរបៀបវារៈគោលនយោបាយរបស់ប្រទេសនីមួយៗ។ ដោយរដ្ឋាភិបាលជាច្រើនព្យាមយាមពង្រីកអប់រំមូលដ្ឋាន រដ្ឋាភិបាលទាំងនោះត្រូវប្រឈមមុខនឹងកាតព្វិច្ចមួយដែលត្រូវបំពេញគឺត្រូវធានាថា សិស្សត្រូវរៀនក្នុងសាលាឲ្យបានយូរគ្រប់គ្រាន់ដើមស្រូបយកចំណេះដឹង និងពុទ្ធិយកទៅប្រើក្នុងសង្គមដែលវិវត្តយ៉ាងលឿននេះ។ ការវាយតម្លៃបង្ហាញថា ការធានានេះមិនទាន់ធ្វើបាននៅប្រទេសជាច្រើន។ របាយការណ៍នេះយកភស្តុតាងបានពីការស្រាវជ្រាវទាក់ទងនឹងកត្តានានាដែលកំណត់អំពីគុណភាពមករីភាគ ហើយរបាយការណ៍នេះបានគូសបញ្ជាក់ច្បាស់អំពីគោលនយោបាយគន្លឹះសម្រាប់លើកកំពស់សកម្មភាពរៀន និងបង្រៀន ជាពិសេសនៅប្រទេសដែលមានប្រាក់ចំណូលទាប។ របាយការណ៍នេះក៏តាមដានអំពីជំនួយអន្តរជាតិជួយដល់វិស័យអប់រំ និងតាមដានការរីកចម្រើនឈានទៅសម្រេចគោលដៅទាំង ៦ របស់ការអប់រំសម្រាប់ទាំងអស់គ្នា ដែលកាលពីឆ្នាំ ២០០០ មានប្រទេសប្រមាណ ១៦០ បានប្តេជ្ញាអនុវត្តឲ្យបាននៅវេទិកាអប់រំពិភពលោក។

រូបថតលើក្រប
កុមារក្នុងថ្នាក់រៀនមួយនៅសាលាទីងទីហ៊ីគ្រែន ប្រទេសម៉ាលី ដែលក្នុងថ្នាក់នោះមាន
គ្រូតែមួយនាក់គត់បង្រៀនសិស្ស ៦៥ នាក់។

© CRISPIN HUGHES/PANOS/EDITINGSERVER.COM